**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# អគ្គការអយ្យការ
# អមសាលាដំបូងរាជធានី-ខេត្ត

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ៖

និស្សិតឈ្មោះ **គឹម ភញ្ញនា**

**ទេពច័ន្ទ ពិសី**

សាស្ត្រាចារ្យណែនាំ

កញ្ញា **ផៃ វិជ្ជតា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# **សេចក្តីថ្លែងអំណរគុណ**

នាងខ្ញុំឈ្មោះ **គឹម កញ្ញានា** និងនាងខ្ញុំឈ្មោះ **ទេពច័ន្ទ ពិសី** ជានិស្សិតថ្នាក់បរិញ្ញាបត្រនៃជំនាញនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២២ ឆ្នាំសិក្សា ២០២១-២០២២ ដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ **សូមថ្លែងនូវសេចក្តីកតញ្ញូតាធម៌ និងអំណរគុណជាអនេកប្បការចំពោះ៖**

លោកឪពុក **គឹម ជួណាល់** និងអ្នកម្តាយ **គក់ ជីវ័ន្ត**

លោកឪពុក **ទេព ប៊ុន្ត្រា** និងអ្នកម្តាយ **កែម ស្រីធា**

ដែលលោកទាំងពីរបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា លះបង់កម្លាំងកាយកម្លាំងចិត្ត ពេលវេលា និងខិតខំក្នុងការទំនុកបំរុងគ្រប់សព្វបែបយ៉ាងដល់កូនតាំងពីតូចរហូតដល់ធំដឹងក្តី ព្រមទាំងបានលើកទឹកចិត្តឲ្យកូនប្រឹងប្រែងរៀនសូត្ររហូតដល់បញ្ចប់ថ្នាក់សាកលវិទ្យាល័យ ។

សាស្ត្រាចារ្យ **ផៃ វិជ្ជតា** ដែលជាសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់ និងចំណាយពេលវេលាដ៏មានតម្លៃក្នុងការជួយជ្រោមជ្រែងបង្ហាត់បង្រៀន បណ្តុះបណ្តាល ព្រមទាំងផ្តល់នូវដំបូន្មានល្អៗ ណែនាំក្នុងការតាក់តែង និងកែលម្អទៅលើអត្ថបទសារណាមួយនេះតាំងពីដើមរហូតដល់ចប់ជាស្ថាពរ ។

**ឯកឧត្តមសាកលវិទ្យាធិការ លុយ ចណ្ណា** ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ថ្នាក់ដឹកនាំ មន្ត្រីការិយាល័យ និងលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចែករំលែកនូវចំណេះដឹង ផ្តល់នូវដំបូន្មានល្អៗ បង្ហាត់បង្រៀន និងណែនាំដល់រូបនាងខ្ញុំទាំងពីរនាក់យ៉ាងយកចិត្តទុកដាក់រហូតដល់ការសិក្សាបញ្ចប់បានដោយជោគជ័យ និងប្រកបដោយក្រមវិជ្ជាជីវៈ ។

ជាចុងក្រោយ នាងខ្ញុំទាំងពីររូបសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយ សូមប្រសិទ្ធិពរជ័យជូនចំពោះ **អ្នកមានគុណទាំងពីរ សាស្ត្រាចារ្យ ផៃ វិជ្ជតា ឯកឧត្តមសាកលវិទ្យាធិការ លុយ ចណ្ណា ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ថ្នាក់ដឹកនាំ មន្ត្រីការិយាល័យ និងលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** សូមឲ្យជួបតែសេចក្តីសុខ សេចក្តីចម្រើន សំណាងល្អ សុខភាពល្អពេញបរិបូរណ៍ អាយុយឺនយូរ ធ្វើកិច្ចការអ្វីប្រកបដោយភាពជោគជ័យ ជាពិសេសសូមឲ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាតឃ្លាឡើយ ។

# អារម្ភកថា

យើងខ្ញុំសូមស្វាគមន៍ និងអរគុណចំពោះប្រិយ៍មិត្តដែលបាននឹងកំពុងអាននូវសារណាបញ្ចប់ការសិក្សាមួយនេះជាទីគោរព និងជាទីរាប់អាន ។

អំពីប្រធានបទស្ដីអំពី **"អង្គការអយ្យការ អមសាលាដំបូងរាជធានី~ខេត្ត"** លើកយកមកសរសេរជាសារណាក្នុងការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ គឺក្នុងគោលបំណងចង់បង្ហាញលំអិតអំពីប្រវត្តិនៃការកកើត អំពីរចនាសម្ព័ន្ធ តួនាទី ភារកិច្ច ក៏ដូចជាសិទ្ធិអំណាចរបស់អង្គការអយ្យការជាដើម ។ ប្រធានបទនេះបានផ្តោតសំខាន់ទៅលើ អង្គការអយ្យការដែលស្ថិតនៅអមសាលាដំបូងរាជធានីខេត្ត~ក្រុងក្នុងព្រះរាជាណាចក្រកម្ពុជាដែលបានបំពេញភារកិច្ចក្នុងការការពារប្រយោជន៍សាធារណៈ សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់នៅក្នុងសង្គម ។ អង្គការអយ្យការជាម្ចាស់នៃបណ្តឹងអាជ្ញា ដោយធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌទៅលើបុគ្គលដែលបានប្រព្រឹត្តល្មើសនឹងច្បាប់ ព្រោះជាបញ្ហាដែលជះឥទ្ធិពលអាក្រក់ដល់សង្គមជាតិ ក៏ដូចជារំខានដល់ការអភិវឌ្ឍន៍ប្រទេសជាតិទាំងមូល ។

ជាចុងក្រោយ យើងខ្ញុំយល់ឃើញថា ការសរសេរសារណាមួយនេះអាចនឹងមិនទាន់មានសេចក្តីពេញលេញគ្រប់គ្រាន់នៅឡើយទេ ហើយក៏មិនបរិយាយឲ្យបានល្អិតល្អន់គ្រប់ជ្រុងជ្រោយផងដែរ ដូច្នេះយើងហើយយើងខ្ញុំក៏សូមខន្តីអភ័យទោសនូវរាល់កំហុសខុសឆ្គងទាំងឡាយដែលកើតមានឡើងដោយអចេតនា និងភាពចន្លោះខ្វះខាតផ្សេងៗក្នុងឯកសារនេះ ។ យើងខ្ញុំក៏សូមទទួលយកនូវរាល់មតិរិះគន់ទាំងឡាយក្នុងន័យស្ថាបនាពីសំណាក់ប្រិយមិត្តអ្នកអានគ្រប់រូប ក៏ដូចជាសិស្សនិស្សិត និងសាស្ត្រាចារ្យផងដែរ ដើម្បីឲ្យអត្ថបទមួយនេះកាន់តែមានខ្លឹមសារពេញលេញបន្ថែមទៀត ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ..................................................... ១

**ជំពូកទី១**
**សញ្ញាណទូទៅ នៃអង្គការអយ្យការ**

**ផ្នែកទី១ និយមន័យ** ..................................................... ៤

**កថាខណ្ឌទី១ ប្រវត្តនៃអង្គការអយ្យការ** ..................................................... ៥

១. ប្រព័ន្ធចោទប្រកាន់របស់ប្រទេសកម្ពុជានាសម័យពីដើម ..................................................... ៥

២. ការបង្កើតអង្គការអយ្យការនៅប្រទេសកម្ពុជាពីឆ្នាំ ១៩៣៧ ដល់បច្ចុប្បន្ន ..................................................... ៧

ក. ពីឆ្នាំ ១៩៣៧ ដល់ឆ្នាំ ១៩៧០ ..................................................... ៧

ខ. ពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥ ..................................................... ៨

គ. ពីឆ្នាំ ១៩៧៥ មកទល់ឆ្នាំ ១៩៧៩ ..................................................... ៨

ឃ. ពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៩២ ..................................................... ៩

ង. ពីឆ្នាំ ១៩៩៣ ដល់បច្ចុប្បន្ន ..................................................... ១០

**កថាខណ្ឌទី២ គោលការណ៍នៃអង្គការអយ្យការ** ..................................................... ១០

១. គោលការណ៍ឯកភាព ឬគោលការណ៍ឋានានុក្រម ..................................................... ១១

២. គោលការណ៍អវិភាគ ..................................................... ១២

៣. គោលការណ៍ឯករាជ្យភាព ..................................................... ១២

៤. គោលការណ៍ដទៃទៀត ..................................................... ១២

**ផ្នែកទី២ ការបែងចែក និងរចនាសម្ព័ន្ធ** ..................................................... ១៣

**កថាខណ្ឌទី១ តុលាការជាន់ទាប** ..................................................... ១៤

១.១. សាលាដំបូង ..................................................... ១៤

១.១.១. រចនាសម្ព័ន្ធនៃសាលាដំបូង និងអយ្យការអមសាលាដំបូង ..................................................... ១៥

ក. សមាសភាពសាលាដំបូង ..................................................... ១៥

ខ. សមាសភាពអយ្យការអមសាលាដំបូង ..................................................... ១៥

១.១.២. តួនាទី និងភារកិច្ចអយ្យការអមសាលាដំបូង ..................................................... ១៥

១.២. តុលាការយោធា ..................................................... ១៦

១.២.១. សមាសភាព ..................................................... ១៧

ក. សមាសភាពតុលាការយោធា ..................................................... ១៧

ខ. សមាសភាពអយ្យការអមតុលាការយោធា ........ ១៧
១.២.២. តួនាទី និងភារកិច្ចតុលាការយោធា........ ១៧
**កថាខណ្ឌទី២ តុលាការជាន់ខ្ពស់........ ១៨**
២.១. សាលាឧទ្ធរណ៍ ........ ១៨
២.១.១. សមាសភាព........ ២០
ក. សមាសភាពសាលាឧទ្ធរណ៍ ........ ២០
ខ. សមាសភាពមហាអយ្យការអមសាលាឧទ្ធរណ៍ ........ ២០
២.១.២. តួនាទី និងភារកិច្ចមហាអយ្យការអមសាលាឧទ្ធរណ៍ ........ ២១
២.២. តុលាការកំពូល........ ២២
២.២.១. សមាសភាព........ ២២
ក. សមាសភាពតុលាការកំពូល ........ ២៣
ខ. សមាសភាពមហាអយ្យការតុលាការកំពូល ........ ២៣
២.២.២. តួនាទី និងភារកិច្ចនៃមហាអយ្យការអមតុលាការកំពូល........ ២៣
**កថាខណ្ឌទី៣ វិសមិតភាព........ ២៤**

## ជំពូកទី២
## តំណាងអយ្យការ

**ផ្នែកទី១ សញ្ញាណទូទៅ ........ ២៦**
**កថាខណ្ឌទី១ និយមន័យ ........ ២៦**
**កថាខណ្ឌទី២ ការជ្រើសរើស ........ ២៧**
២.១. ការជ្រើសរើសនាពេលពីមុន (ពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៩២)........ ២៧
២.១.១. ការជ្រើសរើស និងការតែងតាំងរដ្ឋអាជ្ញា-អគ្គរដ្ឋអាជ្ញា និងការអប់រំ........ ២៧
២.១.២. ការបង្កើតមហាអយ្យការអមតុលាការកំពូល និងការតែងតាំងអគ្គរដ្ឋអាជ្ញា អគ្គរដ្ឋអាជ្ញារង និងរដ្ឋអាជ្ញា ២៩
២.២. ការជ្រើសរើសនាពេលបច្ចុប្បន្ន ........ ២៩
**កថាខណ្ឌទី៣ ការតែងតាំង និងការលុបឈ្មោះចេញពីក្របខណ្ឌ ........ ៣០**
៣.១. ការធ្វើកម្មសិក្សា និងការតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា ........ ៣០
៣.១.១. ការធ្វើកម្មសិក្សា ........ ៣០
៣.១.២. ការតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា ........ ៣០
៣.២. ការលុបឈ្មោះចេញពីក្របខណ្ឌ........ ៣០
៣.៣. ការដំឡើងថ្នាក់ និងឋានន្តរស័ក្ត........ ៣១
៣.៣.១. ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិរបស់ព្រះរាជអាជ្ញា........ ៣១

៣.៣.២. ចំពោះការដាក់ពិន្ទុត្រូវអនុវត្តដូចខាងក្រោម ........ ៣១
៣.៣.៣. សមាសភាពនៃគណៈកម្មការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ........ ៣២
៣.៤. ការផ្តាច់ពីមុខងារ ការដាក់ឲ្យនៅក្រៅក្របខណ្ឌ ការដាក់ឲ្យនៅទំនេរ និងការលុបឈ្មោះព្រះរាជអាជ្ញា .... ៣៣
៣.៤.១. ការផ្តាច់ពីមុខងារ និងការដាក់ឲ្យនៅក្រៅក្របខណ្ឌ ........ ៣៤
៣.៤.២. ការដាក់ឲ្យនៅទំនេរ ........ ៣៤
៣.៤.៣. ការលុបឈ្មោះព្រះរាជអាជ្ញា ........ ៣៥
**ផ្នែកទី២ តួនាទី និងភារកិច្ចរបស់ព្រះរាជអាជ្ញា** ........ ៣៥
**កថាខណ្ឌទី១ ការអនុវត្តបណ្តឹងអាជ្ញា** ........ ៣៦
១.១. បណ្តឹងអាជ្ញា ........ ៣៦
**កថាខណ្ឌទី២ ការផុតរលត់នៃបណ្តឹងអាជ្ញា** ........ ៣៦
២.១. មរណភាពនៃជនល្មើស ........ ៣៦
២.២. ការផុតអាជ្ញាយុកាល ........ ៣៧
២.៣. ការលើកលែងទោសជាទូទៅ ........ ៣៧
២.៤. និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ ........ ៣៩
២.៥. អាជ្ញាអស់ជំនុំ ........ ៣៩
**កថាខណ្ឌទី៣ សិទ្ធិអំណាចរបស់ព្រះរាជាអាជ្ញា** ........ ៤០
៣.១. អំណាចរបស់ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង ........ ៤០
៣.១.១. អំណាចរបស់ព្រះរាជអាជ្ញា ........ ៤០
៣.១.២. អំណាចរបស់ព្រះរាជអាជ្ញារង ........ ៤១
៣.២. អំណាចរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ........ ៤១

## ជំពូកទី៣
## ព្រះរាជអាជ្ញាក្នុងដំណើរការនីតិវិធី នៃរឿងក្តីព្រហ្មទណ្ឌ

**ផ្នែកទី១ នីតិវិធីស៊ើបអង្កេត** ........ ៤២
**កថាខណ្ឌទី១ ការស៊ើបអង្កេតជាក់ស្តែង** ........ ៤២
១.១. ការឆែកឆេរ ........ ៤៤
១.២. ការឃាត់ខ្លួន ........ ៤៥
១.២.១. រយៈពេលឃាត់ខ្លួនសម្រាប់អនីតិជន ........ ៤៥
១.២.២. បែបបទនៃការឃាត់ខ្លួន ........ ៤៦
ក. ពេលបានទទួលបញ្ជាឲ្យឃាត់ខ្លួនពីព្រះរាជអាជ្ញា មន្ត្រីនគរបាលយុត្តិធម៌ត្រូវ ........ ៤៦
ខ. សិទ្ធិជួយប្រាស្រ័យពីមេធាវីក្នុងពេលឃាត់ខ្លួន ........ ៤៦

គ. សិទ្ធិទទួលជំនួយពីគ្រូពេទ្យក្នុងពេលឃាត់ខ្លួន......................................................................................៤៧
១.៣ ការបញ្ជូនខ្លួន ...............................................................................................................................៤៧
**កថាខណ្ឌទី២ ការស៊ើបអង្កេតបឋម** .............................................................................................៤៧
២.១. ការឆែកឆេរ...................................................................................................................................៤៨
២.២. ការបញ្ជាឲ្យចូលខ្លួន.....................................................................................................................៤៩
**ផ្នែកទី២ ដំណាក់កាលនៃការចោទប្រកាន់** ......................................................................................... ៥០
**កថាខណ្ឌទី១ ការតម្កល់រឿងទុកឥតចាត់ការ**................................................................................... ៥១
១.១. មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ.................................................................................... ៥១
១.២. នីតិវិធីក្នុងការអនុវត្តការតម្កល់រឿងទុកឥតចាត់ការ.........................................................................៥២
**កថាខណ្ឌទី២ ការចោទប្រកាន់**.........................................................................................................៥២
២.១. ការបើកការស៊ើបសួរ.....................................................................................................................៥៣
២.១.១. លក្ខខណ្ឌដែលនាំឲ្យមានការបើកការស៊ើបសួរ...........................................................................៥៣
២.១.២. នីតិវិធីនៃការបើកការស៊ើបសួរ.................................................................................................... ៥៤
ក. ការបើកការស៊ើបសួរតាមរយៈបណ្តឹង ដែលមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី .................. ៥៤
ខ. ការបើកការស៊ើបសួរតាមរយៈសំណុំរឿងបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌ .......................... ៥៤
២.២. ការបញ្ជូនទៅជំនុំជំរះផ្ទាល់ ............................................................................................................ ៥៥
២.២.១. លក្ខខណ្ឌដែលនាំឲ្យមានការបញ្ជូនទៅជំនុំជម្រះផ្ទាល់.................................................................. ៥៥
២.២.២. នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់......................................................................................... ៥៥
២.៣. ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ................................................................................................... ៥៦
២.៣.១. លក្ខខណ្ឌនៃការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ............................................................................... ៥៦
២.៣.២. នីតិវិនៃការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម..................................................................................... ៥៦
**ផ្នែកទី៣ ព្រះរាជអាជ្ញាក្នុងដំណាក់កាលនៃការជំនុំជម្រះ**.................................................................... ៥៦
**កថាខណ្ឌទី ១ វិធានទូទៅនៃការជំនុំជម្រះ**.........................................................................................៥៧
**កថាខណ្ឌទី២ ការកោះហៅ** .............................................................................................................៥៧
**សេចក្តីសន្និដ្ឋាន** ............................................................................................................................ ៥៩
**អនុសាសន៍** .................................................................................................................................... ៦០

**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅសម័យមុនៗ ក្នុងសម័យរាជាធិបតេយ្យផ្តាច់ការ ព្រះមហាក្សត្រមានអំណាចអធិបតេយ្យដោយកាន់កាប់អំណាចទាំងបីគឺ អំណាចនីតិប្រតិបត្តិ អំណាចនីតិបញ្ញត្តិ និងអំណាចតុលាការ ។ ព្រះរាជអាជ្ញាប្តឹងសុំឲ្យអនុវត្តច្បាប់ក្នុងឋានៈជាព្រះរាជតំណាង និងក្នុងនាមព្រះមហាក្សត្រដែលជាម្ចាស់អំណាចអធិបតេយ្យ ប៉ុន្តែនៅសម័យក្រោយ ព្រះមហាក្សត្រលែងមានអំណាចអធិបតេយ្យបែបនេះទៀតហើយ ។ ប្រទេសជាច្រើនដែលរក្សាទុករាជានិយមបានប្រកាន់យករបបរាជានិយមអាស្រ័យធម្មនុញ្ញ ដោយក្នុងរបបនោះអំណាចទាំងអស់ត្រូវអនុវត្តដោយតំណាងប្រជាពលរដ្ឋតាមរយៈ សភា រដ្ឋាភិបាល តុលាការ និងតំណាងអយ្យការ ។

ក្នុងប្រព័ន្ធច្បាប់ប្រទេសមួយចំនួនគេគិតថា *ព្រះរាជអាជ្ញាចាត់ការក្នុងនាម និងដើម្បីផលប្រយោជន៍ប្រជាពលរដ្ឋទាំងមូលដែលជាម្ចាស់អំណាចអធិបតេយ្យ* ឬនិយាយម្យ៉ាងទៀតថា *ព្រះរាជអាជ្ញាចាត់ការអ្វីមួយក្នុងនាមសង្គម ឬប្រទេសទាំងមូល មិនមែនដើម្បីបុគ្គលណាម្នាក់ ឬអង្គការណាមួយទេ* ។ ការកំណត់អត្តសញ្ញាណឲ្យបានច្បាស់លាស់នៃអំណាចរបស់ព្រះរាជអាជ្ញា អាចមានអានុភាពជំរះការមានមន្ទិលសង្ស័យទៅលើចំណាត់ការខ្លះៗដែលរដ្ឋាភិបាល ឬមន្ត្រីរដ្ឋាភិបាលជាភាគី ឬការប្រើអំណាចរដ្ឋាភិបាលដោយមិនត្រឹមត្រូវទៅលើភាគីមួយទៀតដែលជារាស្ត្រសាមញ្ញ ។

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលប្រកាន់យកប្រព័ន្ធច្បាប់ស៊ីវិល (Civil Law) ដោយក្នុងនោះបានប្រើប្រាស់ប្រព័ន្ធនីតិវិធីព្រហ្មទណ្ឌដែលមានអង្គការចោទប្រកាន់មួយគឺ **អង្គការអយ្យការ** និងមិនប្រើប្រព័ន្ធចោទប្រកាន់គ្នាទៅវិញទៅមកដោយបុគ្គលឯកជនខ្លួនឯងឡើយ ។ ហេតុដូច្នេះហើយ ទើបគេឃើញមានវត្តមានរបស់អង្គការអយ្យការស្ថិតនៅអមជាមួយតុលាការកម្ពុជាគ្រប់ជាន់ថ្នាក់នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ដែលមានតំណាងអយ្យការជាអ្នកអនុវត្តបណ្តឹងអាជ្ញាក្នុងនាមដើម្បីផលប្រយោជន៍ទូទៅដល់សង្គមជាតិ ។ នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាត្រង់មាត្រា ១៣០ថ្មី បានចែងថា *មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា* និងក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា ២៧ កថាខណ្ឌទី១ វាក្យខណ្ឌទី១ បានចែងថា *អង្គការអយ្យការធ្វើការចោទប្រកាន់ពី បទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់* ដែលនេះជាការបង្ហាញផ្តល់នូវអំណាចតាមរយៈផ្លូវច្បាប់ដល់អង្គការអយ្យការក្នុងការធ្វើបណ្តឹងអាជ្ញា ដែលជាបណ្តឹងមួយមានគោលបំណងពិនិត្យទៅលើអត្ថិភាព និងនិត្ថិភាពនៃបទល្មើស ដើម្បីបង្ហាញឲ្យឃើញពីពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននោះតាមច្បាប់កំណត់ ។ កាលណាមានអង្គការអយ្យការជាអ្នកធ្វើការចោទប្រកាន់ជនល្មើស នោះសុវត្ថិភាពជនរងគ្រោះក៏ត្រូវបានធានា និងអាចធ្វើឲ្យជនល្មើសមានការរាងចាលក្នុងការប្រព្រឹត្តបទល្មើស ដោយសារតែជន

ល្មើសនឹងត្រូវបានផ្តន្ទាទោសតាមច្បាប់យ៉ាងជាក់ស្តែង ហើយវាជាបច្ច័យរិជ្ជមានធ្វើឲ្យអ្នកដទៃមិនហ៊ានយកតម្រាប់តាមជនល្មើសទៀត ។

ដូចនេះ ដើម្បីយល់ដឹងបន្ថែមអំពីអង្គការអយ្យការ សារណានេះនឹងរៀបរាប់អំពីអង្គកានេះតាមកម្រិតថ្នាក់បរិញ្ញាបត្រ ដើម្បីជាការចែករំលែកចំណេះដឹងជូនដល់មិត្តអ្នកអានទាំងឡាយ ជាពិសេសសម្រាប់មិត្តអ្នកអានណាដែលចង់ក្លាយខ្លួនជា តំណាងអយ្យការ នាថ្ងៃអនាគត ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយហេតុថា **អង្គអយ្យការអមសាលាដំបូងរាជធានី~ខេត្ត** គឺជាតួអង្គដែលធានាដល់សន្តិសុខ និងស្ថេរភាពសង្គម ជាពិសេសសិទ្ធិមនុស្ស ។ ដូចនេះហើយ អង្គការនេះពិតជាមានសារៈសំខាន់ណាស់នៅក្នុងការអនុវត្តកាតព្វកិច្ចក៏ដូចជាមុខងារផ្សេងៗ ជាពិសេសនោះគឺតួនាទី និងភារកិច្ចយ៉ាងសំខាន់ក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌនៅដំបូង ។ ដើម្បីយល់ដឹងឲ្យកាន់តែច្បាស់នូវអង្គការនេះ ទើបយើងត្រូវដឹងថាៈ

តើអ្វីជាអង្គការអយ្យការ ?

តើនរណាជាអ្នកតំណាងឲ្យអង្គការនេះ ?

តើតំណាងអង្គការអយ្យការមានការអនុវត្តតួនាទី និងសិទ្ធិអំណាច យ៉ាងដូចម៉េចខ្លះ ?

តើអង្គការអយ្យការចូលរួមអ្វីខ្លះនៅក្នុងកិច្ចនីតិវិធីតុលាការអមសាលាដំបូងរាជធានី~ខេត្ត ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវនេះ គឺមានគោលបំណងក្នុងការចែករំលែកនូវចំណេះដឹងខ្លះៗ អំពីអង្គការអយ្យការថាតើអង្គការអយ្យការមានសារៈប្រយោជន៍យ៉ាងណាខ្លះក្នុងប្រព័ន្ធតុលាការ ឬនៅក្នុងវិស័យយុត្តិធម៌ ? ហេតុអ្វីត្រូវបង្កើតអង្គការអយ្យការនេះ ? តើអង្គការអយ្យការនេះជាអ្វី ? តើអង្គការនេះបានចូលរួមអ្វីខ្លះក្នុងកិច្ចនីតិវិធីតុលាការអមសាលាដំបូងរាជធានី~ខេត្ត ? ហើយយើងខ្ញុំជឿជាក់ថា ការស្រាវជ្រាវនេះជាវណ្ណកម្មមួយសម្រាប់ជាជំនួយដល់មិត្តៗនិស្សិត ដែលមានបំណងចង់សិក្សាស្វែងយល់ពីស្ថាប័ននេះ ដើម្បីជាជំនួយដល់សិក្សាការស្រាវជ្រាវ ការប្រកបអាជីពវិជ្ជាជីវៈក្នុងវិស័យតុលាការ ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

សម្រាប់ការស្រាវជ្រាវទៅលើសារណានេះ គឺមានដែនកំណត់ផ្តោតទៅលើការសិក្សាទាក់ទងនឹងអង្គការអយ្យការអមសាលាដំបូងរាជធានី~ខេត្ត ដោយឡែកសម្រាប់តុលាការយោធា គឺយើងខ្ញុំលើកយកតែចំណុចដែលទាក់ទងទៅនឹងរចនាសម្ព័ន្ធនៃតុលាការនេះតែប៉ុណ្ណោះ ។ លើសពីនេះទៅទៀត ប្រធានបទនេះបានផ្តោត

ទៅលើការសិក្សាអំពីការចូលរួមរបស់តំណាងអយ្យការដែលនៅអមសាលាដំបូងរាជធានី-ខេត្ត ក្នុងកិច្ចដំណើរការនៃរឿងក្តីព្រហ្មទណ្ឌដែលមានដូចជា ក្នុងការស៊ើបអង្កេត ការចោទប្រកាន់ និងការជំនុំជម្រះក្តី ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានអត្ថប្រយោជន៍ជាជំនួយស្មារតី ជាពុទ្ធិ និងពង្រីកចំណេះដឹង ក៏ដូចជាការជំនួយជាធនធានចំណេះដឹងសម្រាប់បំពេញមុខងារក្នុងស្ថាប័នអយ្យការ ។ ជាពិសេស មិត្តអ្នកអានគ្រប់រូបអាចស្វែងយល់អំពីប្រវត្តិ តួនាទី និងកិច្ចការផ្សេងៗ ជាលក្ខណៈទ្រឹស្តីរបស់អង្គការអយ្យការឲ្យកាន់តែមានភាពច្បាស់លាស់ ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ចំពោះការប្រមូលទិន្នន័យឯកសារផ្សេងៗដែលទាក់ទងប្រធានបទនេះ យើងខ្ញុំទាំងពីរនាក់បានខិតខំព្យាយាម ស្រាវជ្រាវជាលក្ខណៈទូទៅនៃប្រធានបទនេះ នៅតាមប្រព័ន្ធអ៊ីនធើណេត ក៏ដូចជាការសាកសួរសុំយោបល់ពីសំណាក់សាស្ត្រាចារ្យផ្នែកច្បាប់ សិស្សច្បង និងមិត្តរួមការងារ ។ ជាពិសេស ឯកសារដែលមានលក្ខណៈជាលាយលក្ខណ៍អក្សរដូចជា សៀវភៅ អត្ថបទផ្សេងៗ ដែលយើងខ្ញុំទាំងពីរបានព្យាយាមរកនៅតាមបណ្ណាល័យនានាក្នុងរាជធានីភ្នំពេញ តាមតូបលក់សៀវភៅ បណ្ណាគារ គេហទំព័រជាតិ និងបរទេសមួយចំនួនទៀតដែលជាគ្រឹះនាំឲ្យអាចដំណើរការសរសេរសារណានេះបានដោយជោគជ័យ ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះចែកចេញជា ០៣ (បី) ជំពូកៈ

**ជំពូកទី១ សញ្ញាណទូទៅ នៃអង្គការអយ្យការ** រៀបរាប់អំពីប្រវត្តិកកើតនៃអង្គការអយ្យការ និងការបែងចែក និងរចនាសម្ព័ន្ធនៃអង្គការអយ្យការ ។

**ជំពូកទី២ តំណាងអយ្យការ** រៀបរាប់អំពីតួនាទី សិទ្ធិអំណាច និងសមត្ថកិច្ចរបស់តំណាងអយ្យការតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងបញ្ចូលនូវការអនុវត្តបណ្តឹងអាជ្ញាដែលជាសមត្ថកិច្ចផ្តាច់មុខរបស់ អយ្យការ ។

**ជំពូកទី៣ ព្រះរាជអាជ្ញាក្នុងដំណើរការនីតិវិធី នៃរឿងក្តីព្រហ្មទណ្ឌ** រៀបរាប់អំពីវត្តមាន និងតួនាទីរបស់អយ្យការក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌនូវតាមសាលាដំបូងរាជធានី~ខេត្ត ដែលត្រូវបានបែងចែកដូចជា ការស៊ើបអង្កេត ការចោទប្រកាន់ និងការជំនុំជម្រះ ។

# ជំពូកទី១

# សញ្ញាណទូទៅ នៃអង្គការអយ្យការ

# ជំពូកទី១
# សញ្ញាណទូទៅ នៃអង្គការអយ្យការ

## ផ្នែកទី១ និយមន័យ

ពាក្យ "អង្គការ" បានមកពីពាក្យ "អង្គ" *(រាងកាយ, ដងខ្លួន, ដើមហេតុ, ហេតុផល, មូលដ្ឋាន,* និងពាក្យ "ការ" *(កាយ៍ ឬការ្យ គឺកិច្ច ឬ អំពើដែលត្រូវធ្វើ)* គឺជា ស្ថាប័ន ឬសមាគមមួយដែលមានគោលដៅរួម និងត្រូវបានផ្សារភ្ជាប់ទៅនឹងបរិយាកាសខាងក្រៅ[១] ។ ពាក្យ "អយ្យការ" គឺបានមកពីពាក្យថា "អយ្យ" ជាពាក្យបាលីដែលមានន័យដូចគ្នាទៅនឹងពាក្យ "អរិយ" ដែរ ដែលប្រែមកថា *"អ្នកមានត្រកូលខ្ពង់ខ្ពស់, អ្នកដែលគេត្រូវគោរពកោតខ្លាច, ម្ចាស់, លោក ឬអ្នកជាម្ចាស់, អ្នកប្រសើរដោយជាតិ (បើស្ត្រីជាអយ្យា)"* ។ ដូច្នោះ "អយ្យការ" គឺ "ឈ្មោះច្បាប់មួយក្រុមមានគតិសម្រាប់ចោទប្រកាន់ព្រមទាំងវិនិច្ឆ័យការផែនដី៖ ច្បាប់អយ្យការ, ក្រុមអយ្យការ, អយ្យការសឹក, ច្បាប់អាជ្ញាសឹក"[២] ។ តាមនិយមន័យនៃពាក្យនេះមានលក្ខណៈត្រូវគ្នាខ្លះដែរនឹងនិយមន័យគតិយុត្តត្រង់សញ្ញាណថា "សម្រាប់ចោទប្រកាន់" និង "អ្នកដែលត្រូវគេគោរពកោតខ្លាច" ព្រោះវាអាចទាក់ទងនឹងអំណាចរបស់អយ្យការក្នុងការចោទប្រកាន់ប្រឆាំងនឹងបទល្មើស ប៉ុន្តែអយ្យការគ្មានអំណាចក្នុងការវិនិច្ឆ័យសេចក្តីចេញជាសាលក្រមឡើយ ។

អង្គការអយ្យការ គឺជាស្ថាប័នមួយរបស់រដ្ឋសំរាប់ដំណើរការបណ្តឹងសាធារណៈ ឬបណ្តឹងព្រហ្មទណ្ឌ ហើយស្ថាប័ននេះមាន ព្រះរាជអាជ្ញា/រដ្ឋអាជ្ញាធ្វើការដើម្បីឲ្យបានសំរេចនូវបេសកកម្មរបស់អង្គការនេះ[៣] ។ នៅក្នុងប្រព័ន្ធយុត្តាធិការ ស្ថាប័ននេះអនុវត្តនូវការធ្វើបណ្តឹងអាជ្ញាក្នុងនាមតំណាងឲ្យផលប្រយោជន៍ទូទៅក្នុងសង្គម គឺធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់[៤] ។ អង្គការអយ្យការធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន ។ ដូច្នេះបានសេចក្តីថា មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ដើម្បីធានាសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងអនុវត្តមុខងារផ្សេងៗទៀតតាមការកំណត់របស់ច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

ជាទូទៅ ស្ថាប័នអយ្យការស្ថិតនៅក្នុងបរិវេណនៃស្ថាប័នតុលាការដែរ ប៉ុន្តែស្ថាប័ននេះមានអ្នកដឹកនាំផ្សេងដាច់ដោយឡែកពីតុលាការ ។ ចៅក្រមអយ្យការ ឬព្រះរាជអាជ្ញា/រដ្ឋអាជ្ញា មានសិទ្ធិកេណ្ឌកងកម្លាំង

[១] វចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត ។
[២] វចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត ។
[៣] លោក កុយ នាម និងលោក ឡុង បញ្ញាវុធ, សៀវភៅស្តីពីអយ្យការ ប្រវត្តិ និងការសិក្សាប្រៀបធៀប, បោះពុម្ពឆ្នាំ ២០០៦ ។
[៤] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៤ ។

សាធារណៈដោយផ្ទាល់ជាជំនួយរបស់ខ្លួនក្នុងការបំពេញភារកិច្ច ក៏ដូចជានីតិវិធីតុលាការចំពោះចំណាត់ការក្នុងរឿងក្តីព្រហ្មទណ្ឌ ជាមួយគ្នានេះផងដែរចៅក្រមអយ្យការត្រូវតែមានវត្តមានក្នុងពេលសវនាការសម្រាប់រឿងក្តីព្រហ្មទណ្ឌជានិច្ច ។

## កថាខណ្ឌទី១ ប្រវត្តិនៃអង្គការអយ្យការ

**«អង្គការអយ្យការ»** គឺជាស្ថាប័នមួយរបស់រដ្ឋសម្រាប់ដំណើរការនូវបណ្តឹងសាធារណៈ ឬបណ្តឹងព្រហ្មទណ្ឌ ដែលត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ត្រង់មាត្រា ១៣១ ថ្មី (មាត្រា ១២២ ចាស់) បានកំណត់សេចក្តីថា ***"មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា"*** ដែលខ្លឹមសារនេះអាចបកស្រាយបានថា អង្គការអយ្យការមានអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ដែលជាអ្នកតំណាងឲ្យស្ថាប័នមួយនេះមានសិទ្ធិអំណាចផ្តាច់មុខក្នុងការធ្វើការចោទប្រកាន់ចំពោះបណ្តឹងព្រហ្មទណ្ឌគ្រប់ប្រភេទដោយអនុទ្បោមតាមគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ និងគោលការណ៍កាលានុវត្តភាពក្នុងគោលបំណងការពារផលប្រយោជន៍សង្គម ធានានូវការអនុវត្តនីតិវិធីព្រហ្មទណ្ឌ ដូចដែលមានចែងក្នុងមាត្រា ១២៧ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៩ ។

នៅប្រទេសកម្ពុជាគេឃើញមានវត្តមានស្ថាប័ននេះក្នុងប្រព័ន្ធយុត្តាធិការមួយនេះ ចាប់ផ្តើមចាប់ពីកម្ពុជាបានស្ថិតនៅក្រោមអាណានិគមន៍និយមបារាំង ដែលបានទទួលនូវប្រព័ន្ធគ្រប់គ្រងរដ្ឋតាមសម័យទំនើបក្រោមការដាក់នូវអាណានិគមន៍នេះ ។ អង្គការអយ្យការនេះបានលេចរូបរាងឡើងចាប់តាំងពីពេលនោះមក និងឆ្លងកាត់តាមការវិវត្តរបស់ប្រទេសនេះទៅតាមសម័យកាលរហូតមកដល់បច្ចុប្បន្ននេះ ហើយការវិវត្តរបស់ស្ថាប័នអយ្យការនៃប្រទេសកម្ពុជាមានដូចជាៈ **(១). ប្រព័ន្ធចោទប្រកាន់របស់ប្រទេសកម្ពុជានាសម័យពីដើម (២). ការបង្កើតអង្គការអយ្យការនៅកម្ពុជាពីឆ្នាំ១៩៣៧ ដល់ឆ្នាំបច្ចុប្បន្ន ដែលត្រូវបានវិវត្តន៍ទៅតាមសម័យកាល** ។

### ១. ប្រព័ន្ធចោទប្រកាន់របស់ប្រទេសកម្ពុជានាសម័យពីដើម

នៅក្នុងប្រទេសកម្ពុជានាសម័យមុនអាណានិគមបារាំង (១៨៦៣) ការចោទប្រកាន់នៅក្នុងរឿងព្រហ្មទណ្ឌ គឺជាបន្ទុករបស់បុគ្គលម្នាក់ៗដែលជាជនរងគ្រោះពីអំពើប្រព្រឹត្តរបស់មនុស្សម្នាក់ទៀត ។ ការចោទប្រកាន់នេះអាចបញ្ជាក់បានដោយហេតុថា ដើមបណ្តឹងជាអ្នកមានបន្ទុកបង់ប្រាក់ប្រដាប់ក្តី និងផ្តល់ពាក្យរាយការណ៍បណ្តឹងរបស់ខ្លួន ផ្ទុយពីសម័យបច្ចុប្បន្នយើងដែលរដ្ឋទទួលភារៈចំពោះរឿងទាំងអស់នេះ[៥] ។ នៅក្នុងមាត្រា ១៦ នៃក្រមទទួលបណ្តឹងចែងថា *"ទោះអ្នកផងប្តឹងចោទថាគេតប់ ដាល់វាយបាញ់ ចាក់កាប់ ទទូលជាំ មុត ធ្លុះ រង្កើបែកបាក់ ខ្ទាក់ បើមកប្តឹងឲ្យកត់ត្រាបួស ស្លាកស្នាម ក្នុងថ្ងៃនោះ ឬថ្ងៃក្រោយ គប្បីឲ្យទទួលកត់ត្រាបួសបាន ។*

[៥] លោក កុយ នាម និងលោក ឡុង បញ្ញារុធ, សៀវភៅស្តីពីអយ្យការ ប្រវត្តិ និងការសិក្សាប្រៀបធៀប, បោះពុម្ពឆ្នាំ ២០០៦ ។

*បើកន្លងទៅរយៈពេលពី ៣-៤ថ្ងៃនោះ នឹងទទួលកត់របួសពុំបានឡើយ បើដើមចោទធ្វើពាក្យស្រេចមកប្ដឹង ទទួលបណ្ដឹងបាន"*[៦] មានន័យថា តុលាការអាចទទួលបណ្ដឹង និងកត់ត្រាភស្តុតាងនៃការខូចខាតតែក្នុងថ្ងៃ ឬមួយថ្ងៃក្រោយមានការខូចខាត បើចាប់ពីបីថ្ងៃទៅតុលាការមិនទទួលយកបណ្ដឹងនេះទេ ឬតុលាការអាចទទួលបណ្ដឹងបានដែរ បើជនរងគ្រោះធ្វើពាក្យបណ្ដឹងដោយសរសេររ៉ាយរាប់ពីហេតុការណ៍ដែលកើតឡើង ។ នេះអាចបញ្ជាក់ថា ដើមបណ្ដឹងជាអ្នកមានបន្ទុកត្រូវផ្ដល់ព័ត៌មានគ្រប់គ្រាន់ដល់តុលាការពីបទល្មើស ហើយការផ្ដល់ព័ត៌មាននេះត្រូវមានពេលវេលាកំណត់ទៀត ។ ក្នុងមាត្រា ១៦ បានចែងថា *"ភាគីប្ដឹងត្រូវចែងពីការទាមទារឲ្យកោះហៅចុងចោទ ទោះបីដើមបណ្ដឹងនោះមានឋានៈបែបណាក្ដី ប្រភេទនៃបណ្ដឹងនោះជាអ្វីក្ដី បើកាលណាមិនមានការបញ្ជាក់ឲ្យកោះហៅទេនោះ តុលាការមិនត្រូវទទួលពាក្យបណ្ដឹងនោះទេ"*[៧] ។ ទាំងនេះជាលក្ខណៈជាឯកជននៃបណ្ដឹងដែលខុសពីបណ្ដឹងសាធារណៈសម័យបច្ចុប្បន្ន ដោយការកោះហៅភាគីណាមកសាកសួរជាភារកិច្ចរបស់អាជ្ញាធរតុលាការ ។

ចំណែកឯប្រាក់សំរាប់ដំណើរការរឿងក្ដីក៏ជាបន្ទុករបស់ដើមបណ្ដឹងដែរ ។ ប្រាក់ទាំងនោះមានដូចជា ថ្លៃសំណាររជើង (ថ្លៃកោះហៅ) ប្រាក់ដំណាច់ដីស (ថ្លៃដីសសំរាប់សរសេរចម្លើយឲ្យទៅតុលាការ) ថ្លៃរក្សាពាក្យ (ថ្លៃសំរាប់ទុកដាក់ឯកសារបណ្ដឹងនៅក្នុងតុលាការ) ថ្លៃផ្គុំពាក្យ (ថ្លៃសំរាប់ការដាក់ញត្តិទាមទារអ្វីមួយ) ថ្លៃខាឃុំ (ថ្លៃចំណាយលើការឃុំឃាំងបណ្ដោះអាសន្ន) ។ ថ្លៃដំណើរការយុត្តិធម៌នេះត្រូវបានលុបចោលទៅវិញនៅឆ្នាំ ១៨៩៧ ប៉ុន្តែថ្លៃដាក់ពាក្យបណ្ដឹងនៅរក្សាទុកដដែល[៨] ។ ពាក្យបណ្ដឹងដើម្បីអាចទទួលបានត្រូវប្រថាប់ត្រាដែលគេហៅថា **"ត្រាបូកែវ"** ដែលមានតម្លៃ ១រៀល នៅសម័យចុងសតវត្សមុននោះ ។ ប៉ុន្តែនៅពេលជាមួយគ្នាដែលជនរងគ្រោះមានភារៈផ្ដើមការចោទប្រកាន់ ឬបណ្ដឹងជាឯកជននេះ គេក៏ឃើញលេចសញ្ញាខ្លះៗនៃបណ្ដឹងសាធារណៈ ដែលផ្ដើមដោយមន្ត្រីមួយបែបដែលគេហៅថា **"អាជ្ញាហ្លួង"**[៩] ។ អាជ្ញាហ្លួង គឺជាប្រេសិតរបស់ព្រះមហាក្សត្រ ដើម្បីសង្កេតការពីហេតុការណ៍ផ្សេងៗនៅតាមខេត្តដើម្បីរាយការណ៍ជូនព្រះមហាក្សត្រ ។ នៅពេលមានបទល្មើស អាជ្ញាហ្លួងរាយការណ៍ឲ្យដល់ចៅហ្វាយខេត្ត បន្ទាប់មកអាជ្ញាហ្លួងនេះអាចចូលរួមវិនិច្ឆ័យសេចក្ដីជាមួយតុលាការខេត្តដែលមានចៅហ្វាយខេត្តជាប្រធាន ។ ប៉ុន្តែយោងតាម លោកអាដេម៉ា ឡឺគែរ នៅក្នុងសៀវភៅដែលមានចំណងជើងថា "Droit Public des Cambodgiens" ឬ "ច្បាប់សាធារណៈរបស់ខ្មែរ" បានបញ្ជាក់ថា អាជ្ញាហ្លួង

---

[៦] លោក កុយ នាម និងលោក ឡុង បញ្ញារ៉ុង, សៀវភៅស្ដីពីអយ្យការ ប្រវត្តិ និងការសិក្សាប្រៀបធៀប, បោះពុម្ពឆ្នាំ ២០០៦ (ក្រមទទួលបណ្ដឹងនេះមានពីបុរាណ និងត្រូវបានចម្លងជាសំណេរឡើងវិញនៅឆ្នាំ ១៨៧៤) ។

[៧] លោក កុយ នាម និងលោក ឡុង បញ្ញារ៉ុង, សៀវភៅស្ដីពីអយ្យការ ប្រវត្តិ និងការសិក្សាប្រៀបធៀប, បោះពុម្ពឆ្នាំ ២០០៦ (ក្រមកាត់បណ្ដឹង (ក្រមកាត់បណ្ដឹងជាឧបសម្ព័ន្ធនៃក្រមទទួលបណ្ដឹង) ។

[៨] លោក កុយ នាម និងលោក ឡុង បញ្ញារ៉ុង, សៀវភៅស្ដីពីអយ្យការ ប្រវត្តិ និងការសិក្សាប្រៀបធៀប, បោះពុម្ពឆ្នាំ ២០០៦ ។

[៩] លោក កុយ នាម និងលោក ឡុង បញ្ញារ៉ុង, សៀវភៅស្ដីពីអយ្យការ ប្រវត្តិ និងការសិក្សាប្រៀបធៀប, បោះពុម្ពឆ្នាំ ២០០៦ ។

នេះ "ហាក់ដូចជាមិនមានមុខងារច្បាស់លាស់ជាមន្ត្រីដើមបណ្តឹងសាធារណៈតំណាងឲ្យព្រះមហាក្សត្រដូចដែលយើងយល់ក្នុងសម័យនេះទេ ។ មុខងារសំខាន់របស់អាជ្ញាហ្លួង គឺជាមនុស្សរបស់មហាក្សត្រដើម្បីតាមដានឃ្លាំមើលភក្តីភាពរបស់ចៅហ្វាយខេត្តចំពោះព្រះមហាក្សត្រ ដោយជួនកាលអាជ្ញាហ្លួងត្រូវទៅស្នាក់នៅក្នុង ឬក្បែរផ្ទះចៅហ្វាយខេត្ត ហើយមានរហូតដល់បំពាន និងត្រួតចៅហ្វាយខេត្តទៀតផង ។ ជួនកាលមនុស្សនេះរាយការណ៍មួលបង្កាច់ទៅព្រះមហាក្សត្រ ដើម្បីទម្លាក់ចៅហ្វាយខេត្តដែរ ។ ដូច្នេះមន្ត្រីនេះមិនមានបេសកកម្មពិតប្រាកដដើម្បីបង្ក្រាបបទល្មើសទូទៅទេ" ។

## ២. ការបង្កើតអង្គការអយ្យការនៅប្រទេសកម្ពុជាពីឆ្នាំ ១៩៣៧ ដល់បច្ចុប្បន្ន

### ក. ពីឆ្នាំ ១៩៣៧ ដល់ឆ្នាំ ១៩៧០

អង្គការអយ្យការត្រូវបានបង្កើតដំបូងបង្អស់នៅឆ្នាំ ១៩៣៧ ដោយការបញ្ចូលតំណែងនេះទៅក្នុងក្រមពិភាក្សាព្រហ្មទណ្ឌ (ភាសាសម័យយើងនេះគេហៅថា "ក្រមនីតិវិធីព្រហ្មទណ្ឌ" នៅមុនឆ្នាំ ១៩៣៧ គេហៅថា "ក្រមលក្ខណពិភាក្សាព្រហ្មទណ្ឌ") ។ យោងតាមក្រមនេះ នៅអមសាលាដំបូងនីមួយៗមាន ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ហើយនៅអមសាលាជាន់ខ្ពស់មាន **"ព្រះរាជបំរើ"** និង **"ភូឈួយព្រះរាជបំរើ"** ដោយពេលនោះតំណែងព្រះរាជអាជ្ញាមិនទាន់មាននៅគ្រប់សាលាដំបូងគ្រប់ខេត្តទេ គឺមានតែនៅភ្នំពេញប៉ុណ្ណោះ និងដោយមានការខ្វះខាតថវិកា គេបានជ្រើសយកប្រធានសាលាដំបូងឲ្យដើរតួនាទីពីរជា ព្រះរាជអាជ្ញានៅអមសាលានេះផង និងជាចៅក្រមជំនុំជំរះផង[១០] ។ តួនាទីព្រះរាជអាជ្ញានេះមកជំនួសតួនាទីរបស់ចៅក្រមស៊ើបសួរ ឬ សុភាចារបុរស ដែលដើមឡើយជាអ្នកបង្គស់ំណុំរឿងចោទប្រកាន់ទៅសាលាមជ្ឈិម (ដែលជាផ្នែកនៃសាលាដំបូងសំរាប់វិនិច្ឆ័យរឿងមជ្ឈិមដែលមានទោសពី ០៥ថ្ងៃ ដល់ ០៥ឆ្នាំ) ឬទៅសាលាក្រុមចោទ (ដែលជាសាខាមួយរបស់សាលាឧទ្ធរណ៍ដែលពិនិត្យរឿងឧក្រិដ្ឋ និងរឿងដែលប្តឹងជំទាស់នឹងដីការបស់សុភាចារបុរស) ។

មន្ត្រីអយ្យការនៅអមសាលាដំបូងមានឈ្មោះថា **"ព្រះរាជអាជ្ញា"** ចំណែកនៅអមសាលាឧទ្ធរណ៍ មន្ត្រីនេះមានឈ្មោះថា **"ព្រះរាជបំរើ"** ។ ចំណែកនៅសាលាវិនិច្ឆ័យាធិតី (សមមូលនឹងតុលាការកំពូលយើងសព្វថ្ងៃ) វិញពុំមានព្រះរាជអាជ្ញានៅអមទេ ប៉ុន្តែនៅសម័យក្រោយមកទៀត តំណែងអគ្គព្រះរាជអាជ្ញាអមសាលាវិនិច្ឆ័យត្រូវបានឃើញមាននៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈស្តីពីយុត្តាធិការ ចៅក្រម និងក្រឡាបញ្ជីខាងផ្នែកតុលាការ ចុះថ្ងៃទី៩ ខែមិនា ឆ្នាំ១៩៥៤ ។ តាមច្បាប់លក្ខន្តិកៈនេះ អគ្គព្រះរាជអាជ្ញាអមសាលាវិនិច្ឆ័យគ្មានអំណាចលើសមាជិកនៃក្រសួងអយ្យការទេ[១១] ។

[១០] លោក កុយ នាម និងលោក ឡុង បញ្ញារុធ, សៀវភៅស្តីពីអយ្យការ ប្រវត្តិ និងការសិក្សាប្រៀបធៀប, បោះពុម្ពឆ្នាំ ២០០៦ ។

[១១] លោក កុយ នាម និងលោក ឡុង បញ្ញារុធ,សៀវភៅស្តីពីអយ្យការ ប្រវត្តិ និងការសិក្សាប្រៀបធៀប, បោះពុម្ពឆ្នាំ ២០០៦ (មាត្រា ៩ នៃលក្ខន្តកៈស្តីពីយុត្តាធិការ ចៅក្រម និងក្រឡាបញ្ជីខាងផ្នែកតុលាការ ចុះថ្ងៃទី៩ ខែមិនា ឆ្នាំ១៩៥៤) ។

**ខ. ពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥**

ថ្វីបើប្រទេសខ្មែរបានប្តូររបបពីរាជានិយមមកសាធារណរដ្ឋនិយម នៅក្នុងចន្លោះឆ្នាំ ១៩៧០~១៩៧៥ ក្តី ក៏ប្រព័ន្ធច្បាប់នៅប្រទេសខ្មែរមិនបានផ្លាស់ប្តូរដូចនៅសម័យក្រោយៗទេ ។ របបសាធារណរដ្ឋរបស់សេនាប្រមុខ **លន់ នល់** បន្តនិរន្តរភាពនៃប្រព័ន្ធតុលាការរហូតដល់ពេលត្រូវបានកម្លាំងប្រដាប់អាវុធខ្មែរក្រហមផ្តួលរំលំ និងឡើងកាន់អំណាចបន្តនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ចំនួនរដ្ឋអាជ្ញានៅក្នុងសម័យសាធារណរដ្ឋនេះ ដែលសល់បន្តពីសម័យមុនមកមានចំនួន ៣៨នាក់ ក្នុងនោះមានស្ត្រីម្នាក់ជាភរិយារបស់លោក **អ៊ុង មីង** ដែលមាននាមដើម **យស់ ឡាម្លែល** ។ រដ្ឋអាជ្ញា ០២នាក់ ក្នុងចំណោមចំនួននេះមានតំណែងនៅក្នុងក្រសួងយុត្តិធម៌ ចំណែកឯចៅក្រមវិញមានចំនួន ៩២នាក់ ហើយពុំមានស្ត្រីទេ[១២] ។

**គ. ពីឆ្នាំ ១៩៧៥ មកទល់ឆ្នាំ ១៩៧៩**

ក្នុងអំឡុងពេលឆ្នាំនេះជាសម័យដែលប្រទេសខ្មែរគ្មានប្រព័ន្ធច្បាប់ គ្មានប្រព័ន្ធតុលាការអ្វីទាំងអស់ គឺលើកលែងតែរដ្ឋធម្មនុញ្ញមួយគត់ ដែលអនុម័តដោយសភាខ្មែរក្រហម ។ ប្រទេសខ្មែរក្នុងរយៈពេលនេះគ្មានអត្ថបទច្បាប់អ្វីទាំងអស់ដើម្បីអនុវត្ត ថ្វីបើរបបកម្ពុជាប្រជាធិបតេយ្យមិនបានប្រកាសនិរាករណ៍ច្បាប់ពីសម័យមុនៗក៏ដោយ គឺពួកខ្មែរក្រហមបានបង្កើតរដ្ឋធម្មនុញ្ញមួយយ៉ាងចម្លែក ដែលមិនទទួលស្គាល់សិទ្ធិ និងសេរីភាពបុគ្គលអ្វីទាំងអស់ ។ ចំពោះប្រព័ន្ធតុលាការវិញ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យបានបង្កើតប្រព័ន្ធតុលាការមួយដែលមានឈ្មោះថា **"តុលាការប្រជាជន"**[១៣] ។ គ្មានអ្នកណាម្នាក់យល់ពីសញ្ញាណនៃតុលាការប្រជាជន ក្រៅពីអ្នកតាក់តែងធម្មនុញ្ញនេះទេ ។ ពាក្យ "តុលាការប្រជាជន" នេះត្រូវបានប្រើដោយកម្មភិបាល ឬប្រជាពលរដ្ឋស្លូលរបស់ខ្មែរក្រហម ដែលអាចប្រដូចទៅនឹងប្រព័ន្ធយុត្តិធម៌មួយដែលធ្វើអ្វីតាមទំនើងចិត្ត និងអមនុស្សធម៌ ។ មនុស្សទាំងអស់នេះពន្យល់ថា "ប្រជាជនជាអ្នកកាត់សេចក្តី" តែជាក់ស្តែងគេមិនដែលឃើញមានការរួមប្រជុំប្រជាជនដើម្បីកាត់សេចក្តីអ្នកណាម្នាក់ទេ គឺគេតែងតែសង្កេតឃើញកម្មាភិបាលដូចជា ប្រធានភូមិ ប្រធានក្រុម ប្រជាជនមូលដ្ឋាន(ប្រជាជនដែលបានរស់នៅក្នុងតំបន់ត្រួតត្រាដោយខ្មែរក្រហមក្នុងពេលច្បាំងជាមួយរបបសាធារណរដ្ឋ) ឬឈ្លប ជាអ្នកចោទថាអ្នកនេះធ្វើខុស អ្នកនេះជាអ្នកក្បត់ ។

[១២] លោក កុយ នាម និងលោក ឡុង បញ្ញារុធ, សៀវភៅស្តីពីអយ្យការ ប្រវត្ត និងការសិក្សាប្រៀបធៀប, បោះពុម្ពឆ្នាំ ២០០៦ (ក្រិត្យលេខ ១៩២/៧៣/បសខ ចុះថ្ងៃទី ១ មិនា ១៩៧៣) ។

[១៣] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យមហាសន្និបាតជាតិលើកទី៣ អនុម័តកាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៥, ប្រកាសជាផ្លូវការ នៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦, មាត្រា ៩ ។

តាមរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ បទល្មើសមានតែពីរប្រភេទនោះទេគឺ បទល្មើសប្រឆាំង និងបំផ្លិចបំផ្លាញរដ្ឋដែលត្រូវមានទោសធ្ងន់ ហើយបទល្មើសក្រៅពីនេះត្រូវទទួលតែការអប់រំប៉ុណ្ណោះ[១៤] ។ សរុបសេចក្ដីមក ប្រព័ន្ធចោទប្រកាន់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យស្ថិតនៅលើបុគ្គលម្នាក់ៗជាកម្មាភិបាល (ជាមន្ត្រីរបស់របបនេះ) ជាអ្នកសំរេច ដោយផ្អែកតែលើការសង្ស័យតែម្យ៉ាង ហើយអ្នកចោទនេះជាអ្នកកាត់សេចក្ដីផងដែរ ។

**ឃ. ពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៩២**

អង្គការអយ្យការត្រូវបានបង្កើត ៣ឆ្នាំ ក្រោយពេលដែលកងទ័ពវៀតណាមចូលកាន់កាប់ប្រទេសកម្ពុជា ដែលនេះជារយៈពេលដែលប្រទេសកម្ពុជាស្ថិតនៅក្រោមការគ្រប់គ្រងរបស់វៀតណាម ។ ដូចបានបញ្ជាក់ពីខាងលើ ប្រទេសកម្ពុជាបានបាត់បង់ស្ថាប័នច្បាប់របស់ខ្លួននៅក្រោមរបបខ្មែរក្រហម ហើយធនធានមនុស្សក៏រលាយស្ទើរតែអស់ក្នុងរបបនេះ ។ ក្នុងចំណោមរដ្ឋអាជ្ញាចំនួន ៣៨នាក់ ក្នុងសម័យសាធារណរដ្ឋខ្មែរ ប្រហែលជា ០៣ នាក់ប៉ុណ្ណោះដែលនៅសល់ជីវិតនៅពីក្រោយការរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយក្នុងចំណោមចៅក្រម ៩២នាក់ មានចៅក្រមប្រហែល ០៨នាក់ ដែលនៅសល់ជីវិត ។

ប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជាមិនមាននិរន្តរភាពដូចជានៅប្រទេសផ្សេងៗទៀតទេ ដោយហេតុថា លក្ខណៈ និងអត្តសញ្ញាណនៃប្រព័ន្ធច្បាប់ និងច្បាប់នានានៃប្រទេសនេះផ្លាស់ប្ដូរទៅតាមរបបកាន់កាប់អំណាច ជាពិសេសចាប់តាំងពីរបបកម្ពុជាប្រជាធិបតេយ្យមក ពីព្រោះការផ្ទេរអំណាចពីរបបមួយទៅរបបមួយត្រូវបានធ្វើឡើងដោយសារសង្គ្រាមបដិវត្ត ។

នៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ថ្វីបើមានការកសាងឡើងវិញនូវប្រព័ន្ធច្បាប់មួយដែលបានរលាយរលត់ទៅហើយនោះ ប្រព័ន្ធច្បាប់ថ្មីនេះទទួលឥទ្ធិពលពីកត្តាបីយ៉ាងគឺ **ទស្សនៈនយោបាយនៃរបបថ្មី ស្ថានភាពសន្តិសុខនៃប្រទេស** និង **ការទទួលឥទ្ធិពលវៀតណាមតាមរយៈអ្នកជំនាញការ និងការអប់រំ** ។ ថ្វីបើនៅក្នុងប្រព័ន្ធច្បាប់ថ្មីមាននៅសល់រូបភាពខ្លះៗនៃប្រព័ន្ធច្បាប់ស៊ីវិល ឬប្រព័ន្ធរ៉ូមាណូហ្ស៊េមានិចក្នុងសម័យមុនសង្គ្រាមឆ្នាំ១៩៧០ ក្ដី តែខ្លឹមសារសំខាន់ៗនៃប្រព័ន្ធបច្ចុប្បន្នបានកែប្រែដើម្បីសំរបទៅនឹងទស្សនវិជ្ជានយោបាយសង្គមនិយម ដោយឡែកអង្គតុលាការមិនមានឯករាជ្យភាព ឬស្វ័យភាពរបស់ខ្លួនទេ ទាំងនៅកំរិតការចាត់តាំង ទាំងនៅកំរិតប្រតិបត្តិការ ។ ដូច្នេះ អង្គតុលាការនេះគ្រាន់ជាការបន្តខ្លួន (Extension) ពីអំណាចប្រតិបត្តិប៉ុណ្ណោះ ឬជាអង្គដែលរងការបំពានដោយងាយពីអំណាចដទៃទៀតរបស់រដ្ឋ និងជួនកាលពីបក្សទៀតផង[១៥] ។

---

[១៤] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ មហាសន្និបាតជាតិលើកទី៣ អនុម័តកាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៥, ប្រកាសជាផ្លូវការ នៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧, មាត្រា ១០ ។

[១៥] លោក កុយ នាម និងលោក ឡុង បញ្ញាវុធ, សៀវភៅស្ដីពីអយ្យការ ប្រវត្តិ និងការសិក្សាប្រៀបធៀប, បោះពុម្ពឆ្នាំ ២០០៦ ។

**ខ. ពីឆ្នាំ ១៩៩៣ ដល់បច្ចុប្បន្ន**

ចាប់ពីឆ្នាំ ១៩៩៣ មក តុលាការខ្មែរត្រូវបានរៀបចំ និងកែប្រែទៅតាមគំរូថ្មី ដូចជាការបង្កើតចៅក្រមស៊ើបអង្កេត ការលុបចោលនូវទីប្រឹក្សាប្រជាជនពីក្រុមប្រឹក្សាវិនិច្ឆ័យ ការបង្កើតសាលាឧទ្ធរណ៍ ការអនុម័តនីតិវិធីព្រហ្មទណ្ឌថ្មី ការបង្កើតឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងការបង្កើតក្រុមប្រឹក្សាធម្មនុញ្ញជាដើមដោយអាជ្ញាធរអន្តរកាលនៃអង្គការសហប្រជាជាតិនៅកម្ពុជា ។

បុគ្គលិកតុលាការដែលបំរើការនៅក្នុងសម័យរដ្ឋកម្ពុជាបានបន្តមុខងាររបស់ខ្លួនតទៅទៀតជា ចៅក្រម ព្រះរាជអាជ្ញា និងជាក្រឡាបញ្ជី ។ វគ្គបណ្តុះបណ្តាលចៅក្រម និងព្រះរាជអាជ្ញាលើកទីមួយក៏បានចាប់ផ្តើមចាត់តាំងពីឆ្នាំ ១៩៩៤ មកដោយក្រសួងយុត្តិធម៌ក្រោមការដឹកនាំនៃរដ្ឋមន្ត្រី **ចែម ស្គួន** ។ ក្នុងវគ្គនេះមានសិស្ស ៤២នាក់ដែលត្រូវបានជ្រើសរើសចេញពីការប្រឡងវិញ្ញាសារសរសេរ និងផ្ទាល់មាត់[១៦] ។

## កថាខណ្ឌទី២ គោលការណ៍នៃអង្គការអយ្យការ

នៅក្នុងសង្គមរស់នៅជាក់ស្តែង មានមនុស្សភាគតិចណាស់ដែលបានឮពាក្យ **“អយ្យការ”** ផ្ទុយទៅវិញគេបានឮនូវពាក្យ **“ព្រះរាជអាជ្ញា”** ច្រើនជាង ហើយក៏មានមនុស្សមិនច្រើនប៉ុន្មានដែរ ដែលអាចញែកឲ្យដាច់រវាងព្រះរាជអាជ្ញា និងចៅក្រម ដោយសារនៅក្នុងច្បាប់គេច្រើនប្រើពាក្យ **“ចៅក្រម”** ជាពាក្យទូទៅសម្រាប់ហៅទាំងចៅក្រមកាត់សេចក្តីផង ទាំងព្រះរាជអាជ្ញាដែលជាតួអង្គចោទប្រកាន់នៅក្នុងក្តីព្រហ្មទណ្ឌផង ។ ម្យ៉ាងវិញទៀតអ្នកទាំងពីរចេញពីសាលាតែមួយ ទទួលបានការតែងតាំងក្នុងពេលតែមួយ និងអាចប្តូរមុខងារគ្នាទៅវិញទៅមកបាន ព្រមទាំងមានការិយាល័យនៅក្នុងទីតាំងតែមួយ ដែលជាហេតុនាំឲ្យគេយល់ថា អ្នកទាំងពីរស្ថិតនៅក្នុងស្ថាប័នតែមួយ ប៉ុន្តែអ្វីដែលធ្វើឲ្យចៅក្រមខុសពីព្រះរាជអាជ្ញានោះ គឺការបំពេញមុខងាររបស់គេ ។

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសាលាជំរះក្តីរដ្ឋកម្ពុជា ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ១៩៩៣ និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាអង្គចៅក្រម គឺជាក្របខ័ណ្ឌដែលកំណត់ឲ្យបាននូវរចនាសម្ព័ន្ធរបស់ស្ថាប័នអយ្យការបច្ចុប្បន្ន ។ ថ្វីបើក្នុងពេលបច្ចុប្បន្ននេះ ប្រភពគតិយុត្តទាំងបីខាងលើមិនបានចែងលំអិតអំពីលក្ខន្តិកៈនៃអយ្យការនៅក្នុងការអនុវត្តជាក់ស្តែង គេអាចសន្មត់យកគោលការណ៍ទាំងបីដែលអនុវត្តចំពោះអយ្យការ ហើយគោលការណ៍[១៧]ទាំងនោះគេប្រទះឃើញនៅក្នុងក្រមលេខ ៨៥៧ ន.ស ចុះថ្ងៃទី៩ ខែមិនា ឆ្នាំ១៩៥៤ ទាក់ទងនឹងលក្ខន្តិកៈយុត្តាធិការ ចៅក្រម និងក្រឡាបញ្ជីនៃអង្គតុលាការ គឺ (១). **គោលការណ៍ឯកភាព ឬគោលការណ៍ឋានានុក្រម** (២). **គោលការណ៍អវិភាគ** និង (៣). **គោលការណ៍ឯករាជ្យភាព** ។

---

[១៦] លោក កុយ នាម និងលោក ឡុង បញ្ញាវុធ, សៀវភៅស្តីពីអយ្យការ ប្រវិត្ត និងការសិក្សាប្រៀបធៀប, បោះពុម្ពឆ្នាំ ២០០៦ ។

[១៧] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ៧៥ និងប្រសាសន៍របស់ឯកឧត្តម ផូវ សំភីអគ្គនាយកនៃអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌ នៃក្រសួងយុត្តិធម៌ ។

## ១. គោលការណ៍ឯកភាព ឬគោលការណ៍ឋានានុក្រម

ពាក្យឯកភាព គឺសំដៅទៅលើការរួបរួមគ្នា ឬចូលរួមគ្នាជាអង្គតែមួយមានន័យថា ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងទាំងអស់បង្កើតបានជាតំណាងអយ្យការមួយដែលស្ថិតនៅក្រោមការដឹកនាំតែមួយតាមឋានានុក្រម ។ សមាជិកអង្គការអយ្យការទាំងអស់ធ្វើការតាមលំដាប់ឋានានុក្រម គឺបានសេចក្តីថា ក្នុងដំណើរការនៃរឿងក្តីព្រហ្មទណ្ឌព្រះរាជអាជ្ញារងនៅអមសាលាដំបូងនីមួយៗធ្វើការក្រោមការទទួលខុសត្រូវ និងការណែនាំរបស់ព្រះរាជអាជ្ញា ។ ព្រះរាជអាជ្ញារងត្រូវគោរពអធិបញ្ជារបស់អគ្គព្រះរាជអាជ្ញា ឬរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ ក្នុងករណីនេះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចធ្វើអធិបញ្ជាទៅដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូងចំពោះបណ្តឹង ឬបទល្មើសដែលខ្លួនបានដឹង ព្រមទាំងបង្ហាញនូវសេចក្តីសន្និដ្ឋានដែលខ្លួនយល់ឃើញថាជាការគួរ ប៉ុន្តែមិនអាចធ្វើអធិបញ្ជាឲ្យតម្កល់រឿងទុកឥតចាត់ការបានទេ ។ ព្រះរាជអាជ្ញា គឺផ្ទុយពីចៅក្រមដែលមានឯករាជ្យភាពក្នុងសេចក្តីសំរេចរបស់ខ្លួន ដោយមិនមានកាតព្វកិច្ចតាមផ្លូវច្បាប់នឹងត្រូវទទួលបញ្ជាពីប្រធានតុលាការ ឬចៅក្រមណាផ្សេងទៀត ។

នៅក្នុងប្រព័ន្ធតុលាការខ្មែរបច្ចុប្បន្នសមាជិកទាំងនេះមានងារជា **"ព្រះរាជអាជ្ញា ឬ ចៅក្រមឈរ"** ។ ក្នុងក្រមលក្ខណៈពិភាក្សាព្រហ្មទណ្ឌឆ្នាំ ១៩៣៧ ប្រមុខមហាអយ្យការមានឈ្មោះថាជា **"ព្រះរាជបំរើ"** ហើយអ្នកនៅក្រោមបង្គាប់របស់គាត់ហៅថា **"ភូឈួយព្រះរាជបំរើ"** ។ នៅសម័យក្រោយមក ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៦២ ព្រះរាជបំរើត្រូវបានប្រែក្លាយឈ្មោះទៅជា **"អគ្គព្រះរាជអាជ្ញា"** ហើយភូឈួយព្រះរាជបំរើត្រូវបានប្រែឈ្មោះទៅជា **"អគ្គមេធាវី"**[១៨] ។

នៅក្នុងក្រមលក្ខណៈពិភាក្សាព្រហ្មទណ្ឌឆ្នាំ ១៩៣៧ ស្ថាប័ននេះត្រូវបានហៅថា **"ក្រសួងអយ្យការ"** ក្រោយមកមានការកែប្រែដោយ មហាអយ្យការអមសាលាឧទ្ធរណ៍ និងអយ្យការអមតុលាការខេត្ត-ក្រុងរួមគ្នាបង្កើតបានជាស្ថាប័នមួយហៅថា **"អង្គការអយ្យការ"** ជាឈ្មោះដែលដាក់ដោយរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ក្នុងមាត្រា ១៣១ ។ កាលពីសម័យដើមនៅប្រទេសបារាំង សមាជិកនៃអង្គការនេះឈរលើផ្ទៃក្រាលរបស់តុលាការដើម្បីឡើងនិយាយរឿងក្តីរបស់ខ្លួននៅចំពោះមុខចៅក្រមជំរះក្តីដែលអង្គុយនៅលើផ្ទៃតម្កល់ខ្ពស់ ដោយសារតែពួកសមាជិកនៃអង្គការនោះតែងតែឈរលើផ្ទៃក្រាលដូច្នេះទើបគេហៅពួកគាត់ថាជា **"មន្ត្រីតុលាការឈរ"** ហើយដោយសារតែពួកអ្នកកាត់ក្តីតែងតែអង្គុយ ដូច្នេះទើបគេហៅពួកនោះថាជា **"មន្ត្រីតុលាការអង្គុយ"**[១៩] ។ នៅ

---

[១៨] លោក កុយ នាម និងលោក ឡុង បញ្ញារុធ, សៀវភៅស្តីពីអយ្យការ ប្រវិត្ត និងការសិក្សាប្រៀបធៀប, បោះពុម្ពឆ្នាំ ២០០៦ (មាត្រា ៨ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៦២) ។

[១៩] លោក កុយ នាម និងលោក ឡុង បញ្ញារុធ, សៀវភៅស្តីពីអយ្យការ ប្រវិត្ត និងការសិក្សាប្រៀបធៀប, បោះពុម្ពឆ្នាំ ២០០៦ ។

ប្រទេសខ្មែរយើងសព្វថ្ងៃ សមាជិកអង្គការអយ្យការមិនឈរលើក្តារកម្រាលទេ ពួកគាត់មានអសនៈរបស់គាត់ខ្ពស់ស្មើចៅក្រម តែនៅពេលណាពួកគាត់និយាយគាត់ត្រូវឡើងឈរ ។

**២. គោលការណ៍អវិភាគ**

គោលការណ៍អវិភាគ សំដៅដល់ការបំពេញមុខងាររបស់សមាជិកម្នាក់ៗនៃអង្គការអយ្យការ ដែលចៅក្រមអយ្យការអាចជំនួសគ្នាបានជានិច្ចដើម្បី និងក្នុងផលប្រយោជន៍សមូហភាព ដូច្នេះហើយបានជានៅមុខតុលាការ ព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារងតែងតែប្រើពាក្យ **"តំណាងអយ្យការ"** ព្រោះគេមិនធ្វើការក្នុងនាមខ្លួនផ្ទាល់ទេ តែក្នុងនាមអង្គការរបស់ខ្លួន បានន័យថា *ក្នុងរឿងក្តីមួយចាប់ពីការចាប់ផ្តើមដំបូង ព្រះរាជអាជ្ញាចូលធ្វើការសន្និដ្ឋាន បន្ទាប់មកគាត់អាចឲ្យព្រះរាជអាជ្ញារងផ្លាស់ប្តូរគ្នាបាន ហើយផ្តើមចេញពីគោលការណ៍នេះគឺព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងត្រូវទទួលខុសត្រូវរួមគ្នា* បានសេចក្តីថា *ប្រសិនបើព្រះរាជអាជ្ញារងធ្វើខុស គឺព្រះរាជអាជ្ញាត្រូវតែទទួលខុសត្រូវចំពោះថ្នាក់លើរបស់គាត់*[២០] ។ លើសនេះទៅទៀត ព្រះរាជអាជ្ញាម្នាក់អាចត្រូវបានដក ឬជំនួសដោយព្រះរាជអាជ្ញាម្នាក់ទៀត ទោះបីដំណើរការក្តីមួយកំពុងប្រព្រឹត្តទៅក្តី ។ ឧទាហរណ៍៖ បើព្រះរាជអាជ្ញារងម្នាក់ជាអ្នកផ្តើមចោទ តមកអយ្យការអាចចាត់តាំងឲ្យព្រះរាជអាជ្ញារងណាម្នាក់ទៀតឡើងជជែកក្តីដដែលនោះនៅពេលសវនាការ ឬសូម្បីតែនៅក្នុងសវនាការនៃរឿងដដែលនោះ ម្នាក់ជាអ្នកផ្តើមនីតិវិធី ហើយម្នាក់ទៀតជាអ្នកសន្និដ្ឋានក៏បាន ។

**៣. គោលការណ៍ឯករាជ្យភាព**

ឯករាជ្យភាពនៅចំពោះមុខតុលាការមានន័យថា *ព្រះរាជអាជ្ញានៅអមតុលាការណាមួយមិននៅក្រោមអំណាចរបស់តុលាការនោះទេ* ។ ចៅក្រមអសនៈ ឬប្រធានតុលាការនោះគ្មានអំណាចអ្វីមកត្រួតពិនិត្យកិច្ចការ ឬសកម្មភាពការងារ ធ្វើការស្តីបន្ទោសផ្ទាល់ ឬបង្គាប់បញ្ជាទៅលើការចោទប្រកាន់តាមដែលខ្លួនយល់ឃើញដល់តំណាងអយ្យការបានទេ ។ ការធ្វើដូច្នេះជាការបំពានអំណាច តែក្នុងករណីខ្លះតំណាងអយ្យការធ្វើខុសដែលមើលទៅជាករណីធ្ងន់ធ្ងរ ចៅក្រមអសនៈ ជាពិសេសប្រធានតុលាការអាចរាយការណ៍ទៅកាន់ថ្នាក់លើនៃតំណាងអយ្យការ[២១] ។

**៤. គោលការណ៍ដទៃទៀត**

ព្រះរាជអាជ្ញាត្រូវបានការពារដោយគោលការណ៍ផ្សេងទៀតដែរ ដោយហេតុថា ព្រះរាជអាជ្ញាជាគូបដិបក្ខនៅក្នុងរឿងក្តី តែគេមិនអាចប្តឹងសុំដកព្រះរាជអាជ្ញា ដូចជាការអាចប្តឹងជិតចិត្តលើចៅក្រមទេ ។ ពួកគាត់ការពារផលប្រយោជន៍មួយ ឯចៅក្រមមិនការពារផលប្រយោជន៍ខាងណាមួយឡើយ ។ តែផ្ទុយទៅវិញ ព្រះរាជអាជ្ញាក៏

[២០] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា ៧៥ ។

[២១] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា ៧៥ ។

ដូចជាចៅក្រមដែរ គឺអាចរងបណ្តឹងវិន័យ បើកាលណាគាត់បំពេញភារកិច្ចរបស់គាត់ប្រាសចាកពីក្រមសីលធម៌ ឬត្រូវរងបណ្តឹងអាជ្ញា បើគាត់ប្រព្រឹត្តអំពើពុករលួយជាដើមនៅក្នុងរឿងក្តីនោះ ។ លើសពីនេះទៅទៀតនោះ ព្រះរាជអាជ្ញាក៏មិនទទួលខុសត្រូវចំពោះការដែលខ្លួនធ្វើការចោទប្រកាន់ខុសនោះទេ គ្រាន់តែគាត់អាចរងបណ្តឹងវិន័យដូចដែលបានពោលខាងលើ ប្រសិនជាគាត់ធ្វើកិច្ចការធ្វេសប្រហែសមិនយកចិត្តទុកដាក់តាមស្តង់ដាដែលតម្រូវឲ្យគាត់ប្រកាន់តាមនៅក្នុងក្រមសីលធម៌វិជ្ជាជីវៈរបស់គាត់[២២] ។

## ផ្នែកទី២ ការបែងចែក និងរចនាសម្ព័ន្ធ

ប្រភពជាមូលដ្ឋាននៃសិទ្ធិ និងអំណាចខ្លះៗរបស់ព្រះរាជអាជ្ញាដែលគេស្គាល់នោះមានចែងនៅក្នុងច្បាប់ស្តីពីនីតិវិធីដូចជា ច្បាប់ព្រហ្មទណ្ឌអ៊ុនតាក់ ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា និងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ សម័យរដ្ឋកម្ពុជាជាដើម ។

ដោយឡែក នាថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤ ក្រុមប្រឹក្សាធម្មនុញ្ញ បានប្រកាសថា **"ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម"**[២៣] ស្របនឹងរដ្ឋធម្មនុញ្ញ ហើយត្រូវបានព្រះមហាក្សត្រប្រកាសឲ្យប្រើដោយព្រះរាជក្រម កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ផងដែរ បន្ទាប់ពីបានឆ្លងការប្រជុំជាច្រើនលើកច្រើនសាផងនោះ ជាពិសេសការពិគ្រោះយោបល់ជាមួយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងការផ្តល់យោបល់របស់ក្រសួងស្ថាប័ននានាផងដែរ ។

ច្បាប់គោលទាំងបី គឺជាប្រភេទច្បាប់រៀបចំអង្គការដ៏មានសារសំខាន់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សំដៅពង្រឹងឯករាជ្យនៃអំណាចតុលាការ និងធានាឲ្យអង្គការតុលាការមានកិច្ចដំណើរការប្រព្រឹត្តទៅបានល្អប្រសើរ ក្នុងការលើកកម្ពស់ការបម្រើសេវាយុត្តិធម៌ជូនប្រជាពលរដ្ឋ ស្របតាមគោលការណ៍នៃនីតិរដ្ឋ ។ ទន្ទឹមនឹងនេះ ច្បាប់គោលទាំងបីនេះក៏ជាអាទិភាពដ៏សំខាន់ដើម្បីបង្កើតឲ្យមានអភិក្រមមួយច្បាស់លាស់ និងរឹងមាំនៅក្នុងវិស័យតុលាការ ដើម្បីជួយជំរុញក្នុងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលជាផ្នែកមួយនៃស្នូលយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ០៣ របស់រាជរដ្ឋាភិបាលកម្ពុជា ។

យោងតាមមាត្រា ៥១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ អំណាចគ្រប់គ្រងរដ្ឋត្រូវបានបែងចែកជាបីដាច់ដោយឡែកពីគ្នាគឺ អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។ តុលាការ

---

[២២] លោក កុយ នាម និងលោក ឡុង បញ្ញារ៉ុជ, សៀវភៅស្តីពីអយ្យការ ប្រវិត្ត និងការសិក្សាប្រៀបធៀប, បោះពុម្ពឆ្នាំ ២០០៦ ។

[២៣] ឧបសម្ព័ន្ធទី ១ ។

គឺជាស្ថាប័នឯករាជ្យមួយ ដែលមានអំណាចក្នុងការជំនុំជម្រះគ្រប់រឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ហើយចំពោះការអនុវត្តតាមរយៈសាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជាបែងចែកជាពីរ រួមមានៈ សាលាជម្រះក្តីជាន់ទាប និងសាលាជម្រះក្តីជាន់ខ្ពស់[២៤] ។

## ក.ចំណុចទី១ តុលាការជាន់ទាប

តុលាការជាន់ទាប ត្រូវបានដាក់ឲ្យមាននៅគ្រប់រាជធានី-ខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានហៅថា **"សាលាដំបូងរាជធានី-ខេត្ត"** ។ ជាគោលការណ៍ តុលាការជាន់ទាបត្រូវបែងចែកជាតុលាការជំនាញដូចជា តុលាការព្រហ្មទណ្ឌ តុលាការរដ្ឋប្បវេណី តុលាការការងារ និងតុលាការពាណិជ្ជកម្មជាដើម ។ តុលាការយោធា ជាតុលាការដោយឡែកដែលមានថ្នាក់ស្មើនឹងសាលាដំបូង ដោយតុលាការនេះមានលក្ខណៈពិសេសទទួលដោះស្រាយតែទៅលើរឿងក្តីដែលមានចរិតលក្ខណៈជា ប្រភេទបទល្មើសយោធា ។ តុលាការយោធាមានតែមួយប៉ុណ្ណោះ គឺមានទីតាំងក្នុងរាជធានីភ្នំពេញ និងមានយុត្តាធិការលើគ្រប់សំណុំរឿងបទល្មើសយោធាទូទាំងប្រទេស ។

### ១.១. សាលាដំបូង

សាលាដំបូង គឺជាសាលាជម្រះក្តីថ្នាក់ទី១ ដែលត្រូវបង្កើតឲ្យមានឡើងនៅរាជធានីភ្នំពេញ និងនៅគ្រប់ខេត្តនៃព្រះរាជាណាចក្រកម្ពុជា ។ ការដាក់ឲ្យដំណើរការសាលាដំបូងនានា ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ ។ សាលាដំបូងគឺជាសាលាជម្រះក្តីទូទៅដែលមានសមត្ថកិច្ចក្នុងការស៊ើបសួរ និងជំនុំជម្រះក្តីទាំងអស់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន លើកលែងតែរឿងក្តីដែលស្ថិតនៅក្រោមសមត្ថកិច្ចនៃសាលាជម្រះក្តីពិសេស (ជម្រះលើរឿងក្តីលែងលះគ្នា និងរឿងក្តីអំពីបុត្តភាព) ឬសាលាជម្រះក្តីវិសាមញ្ញ (ជម្រះទៅលើរឿងក្តីដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម) ដែលបង្កើតឡើងដោយច្បាប់ដោយឡែក[២៥] ។ នៅតាមសាលាដំបូងរាជធានី-ខេត្តមានស្ថាប័នមួយនៅអមជាមួយហៅថា **"អយ្យការអមសាលាដំបូង"** ។

ការជំនុំជម្រះរឿងក្តី ឬការសម្រេចសេចក្តីរបស់សាលាដំបូងរាជធានី-ខេត្ត អាចធ្វើឡើងដោយចៅក្រមទោល (ម្នាក់) ឬ ដោយក្រុមប្រឹក្សាជំនុំជម្រះ (ចៅក្រមបីរូប) ដោយមានក្រឡាបញ្ជីជាអ្នកកត់ត្រា ចូលរួមដោយតំណាងអយ្យការ និងមេធាវីតំណាង ឬការពារសិទ្ធិឲ្យភាគី ដោយអនុលោមតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី នីតិវិធីព្រហ្មទណ្ឌ ឬ បទប្បញ្ញត្តិស្តីពីនីតិវិធីផ្សេងៗទៀត ។ ដោយឆ្លងកាត់ការជំនុំជម្រះក្តី សាលាដំបូងត្រូវចេញ

[២៤] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ កក្កដា ២០១៤, មាត្រា ៣ ។

[២៥] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ១០ ។

សេចក្ដីសម្រេចចុងក្រោយរបស់ខ្លួន ដែលត្រូវបានហៅថា «**សាលក្រម**» ។ ភាគីដែលមិនសុខចិត្តនឹងការសម្រេចសេចក្ដីដែលមានក្នុងសាលក្រម អាចប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់[២៦] ។

### ១.១.១. រចនាសម្ព័ន្ធនៃសាលាដំបូង និងអយ្យការអមសាលាដំបូង

#### ក. សមាសភាពសាលាដំបូង

- ប្រធាន
- អនុប្រធាន
- ចៅក្រម
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងៗទៀតដែលបម្រើការងារនៅសាលាដំបូង ។[២៧]

#### ខ. សមាសភាពអយ្យការអមសាលាដំបូង

- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងៗទៀតដែលនៅបម្រើការងារនៅអយ្យការអមសាលាដំបូង ។[២៨]

### ១.១.២. តួនាទី និងភារកិច្ចអយ្យការអមសាលាដំបូង

ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង គឺជាតំណាងអយ្យការអមសាលាដំបូងដែលខ្លួនបំពេញការងារ ។ ព្រះរាជអាជ្ញារងចូលរួមបំពេញមុខងាររបស់អយ្យការក្រោមការដឹកនាំ និងទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង ។ ក្នុងករណីមានធុរៈ ឬមានជម្ងឺ ឬអវត្តមាន ព្រះរាជអាជ្ញាត្រូវរៀបចំចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ដើម្បីជំនួសបាន ដោយឡែកក្នុងករណីដែលព្រះរាជអាជ្ញាស្ថិតក្នុងស្ថានភាពមិនអាចបំពេញការងារបាន ឬក្នុងករណីតំណែងព្រះរាជអាជ្ញាស្ថិតក្នុងស្ថានភាពទំនេរ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ឲ្យធ្វើជាព្រះរាជអាជ្ញាស្ដីទីជំនួសបាន ដើម្បីធានាដំណើរការរបស់អយ្យការអមសាលាដំបូងរហូតដល់មានការតែងតាំងព្រះរាជអាជ្ញាជាផ្លូវការ[២៩] ។ ព្រះរាជអាជ្ញាមានអំណាចលើព្រះរាជអាជ្ញា-រងទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងអាចចាត់តាំង និងបែងចែកការងារដល់ព្រះរាជអាជ្ញារងទាំង

---

[២៦] ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា ១២ ។
[២៧] ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា ១៥ ។
[២៨] ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា ២៥ ។
[២៩] ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា ៣០ ។

អស់ និងមានសិទ្ធិធ្វើអធិបញ្ញាឲ្យព្រះរាជអាជ្ញារងធ្វើការចោទប្រកាន់ ឬក៏ចាត់ឲ្យចោទប្រកាន់ ឬក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមដែលខ្លួនយល់ឃើញថាជាការគួរ[៣០] ។

សេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញារងត្រូវតែបញ្ជូនទៅព្រះរាជអាជ្ញាពិនិត្យនៅមុនពេលសវនាការ។ ប្រសិនបើព្រះរាជអាជ្ញាមិនយល់ព្រមលើសេចក្តីសន្និដ្ឋាននោះទេ ហើយតំណាងអយ្យការដែលជាអ្នកធ្វើសេចក្តីសន្និដ្ឋាននោះនៅតែមិនព្រមធ្វើតាម ព្រះរាជអាជ្ញាអាចចាត់តាំងព្រះរាជអាជ្ញារងផ្សេងទៀត ឬក៏ចាត់ចែងខ្លួនឯងតែម្តងឲ្យធ្វើជាតំណាងអយ្យការនៅក្នុងសវនាការនៃសាលាដំបូង ។ ប៉ុន្តែនៅពេលសវនាការ ព្រះរាជអាជ្ញារងអាចធ្វើការកត់សម្គាល់ដោយផ្ទាល់មាត់បានដោយសេរីតាមការដែលខ្លួនយល់ឃើញស្របតាមសតិសម្បជញ្ញៈរបស់ខ្លួន និងគ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលអាចត្រូវធ្វើចំពោះតំណាងអយ្យការ ដោយសារតែការកត់សម្គាល់ផ្ទាល់មាត់របស់ខ្លួននាពេលសវនាការខុសពីសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរឡើយ ។

### ១.២. តុលាការយោធា

តុលាការយោធា ជាសាលាជម្រះក្តីជាន់ទាបដែលមានថ្នាក់ស្មើនឹងសាលាដំបូង និងមានទីតាំងនៅក្នុងរាជធានីភ្នំពេញតែមួយគត់[៣១] ។ តុលាការយោធា ជាតុលាការដំបូងដែលមានយុត្តាធិការផ្តាច់មុខលើករណីទាំងឡាយប្រព្រឹត្តឡើងដោយកងយោធា ដែលពាក់ព័ន្ធនឹងបទល្មើសយោធា ( ការរំលោភករណីយកិច្ចយោធា ការប្រព្រឹត្តិខុសវិន័យយោធា ។ល។) ឬ បទល្មើសណាមួយដែលប៉ះពាល់ដល់ទ្រព្យសម្បត្តិកងទ័ព ។ បទល្មើសធម្មតាផ្សេងៗទៀតដូចជា មនុស្សឃាត អំពើប្លន់ ។ល ដែលបង្កឡើងដោយកងយោធា គឺត្រូវនៅក្រោមយុត្តាធិការរបស់តុលាការខេត្ត-ក្រុង ។ តុលាការយោធាពុំត្រូវបានអនុញ្ញាតឲ្យពង្រីកយុត្តាធិការរបស់ខ្លួនទៅលើជនស៊ីវិលឡើយ ទោះបីជាជនស៊ីវិលណាម្នាក់ បានបង្កការខូចខាតដល់ កងទ័ពក៏ដោយ[៣២] ។

តុលាការយោធាត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រសួងការពារជាតិខាងផ្នែក រដ្ឋបាល ហិរញ្ញវត្ថុ និងផ្នែកបរិក្ខា ។ អ្នកនាំពាក្យក្រសួងយុត្តិធម៌លោក ជិន ម៉ាលីន ធ្លាប់បានមានប្រសាសន៍ថា *"ការតែងតាំងចៅក្រមតុលាការយោធាមិនដូចនីតិវិធីនៃការតែងតាំងនៅក្នុងតុលាការធម្មតា ឬតុលាការស៊ីវិលនោះទេ ហើយក្រសួងយុត្តិធម៌ក៏មិនមានតួនាទីគ្រប់គ្រង និងត្រួតពិនិត្យលើតុលាការយោធាដែរ៖ «តុលាការយោធា គឺជាផ្នែកមួយរបស់ក្រសួងការពារជាតិ អ៊ីចឹងការតែងតាំង ចៅក្រម និងមន្ត្រីផ្សេងៗទៀត គឺស្ថិតនៅក្នុងក្របខ័ណ្ឌ របស់ក្រសួងការពារជាតិ ដែលត្រូវបានតែងតាំង និងដាក់ឲ្យបំពេញភារកិច្ចដោយក្រសួងការពារជាតិ ។ ក្រសួងយុត្តិធម៌ មិនមានអី ដែលត្រួតពិនិត្យ ឬក៏គ្រប់គ្រងលើតុលាការយោធាទេ»"*[៣៣] ។

[៣០] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា ៣១ ។

[៣១] សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, ឯកសារសម្រាប់ប្រជុំលើកទី១ (ថ្ងៃទី០៩ មករា ២០១៤), មាត្រា ៣៥ ។

[៣២] សៀវភៅស្តីពី ប្រព័ន្ធតុលាការ របស់វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ ។

[៣៣] ប្រសាសន៍របស់អ្នកនាំពាក្យក្រសួងយុត្តិធម៌លោក ជិន ម៉ាលីន កាលពីខែកក្កដា ថ្ងៃទី៧ ឆ្នាំ២០១៩ តាមរយៈអាស៊ីសេរី (RFA) ។

នៅតុលាការយោធា មានស្ថាប័នមួយនៅអមជាមួយហៅថា **"អយ្យការអមតុលាការយោធា"** ដែលស្ថិតនៅក្រោមក្រសួងការពារជាតិដែរ ។

**១.២.១. សមាសភាព**

**ក. សមាសភាពតុលាការយោធា**

- ប្រធាន
- អនុប្រធាន
- ចៅក្រម
- ក្រឡាបញ្ជី ។[៣៤]

**ខ. សមាសភាពអយ្យការអមតុលាការយោធា**

- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង
- ក្រឡាបញ្ជី ។[៣៥]

**១.២.២. តួនាទី និងភារកិច្ចតុលាការយោធា**

តុលាការយោធាមានសមត្ថកិច្ចជំនុំជម្រះលើបទល្មើសយោធា ដែលស្ថាប័ននេះជាអ្នកកំណត់បទល្មើសបែបណាខ្លះដែលមានលក្ខណៈជាយោធាតាមក្រឹតច្បាប់លេខៈ ០៤ របស់អគ្គស្នងការនយោបាយក្រសួងការពារប្រទេសលេខ១២៧១/៨៤ន.ប ភ្នំពេញ ថ្ងៃទី២៨.០៨.១៩៨៤ នៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជាដែលបានកំណត់សញ្ញាណអំពីបទល្មើសមានលក្ខណៈយោធា និងទណ្ឌកម្មក្នុងនោះមានចំនួន ០៩[៣៦] គឺៈ

១. ទោសប្រឆាំងនឹងបទបញ្ជាថ្នាក់លើ

២. បទល្មើសចុះចូលខ្មាំង

៣. ទោសលួចទិញអាវុធ បរិក្ខារសឹក

៤. ទោសគំរាមកំហែងភ្នាក់ងាររដ្ឋការ

៥. ទោសឃោសនាបំផ្លិចបំផ្លាញបំបែកបំបាក់កងទ័ព

៦. ទោសប្រព្រឹត្តអំពើហិង្សា

៧. ទោសធ្វើឲ្យបែកបាក់ការសម្ងាត់យោធា ឬធ្វើ ឲ្យបាត់ឯកសារសម្ងាត់

---

[៣៤] សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, ឯកសារសម្រាប់ប្រជុំលើកទី១ (ថ្ងៃទី០៩ មករា ២០១៤), មាត្រា ៣៦ របស់គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។

[៣៥] សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, ឯកសារសម្រាប់ប្រជុំលើកទី១ (ថ្ងៃទី០៩ មករា ២០១៤), មាត្រា ៣៧ ។

[៣៦] លោកមេធាវី ទៀង វុទ្ធា, អត្ថបទ មូលដ្ឋានចោទប្រកាន់សម្រាប់ព្រះរាជអាជ្ញាក្នុងរឿងក្តីព្រហ្មទណ្ឌ ។

៨. ទោសខ្វះស្មារតីទទួលខុសត្រូវ ឬមិនយកចិត្តទុកដាក់ក្នុងការងារ ដែលបានប្រគល់បណ្ដាលឲ្យមានផលវិបាកអាក្រក់ និងគ្រោះថ្នាក់ធ្ងន់ធ្ងរ

៩. ទោសគេចវេសពី បរិចារកិច្ចយោធា ។

**-ករណីមានវិវាទៈ** ក្នុងករណីមានវិវាទសមត្ថកិច្ចរវាងតុលាការយោធា និងសាលាដំបូង សាលាឧទ្ធរណ៍ភ្នំពេញត្រូវសម្រេចអំពីសមត្ថកិច្ចនេះ តាមបណ្ដឹងសុំរបស់តំណាងអយ្យការ ឬតំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ [៣៧] លើកលែងតែមានច្បាប់ចែងអំពីនីតិវិធីដោយឡែកសម្រាប់អនុវត្តចំពោះបទល្មើសយោធា ។ ការដោះស្រាយទៅលើសំណុំរឿងបទល្មើសយោធាដោយតុលាការយោធា និងអយ្យការអមតុលាការយោធាត្រូវតែអនុលោមតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន[៣៨] ។

**សាលក្រម**របស់តុលាការយោធា បើកសិទ្ធិប្ដឹងឧទ្ធរណ៍ទៅសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ចដែនដីដោយអនុលោមតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន ។ ការប្ដឹងសាទុក្ខនឹងសាលដីការបស់សាលាឧទ្ធរណ៍ទៅតុលាការកំពូល ត្រូវអនុលោមតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីព្រហ្មទណ្ឌ ហើយការរៀបចំ និងការប្រព្រឹត្តទៅរបស់តុលាការយោធាត្រូវកំណត់ដោយច្បាប់ដោយឡែក ។

## កថាខណ្ឌទី២ តុលាការជាន់ខ្ពស់

តុលាការជាន់ខ្ពស់ ត្រូវបានបែងចែកជាពីរគឺ សាលាឧទ្ធរណ៍ និងតុលាការកំពូល ។ សាលាឧទ្ធរណ៍ គឺជាសាលាជម្រះក្ដីថ្នាក់ទី០២ ដែលជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ និងបណ្ដឹងជំទាស់លើសេចក្ដីសម្រេចរបស់តុលាការជាន់ទាប និងមានចំនួន ០៤ តំបន់ ។ តុលាការកំពូល គឺជាសាលាជម្រះក្ដីជាន់ខ្ពស់ និងចុងក្រោយបង្អស់ ហើយសេចក្ដីសម្រេចរបស់តុលាការកំពូល គឺជាសេចក្ដីសម្រេចបិទផ្លូវតវ៉ា ។ តុលាការកំពូលមានតែមួយគត់ និងមានទីតាំងនៅរាជធានីភ្នំពេញ ។

### ២.១. សាលាឧទ្ធរណ៍

សាលាឧទ្ធរណ៍ គឺជាសាលាជម្រះក្ដីថ្នាក់ទី០២ និងមានសមត្ថកិច្ចជំនុំជម្រះរឿងក្ដីដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួនលើកលែងតែរឿងក្ដីទាំងឡាយណាដែលច្បាប់ប្រគល់សមត្ថកិច្ចឲ្យទៅតុលាការផ្សេងៗទៀត[៣៩] ។ សាលាឧទ្ធរណ៍សម្រេចសេចក្ដីទាំងអង្គហេតុ និងអង្គច្បាប់លើរឿងក្ដីដែលស្ថិតនៅក្រោមសមត្ថកិច្ច

[៣៧] សេចក្ដីព្រាងច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ, ឯកសារសម្រាប់ប្រជុំលើកទី១ (ថ្ងៃទី០៩ មករា ២០១៤), មាត្រា ៣៨ របស់គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។

[៣៨] សេចក្ដីព្រាងច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ, ឯកសារសម្រាប់ប្រជុំលើកទី១ (ថ្ងៃទី០៩ មករា ២០១៤), មាត្រា ៣៨ ។

[៣៩] ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ កក្កដា ២០១៤, មាត្រា ៤១ ។

របស់ខ្លួនស្របនឹងច្បាប់ និងបទបញ្ញាត្តិជាធរមាន[៤០] ។ ចំពោះការឆ្លងកាត់នីតិវិធីជំនុំជម្រះ សាលាឧទ្ធរណ៍ត្រូវចេញសេចក្តីសម្រេចចុងក្រោយរបស់ខ្លួន ដែលហៅថា **«សាលដីកា»** ។

សាលាឧទ្ធរណ៍ធ្វើការជំនុំជម្រះត្រូវធ្វើឡើងតាមរយៈសភាជំនាញដែលមានចែកដូចជា សភាស៊ើបសួរ សភាព្រហ្មទណ្ឌ សភារដ្ឋប្បវេណី សភាពាណិជ្ជកម្ម និង សភាការងារជាដើម ។ សភាជំនាញនីមួយៗត្រូវមានប្រធានសភា ចៅក្រមប្រឹក្សា និងក្រឡាបញ្ជីរៀងៗខ្លួន ដោយក្រុមប្រឹក្សាជំនុំជម្រះដែលមានចៅក្រម ០៣(បី)រូប រួមមានប្រធាន ០១(មួយ)រូប និងសមាជិក ០២(ពីរ)រូប និងមានការចូលរួមដោយក្រឡាបញ្ជីជាអ្នកកត់ត្រា ចូលរួមដោយតំណាងមហាអយ្យការ និងមេធាវីតំណាង ឬ ការពារសិទ្ធិឲ្យភាគី ដោយអនុលោមតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី នីតិវិធីព្រហ្មទណ្ឌ ឬបទប្បញ្ញត្តិ ស្តីពីនីតិវិធីផ្សេងទៀត ។ ភាគីដែលមិនពេញចិត្តនឹងសេចក្តីសម្រេចដែលមានក្នុងសាលដីការបស់សាលាឧទ្ធរណ៍ អាចប្តឹងសាទុក្ខទៅតុលាការកំពូលតាមកំណត់ច្បាប់ ។ ដោយឡែក សម្រាប់រឿងក្តីដែលត្រូវបានតុលាការកំពូលសម្រេចបង្វិលមកវិញ នោះសាលាឧទ្ធរណ៍ត្រូវធ្វើការជំនុំជម្រះម្តងទៀត ដោយមានក្រុមប្រឹក្សាជំនុំជម្រះ ជាចៅក្រមចំនួន ០៥(ប្រាំ)រូប ក្នុងនោះមានប្រធាន ០១(មួយ)រូប ហើយចៅក្រមចំនួន ០៤(បួន)រូបទៀត ដែលសុទ្ធតែជាចៅក្រមដែលមិនបានចូលរួមជំនុំជម្រះកាលពីលើកមុន ។

សាលាឧទ្ធរណ៍រួមមាន សាលាឧទ្ធរណ៍ភ្នំពេញ និងសាលាឧទ្ធរណ៍បីតំបន់ផ្សេងទៀតគឺ សាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ សាលាឧទ្ធរណ៍តំបន់បាត់ដំបង និងសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ ។ ការដាក់ឲ្យដំណើរការសាលាឧទ្ធរណ៍តំបន់នីមួយៗ និងការកំណត់ពីសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍តំបន់នេះត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ[៤១] ។

**-យោងតាមព្រះរាជក្រឹត្យៈ**

- សម្រាប់សាលាឧទ្ធរណ៍ភ្នំពេញ គឺស្ថិតនៅរាជធានីភ្នំពេញនឹងត្រូវទទួលដោះស្រាយបណ្តឹងឧទ្ធរណ៍សម្រាប់តែសេចក្តីសម្រេចនានារបស់ សាលាដំបូងរាជធានីភ្នំពេញ និងខេត្តកណ្តាល ឬករណីសំណុំរឿងដែលតុលាការកំពូលបានបង្វិលមកវិញតែប៉ុណ្ណោះ ។
- សម្រាប់សាលាឧទ្ធរណ៍ត្បូងឃ្មុំ ដែលមានទីតាំងស្ថិតក្នុងខេត្តត្បូងឃ្មុំនឹងទទួលដោះស្រាយបណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចនានារបស់ សាលាដំបូងខេត្តកំពង់ចាម ខេត្តកំពង់ធំ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ព្រៃវែង ស្វាយរៀង និងខេត្តត្បូងឃ្មុំ ឬករណីសំណុំរឿងដែលតុលាការកំពូលបានបង្វិលមកវិញ ។

[៤០] វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ, សៀវភៅស្តីពី ប្រព័ន្ធតុលាការ ។
[៤១] ឧបសម្ព័ន្ធទី ២ ។

- សម្រាប់សាលាឧទ្ធរណ៍បាត់ដំបង មានទីតាំងស្ថិតក្នុងខេត្តបាត់ដំបងដែលនឹងទទួលដោះស្រាយបណ្ដឹងឧទ្ធរណ៍ចំពោះសេចក្ដីសម្រេចនានារបស់ សាលាដំបូងខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ ឧត្តរមានជ័យ និង ខេត្តសៀមរាប ឬករណីសំណុំរឿងដែលតុលាការកំពូលបានបង្វិលមកវិញ ។
- ចំណែកសម្រាប់សាលាឧទ្ធរណ៍ព្រះសីហនុ មានទីតាំងក្នុងខេត្តព្រះសីហនុនឹងទទួលដោះស្រាយបណ្ដឹងឧទ្ធរណ៍ចំពោះសេចក្ដីសម្រេចនានារបស់ សាលាដំបូងខេត្តតាកែវ កំពត កំពង់ស្ពឺ កោះកុង និង ខេត្តព្រះសីហនុ ឬករណីសំណុំរឿងដែលតុលាការកំពូលបានបង្វិលមកវិញ ។

នៅអមសាលាឧទ្ធរណ៍ក៏មានស្ថាប័នអយ្យការផងដែរ ហើយត្រូវបានហៅថា “**មហាអយ្យការអមសាលាឧទ្ធរណ៍**” ។

### ២.១.១. សមាសភាព

#### ក. សមាសភាពសាលាឧទ្ធរណ៍

- ប្រធាន
- អនុប្រធាន
- ចៅក្រម
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងៗទៀតដែលបម្រើការងារនៅសាលាឧទ្ធរណ៍។[៤២]

#### ខ. សមាសភាពមហាអយ្យការអមសាលាឧទ្ធរណ៍

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងៗទៀតដែលបម្រើការងារនៅមហាអយ្យការអមសាលាឧទ្ធរណ៍ ។[៤៣]

[៤២] ច្បាប់ស្ដីពី ការរៀបចំអង្គការតុលាការ នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ កក្កដា ២០១៤, មាត្រា ៣៦ ។
[៤៣] ច្បាប់ស្ដីពី ការរៀបចំអង្គការតុលាការ នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ កក្កដា ២០១៤, មាត្រា ៤៩ ។

### ២.១.២. តួនាទី និងភារកិច្ចមហាអយ្យការអមសាលាឧទ្ធរណ៍

មុខងាររបស់មហាអយ្យការអមសាលាឧទ្ធរណ៍ ត្រូវបានប្រគល់ឲ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ចូលរួមអនុវត្តមុខងារនេះក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ ប្រសិនបើក្នុងករណីមានធុរៈ ឬមានជំងឺ ឬអវត្តមាន អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវចាត់តាំង អគ្គព្រះរាជអាជ្ញារងមួយរូប ឬបើគ្មានអគ្គព្រះរាជអាជ្ញារងទេ អាចចាត់តាំងព្រះរាជអាជ្ញាណាម្នាក់ ដើម្បីជំនួសខ្លួនបាន ។ ដោយឡែកប្រសិនបើ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ស្ថិតក្នុងស្ថានភាពមិនអាចបំពេញការងារបាន ឬ ក្នុងករណីតំណែងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ស្ថិតក្នុងស្ថានភាពទំនេរ ក្រសួងយុត្តិធម៌ត្រូវចាត់តាំងអគ្គព្រះរាជអាជ្ញារងណាម្នាក់ឲ្យធ្វើជាអគ្គព្រះរាជអាជ្ញាស្ដីទីជំនួសសិនបាន ដើម្បីធានាដំណើរការរបស់មហាអយ្យការអមសាលាឧទ្ធរណ៍ រហូតដល់មានការតែងតាំងអគ្គព្រះរាជអាជ្ញាជាផ្លូវការ ។[៤៤]

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានអំណាចគ្រប់គ្រងលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ចាត់តាំង និងបែងចែកការងារដល់អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទៅក្នុងក្រុមការងារផ្សេងៗនៃមហាអយ្យការនិងអង្គជំនុំជម្រះ ។ សេចក្ដីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវតែបញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដើម្បីពិនិត្យនៅមុនពេលសវនាការ ។ ប្រសិនបើអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មិនយល់ព្រមលើសេចក្ដីសន្និដ្ឋាននោះទេ ហើយតំណាងមហាអយ្យការដែលជាអ្នកធ្វើសេចក្ដីសន្និដ្ឋាននោះ នៅតែមិនព្រមធ្វើតាម អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចចាត់តាំងអគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាផ្សេងទៀត ឬក៏ចាត់តាំងខ្លួនឯងតែម្ដង ឲ្យធ្វើជាតំណាងមហាអយ្យការនៅក្នុងសវនាការ ។

ប៉ុន្តែនៅពេលសវនាការ អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចធ្វើការកត់សម្គាល់ដោយផ្ទាល់មាត់បានដោយសេរីតាមការដែលខ្លួនយល់ឃើញស្របតាមសតិសម្បជញ្ញៈរបស់ខ្លួន និងគ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលអាចត្រូវធ្វើចំពោះតំណាងមហាអយ្យការ ដោយសារតែការកត់សម្គាល់ផ្ទាល់មាត់របស់ខ្លួននាពេលសវនាការខុសពីសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរឡើយ ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានសិទ្ធិធ្វើអធិបញ្ញាឲ្យព្រះរាជអាជ្ញាអមសាលាដំបូងធ្វើការចោទប្រកាន់បាន ដោយអនុលោមតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន[៤៥] ។

---

[៤៤] ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ កក្កដា ២០១៤, មាត្រា ៥០ ។

[៤៥] ច្បាប់ស្ដីពី ការរៀបចំអង្គការតុលាការ នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា ៥១ ។

## ២.២. តុលាការកំពូល

តុលាការកំពូល គឺជាសាលាជម្រះក្តីជាន់ខ្ពស់ និងចុងក្រោយបង្អស់ និងមានទីតាំងនៅរាជធានីភ្នំពេញ។ សេចក្តីសម្រេចរបស់តុលាការកំពូល គឺជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ។

តុលាការកំពូលមានការបែងចែកជាសភាជំនាញដូចជា សភាព្រហ្មទណ្ឌ សភាពាណិជ្ជកម្ម សភាសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សភាសង្គម និងសភារដ្ឋប្បវេណី ដែលគេហៅជាទូទៅថា **“សភាទីមួយ សភាទីពីរ និងសភាទីបី”** និងមានស្ថាប័នមហាអយ្យការនៅអមដូចសាលាឧទ្ធរណ៍ផងដែរ ។ តុលាការកំពូលមានសមត្ថកិច្ចដោះស្រាយរឿងក្តីដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនស្របតាមការកំណត់របស់ច្បាប់[៤៦] ព្រមទាំងជំនុំជម្រះលើបណ្តឹងសាទុក្ខដែលមានចៅក្រមចំនួន ០៥រូប រួមមាន៖ ប្រធាន ០១រូប និងចៅក្រមប្រឹក្សាចំនួន ០៤រូប ។ តុលាការកំពូលមិនជជែករឿងអង្គហេតុឡើងវិញទេ ហើយក៏មិនបាច់ផ្ទៀងផ្ទាត់ថាអង្គហេតុនោះពិត ឬមិនពិតដែរ ដោយអង្គហេតុត្រូវតែបានសម្រេចដាច់ស្រេចរួចរាល់ហើយនៅឯតុលាការថ្នាក់ក្រោម ដូច្នោះតុលាការកំពូលវែកញែកតែលើការអះអាងខាងអង្គច្បាប់ ដែលអនុវត្តទៅលើអង្គហេតុដែលបានសម្រេចដាច់ស្រេចមកហើយ[៤៧] ។ សវនាការ និងសេចក្តីសម្រេចអាចធ្វើដោយសភានីមួយៗ ឬសភារួម ឬដោយតុលាការពេញអង្គ ដែលនៅក្នុងនោះប្រធានសភាធ្វើជា អធិបតី ។

ក្នុងករណីមានបណ្តឹងសាទុក្ខលើកទីពីរ តុលាការកំពូលធ្វើការជំនុំជម្រះដោយពិនិត្យទាំងអង្គហេតុ និងអង្គច្បាប់ ដោយមានចៅក្រមចំនួន ០៩រូប ក្នុងនោះមានប្រធាន ០១រូប និងចៅក្រមប្រឹក្សា ០៨រូប ដែលការជំនុំជម្រះនេះហៅថា **“សភាពេញអង្គ ឬ ការជំនុំជម្រះរួមក្រុម”** ។ សេចក្តីសម្រេចចុងក្រោយរបស់តុលាការកំពូលហៅថា **“សាលដីកា”** ដែលជាសេចក្តីសម្រេចបិទផ្លូវតវ៉ា និងមានលក្ខណៈស្ថាពរ ។ ទោះបីជាយ៉ាងណាក៏ដោយច្បាប់បានបើកផ្លូវឲ្យមានការប្តឹងជំនុំជម្រះសាជាថ្មី ឬជំនុំជម្រះឡើងវិញចំពោះសេចក្តីសម្រេចស្ថាពរផងដែរ ដោយត្រូវបំពេញតាមលក្ខខណ្ឌដែលមានកំណត់ដោយច្បាប់[៤៨] ។

### ២.២.១. សមាសភាព

#### ក. សមាសភាពតុលាការកំពូល

- ប្រធាន
- អនុប្រធាន
- ចៅក្រម

---

[៤៦] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា ៦១ ។

[៤៧] លោក កុយ នាម, អត្ថបទ សិក្សាប្រៀបធៀបអំពីតុលាការកំពូល ។

[៤៨] លោកមេធាវី សេង ឈុនលី, អត្ថបទពត៌មាន យល់ដឹងផ្នែកច្បាប់ សាលាជម្រះក្តី ។

- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងៗទៀតដែលបម្រើការងារនៅតុលាការកំពូល ។[៤៩]

**ខ. សមាសភាពមហាអយ្យការតុលាការកំពូល**

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងៗទៀតដែលមប្រើការងារនៅមហាអយ្យការអម តុលាការកំពូល ។[៥០]

### ២.២.២. តួនាទី និងភារកិច្ចនៃមហាអយ្យការអមតុលាការកំពូល

មុខងាររបស់មហាអយ្យការអមតុលាការកំពូល ត្រូវបានប្រគល់ឲ្យអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលមានអំណាចគ្រប់គ្រង អំណាចក្នុងការចាត់តាំង/បែងចែក (ទៅក្នុងការងារផ្សេងៗនៃមហាអយ្យការ និងក្នុងអង្គជំនុំជម្រះ) ព្រមទាំងមានការទទួលខុសត្រូវរួមលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល ។ ក្នុងករណីមានធុរៈ ឬមានជំងឺ ឬអវត្តមាន អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលត្រូវចាត់តាំង អគ្គព្រះរាជអាជ្ញារងមួយរូប ឬបើគ្មានអគ្គព្រះរាជអាជ្ញារងទេ អាចចាត់តាំងព្រះរាជអាជ្ញាណាម្នាក់ដើម្បីជំនួសខ្លួនបាន ។ ដោយឡែក ក្នុងករណីដែលអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលស្ថិតក្នុងស្ថានភាពមិនអាចបំពេញការងារបាន ឬក្នុងករណីតំណែងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលស្ថិតក្នុងស្ថានភាពទំនេរ ក្រសួងយុត្តិធម៌ត្រូវចាត់តាំងអគ្គព្រះរាជអាជ្ញារងណាម្នាក់ឲ្យធ្វើជាអគ្គព្រះរាជអាជ្ញាស្ដីទីជំនួសបាន ដើម្បីធានាដំណើរការរបស់មហាអយ្យការអមតុលាការកំពូល រហូតដល់មានការតែងតាំអគ្គព្រះរាជអាជ្ញាជាផ្លូវការ[៥១] ។

ចំពោះសេចក្ដីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមតុលាការកំពូលត្រូវតែបញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលដើម្បីពិនិត្យនៅមុនពេលសវនាការ ។ ប្រសិនបើអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលមិនយល់ព្រមលើសេចក្ដីសន្និដ្ឋាននោះទេ ហើយតំណាងមហាអយ្យការដែលជាអ្នកធ្វើសេចក្ដីសន្និដ្ឋាននោះនៅតែមិនព្រមធ្វើតាម អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អាចចាត់តាំងអគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាផ្សេងទៀត ឬក៏ចាត់តាំងខ្លួនឯងតែម្ដងឲ្យធ្វើជាតំណាងមហាអយ្យការនៅក្នុងសវនាការ ។ ប៉ុន្តែនៅ

[៤៩] ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា ៥៧ ។

[៥០] ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា ៦៨ ។

[៥១] ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា ៦៨ ។

ពេលសវនាការ អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមតុលាការកំពូលអាចធ្វើការកត់សម្គាល់ដោយផ្ទាល់មាត់បានដោយសេរីតាមការដែលខ្លួនយល់ឃើញស្របតាមសតិសម្បជញ្ញៈរបស់ខ្លួន និងគ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលអាចត្រូវធ្វើចំពោះតំណាងមហាអយ្យការ ដោយសារតែការកត់សម្គាល់ផ្ទាល់មាត់របស់ខ្លួននាពេលសវនាការខុសពីសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរឡើយ[៥២] ។

**កថាខណ្ឌទី៣ វិសមិតភាព**

ការបំពេញមុខងារជាចៅក្រម ឬព្រះរាជអាជ្ញា នៅគ្រប់សាលាជម្រះក្តី ឬអង្គការអយ្យការអមសាលាជម្រះក្តីនីមួយៗមានវិសមិតភាពជាមួយការបំពេញ មុខងារសាធារណៈ មុខងារជាតំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា សមាជិករាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការ មុខងារទទួលអាណត្តិដោយការបោះឆ្នោតដទៃទៀត ឬមុខងារជាទីប្រឹក្សាគ្រប់ឋានានុក្រម លើកលែងតែមានបទប្បញ្ញត្តិផ្ទុយពីនេះ ។

ចៅក្រម ឬព្រះរាជអាជ្ញាដែលកំពុងបំពេញមុខងារនៅគ្រប់សាលាជម្រះក្តី ឬអង្គការអយ្យការអមសាលាជម្រះក្តីមិនអាចបំពេញ មុខងារជាមេធាវី មុខរបរពាណិជ្ជកម្ម ឬធ្វើសកម្មភាពណាមួយផ្សេងទៀត ដែលនាំឲ្យមានទំនាស់ផលប្រយោជន៍ ឬដែលប៉ះពាល់ដល់កិត្តិយសនៃអង្គចៅក្រម ប៉ុន្តែចៅក្រម និងព្រះរាជអាជ្ញា អាចបំពេញមុខងារជាគ្រូឧទ្ទេសនាមតាមគ្រឹះស្ថានសិក្សាបាន[៥៣] ។

ចៅក្រម ឬព្រះរាជអាជ្ញាដែលបានអនុញ្ញាតឲ្យនៅទំនេរ ប្រសិនបើមានបំណងប្រកបការងារឯកជនត្រូវជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចជំទាស់មិនឲ្យប្រកបការងារនោះបាន ប្រសិនបើយល់ឃើញថា សកម្មភាពទាំងនោះផ្ទុយនឹងកិត្តិយស ឬសេចក្តីទៀងត្រង់ ឬខូចកិត្យានុភាពនៃមុខងារចៅក្រម ឬព្រះរាជអាជ្ញា[៥៤] ។

ក្នុងករណីដែលមានការអនុវត្តផ្ទុយពីនេះ ចៅក្រម ឬព្រះរាជអាជ្ញាដែលដាក់ឲ្យនៅទំនេរត្រូវទទួលទណ្ឌកម្មខាងវិន័យមាន ០២(ពីរ) ថ្នាក់[៥៥]៖

**១-ទណ្ឌកម្មថ្នាក់ទី ១(មួយ)**

ក- ការស្តីបន្ទោសដោយផ្ទាល់មាត់

ខ- ការស្តីបន្ទោសដោយចុះក្នុងសំណុំលិខិតផ្ទាល់ខ្លួន

[៥២] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា ៧0 ។

[៥៣] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ កក្កដា ២០១៤, មាត្រា ១០៦ ។

[៥៤] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ កក្កដា ២០១៤, មាត្រា ១០៧ ។

[៥៥] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ កក្កដា ២០១៤, មាត្រា ៥៥ ។

គ- ការផ្អាកមិនឲ្យចុះឈ្មោះក្នុងតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិមួយរយៈតែមិនត្រូវឲ្យលើស ពី ២ (ពីរ) ឆ្នាំទេ ឬលុបឈ្មោះចេញពីតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិវិញក្នុងករណីដែលមានចុះឈ្មោះរួចហើយ ។

**២-ទណ្ឌកម្មថ្នាក់ទី ២(ពីរ)**

ក- ការផ្លាស់ដោយបង្ខំ អាចតម្រូវឲ្យទទួលការបណ្តុះបណ្តាលបន្ថែម

ខ- ការព្យួរពីការងារមិនឲ្យមានបៀវត្ស ក្នុងរយៈពេលមិនឲ្យលើសពី ១(មួយ) ឆ្នាំ

គ- ការបន្ថយមួយថ្នាក់ ឬច្រើនថ្នាក់ ឬបន្ថយឋានន្តរស័ក្តិ

ឃ- ការដាក់ឲ្យចូលនិវត្តន៍ដោយបង្ខំ

ង- ការបញ្ឈប់ពីមុខងារដោយបង្ខំ

ច- ការបណ្តេញចេញពីក្របខណ្ឌ ។

ទណ្ឌកម្មថ្នាក់ទី ០២(ពីរ) ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ បន្ទាប់ពីមានការសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

# ជំពូកទី២
# តំណាងអយ្យការ

# ជំពូកទី២
# តំណាងអយ្យការ

## ផ្នែកទី១ សញ្ញាណទូទៅ

ជាទូទៅ អង្គការអយ្យការ គឺមាននៅអមសាលាជម្រះក្តីនីមួយៗគ្រប់ជាន់ថ្នាក់ និងស្ថិតនៅក្នុងបរិវេណតែមួយជាមួយតុលាការ ប៉ុន្តែមានអ្នកដឹកនាំផ្សេងគ្នា ហើយមន្ត្រីដែលបម្រើការក្នុងស្ថាប័នពីរគឺសុទ្ធតែចេញពីសាលាចៅក្រមដូចគ្នាគ្រាន់តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បែងចែកឲ្យបំពេញមុខងារផ្សេងៗគ្នាតែប៉ុណ្ណោះ ។

### កថាខណ្ឌទី១ និយមន័យ

ចៅក្រម ដែលត្រូវតែងតាំងឲ្យទៅបំពេញមុខងារនៅខាងស្ថាប័នតុលាការ ខ្លះជាចៅក្រម ខ្លះជាប្រធានតុលាការ និងខ្លះជាអនុប្រធានតុលាការ ។ ចំណែកចៅក្រមដែលត្រូវតែងតាំងឲ្យទៅបំពេញមុខងារនៅស្ថាប័នអយ្យការ ខ្លះជាព្រះរាជអាជ្ញា និងខ្លះជាព្រះរាជអាជ្ញារង ។

**-នៅអង្គការអយ្យការមានចៅក្រមអយ្យការ ដែលមាន[៥៦]៖**

- ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង អមសាលាដំបូង
- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល ។

នៅក្នុងពេលឡើងជំនុំជម្រះក្តី ឬពេលសវនាការ ដែលមានវត្តមានមន្ត្រីទាំងពីរស្ថាប័នគឺមានដូចជាស្ថាប័នតុលាការ និងស្ថាប័នអយ្យការ ដោយខាងតុលាការគេហៅថា **"ចៅក្រមជំនុំជម្រះ"** រីឯខាងអយ្យការគេហៅថា **"តំណាងអយ្យការ"** មិនមែនហៅថា *"ព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង"* នោះទេ ។

ព្រះរាជអាជ្ញាមានតួនាទីដ៏សំខាន់ក្នុងការគ្រប់គ្រងយុត្តិធម៌ និងវិធានទាំងឡាយដែលទាក់ទងដល់ការបំពេញការទទួលខុសត្រូវដ៏សំខាន់របស់ខ្លួន ដែលជាការរួមចំណែកដល់ការរកយុត្តិធម៌ដ៏ត្រឹមត្រូវ និងរួមចំណែកដល់ការការពារដ៏មានប្រសិទ្ធភាពដល់ប្រជាពលរដ្ឋពីឧក្រិដ្ឋកម្ម ។ នេះជាការចាំបាច់ត្រូវធានាថា ព្រះរាជអាជ្ញាមានលក្ខណៈសម្បត្តិវិជ្ជាជីវៈតាមការទាមទារក្នុងការបំពេញមុខងាររបស់ខ្លួន តាមវិធីដ៏ប្រពៃនៃការជ្រើសរើសនិងការហ្វឹកហ្វឺនផ្នែកច្បាប់ និងវិជ្ជាជីវៈ និងតាមរយៈការផ្តល់នូវគ្រប់មធ្យោបាយចាំបាច់ដើម្បីបំពេញតួនាទីរបស់ខ្លួនឲ្យបានត្រឹមត្រូវដើម្បីប្រយុទ្ធប្រឆាំងនឹងបទឧក្រិដ្ឋ ជាពិសេសវិសាលភាព និងទំរង់ថ្មីៗនៃបទឧក្រិដ្ឋទាំងនោះ ។

---

[៥៦] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ,មាត្រា ៩៥ ។

## កថាខណ្ឌទី២ ការជ្រើសរើស

ក្នុងការជ្រើសរើស និងបណ្តុះបណ្តាលសម្រាប់បំពេញមុខងារជាព្រះរាជអាជ្ញា ត្រូវអនុវត្តរួមគ្នាជាមួយនឹងការបណ្តុះបណ្តាលចៅក្រម[៥៧] ។ យោងតាមគោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា គឺរដ្ឋទាំងឡាយត្រូវធានាថាបុគ្គលដែលត្រូវបានជ្រើសរើស[៥៨]៖

(ក) ត្រូវតែជាបុគ្គលមានសមត្ថភាព សេចក្តីសុចរិត សីលធម៌ ស្អាតស្អំ និងមានគុណសម្បត្តិ ព្រមទាំងមានការបណ្តុះបណ្តាល ។

(ខ) លក្ខណៈជ្រើសរើសព្រះរាជអាជ្ញា ត្រូវមានការការពារមិនឲ្យមានការតែងតាំងទាំងឡាយណាដែលឈរលើភាពលំអៀង ឬ បុរេវិនិច្ឆ័យដោយបំបាត់ចោលនូវការរើសអើងណាមួយចំពោះបុគ្គល ដោយមកពីពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិ នយោបាយ ឬមតិផ្សេងទៀត ដើមកំណើតជាតិ សង្គម ឬ ទ្រព្យសម្បត្តិ ប្រភពកំណើត ឋានៈសេដ្ឋកិច្ច ឬ ឋានៈដទៃទៀត លើកលែងតែការតំរូវឲ្យបេក្ខជនសំរាប់ការិយាល័យអយ្យការនោះត្រូវតែមានសញ្ជាតិនៃប្រទេសសាមីប៉ុណ្ណោះ ដែលមិនត្រូវបានចាត់ទុកថាជាការរើសអើង ។

(គ) ព្រះរាជអាជ្ញាត្រូវមានការអប់រំ និងការបណ្តុះបណ្តាលសមស្រប ហើយត្រូវឲ្យយល់ដឹងអំពីឧត្តមគតិនិងករណីយកិច្ចប្រកបដោយសីលធម៌នៃតួនាទីរបស់ខ្លួន យល់ដឹងអំពីការការពាររដ្ឋធម្មនុញ្ញ និងច្បាប់សំរាប់សិទ្ធិរបស់ជនជាប់សង្ស័យ និងជនរងគ្រោះ ហើយក៏ត្រូវយល់ដឹងអំពីសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តដែលទទួលស្គាល់ដោយច្បាប់ជាតិ និងច្បាប់អន្តរជាតិផង ។

### ២.១. ការជ្រើសរើសនាពេលពីមុន (ពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៩២)

#### ២.១.១. ការជ្រើសរើស និងការតែងតាំងរដ្ឋអាជ្ញា-អគ្គរដ្ឋអាជ្ញា និងការអប់រំ

គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង ជាអ្នកជ្រើសរើសរដ្ឋអាជ្ញាអមតុលាការខេត្ត-ក្រុង រួចស្នើសុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ ក្រោយពីទទួលបានការយល់ព្រមរបស់រដ្ឋមន្ត្រីរួចមក រដ្ឋអាជ្ញានោះនឹងត្រូវបានតែងតាំងដោយក្រុមប្រឹក្សារដ្ឋមន្ត្រី រីឯការតែងតាំងរបស់រដ្ឋអាជ្ញារងវិញមានបែបបទខ្លីជាងរដ្ឋអាជ្ញា គឺតម្រូវឲ្យគណៈកម្មាធិការប្រជាជនខេត្ត-ក្រុងជាអ្នកជ្រើសរើសរួច ហើយស្នើសុំការការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លុះទទួលបានការយល់ព្រម រដ្ឋអាជ្ញារងនោះត្រូវបានតែងតាំងដោយគណៈកម្មការនោះតែម្តង ។

[៥៧] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា ៨២ ។

[៥៨] គោលការណ៍ណែនាំស្តីពី តួនាទីរបស់ព្រះរាជអាជ្ញា, អនុម័តដោយ សមាជអង្គការសហប្រជាជាតិលើកទី៨ ស្តីពីការបង្ការបទឧក្រិដ្ឋ និងការគ្រប់គ្រងជនល្មើស នាទីក្រុងហាវ៉ាណា នៃប្រទេសគុយបា, ចំនុចទី១៣ ។

នៅតុលាការថ្នាក់ខេត្ត-ក្រុងនីមួយៗត្រូវមាន រដ្ឋអាជ្ញាម្នាក់ និងរដ្ឋអាជ្ញារងម្នាក់ ឬពីរនាក់ ។ តុលាការខេត្ត-ក្រុង ជាតុលាការតែមួយថ្នាក់ដែលសំរេចសេចក្តីជាលើកចុងក្រោយ ។ នៅក្នុងសម័យនោះ ពុំទាន់មានតុលាការឧទ្ធរណ៍ទេ ប៉ុន្តែក្រសួងយុត្តិធម៌មានភារកិច្ចទទួល និងពិនិត្យបណ្តឹងឧទ្ធរណ៍នេះ ។ តុលាការប្រជាជនត្រូវបានបង្កើតពិតប្រាកដនៅគ្រប់ខេត្តក្នុងឆ្នាំ ១៩៨៣ លើសពីនេះទៅទៀត ខេត្តធំៗបានតែងតាំងរដ្ឋអាជ្ញា និងរដ្ឋអាជ្ញារង ចំណែកខេត្តតូចៗមានតែរដ្ឋអាជ្ញាម្នាក់ ។

**-ការជ្រើសរើសរដ្ឋអាជ្ញាត្រូវធ្វើតាមនីតិវិធីដូចតទៅ**[៥៩]**៖**

ប្រធានមន្ទីរចាត់តាំងខេត្ត-ក្រុងជាអ្នកពិនិត្យមើលប្រវត្តិរូបមន្ត្រីរដ្ឋការនៅក្នុងក្រុង ឬខេត្ត ដែលមិនជាប់ពាក់ព័ន្ធជ្រៅនឹងនិន្នាការនយោបាយក្នុងរបបមុនៗ និងជាសមាជិកសកម្ម ឬក្រុមស្នូលរបស់បក្សប្រជាជនបដិវត្តកម្ពុជា ។ បន្ទាប់មកប្រធានគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុងបញ្ជូនឈ្មោះអ្នកដែលត្រូវជ្រើសមកក្រសួងយុត្តិធម៌ ។ ប៉ុន្តែបុគ្គលិករដ្ឋខ្លះដែលប្រធានមន្ទីរយល់ឃើញថាមាន ជំហរនយោបាយល្អ តែមិនទាន់ក្លាយទៅជាសមាជិកបក្ស ប្រធានមន្ទីរអាចស្នើសុំឲ្យមានការតែងតាំងរួចបញ្ចូលជាសមាជិកបក្សជាក្រោយដែរ ។ ចំពោះសមត្ថភាពវិញមានការព្យាយាមជ្រើសរើសយកអ្នកមានចំណេះវិជ្ជាខាងច្បាប់ដែរ ប៉ុន្តែដោយសារសម័យនោះអ្នកដែលមានប្រវត្តិអប់រំវិស័យនេះមិនមានការជ្រើសរើស គឺគេត្រូវផ្តោតទៅលើអ្នកដែលមានចំណេះដឹងទូទៅជាពិសេសគ្រូបង្រៀន ។ បន្ទាប់ពីទទួលបានការតែងតាំងមក រដ្ឋអាជ្ញា និងរដ្ឋអាជ្ញារងត្រូវបានបញ្ជូនមកហ្វឹកហ្វឺន ០២(ពីរ)វគ្គ នៅសាលាកម្មាភិបាលរដ្ឋបាល និងនីតិសាស្ត្រ ។ វគ្គហ្វឹកហ្វឺននេះត្រូវបានចាប់ផ្តើមនៅឆ្នាំ ១៩៨៥ ដោយវគ្គទី ០១(មួយ) មានរយៈពេល ០៣(បី)ខែ បង្រៀនដោយសាស្ត្រាចារ្យវៀតណាម រួមទាំងសាស្ត្រាចារ្យអាល្លឺម៉ង់ និងសាស្ត្រាចារ្យខ្មែរខ្លះដូចជា **លោក វ៉ាន់ឌី កាអុន លោក អ៊ុង ផន លោក អ៊ុក សារី លោក ឈួរ លាងហួត និងលោក លឿង ផៃ** ដែលពេលនោះជានាយកសាលានេះជាដើម ដែលអ្នកទាំងបីខាងក្រោយនេះជាអតីតចៅក្រម និងអ្នកច្បាប់តាំងពីសម័យមុនឆ្នាំ១៩៧០ ។ វគ្គទី ០១(មួយ) នេះរៀបចំឡើងសំរាប់រដ្ឋអាជ្ញា និងប្រធានតុលាការ គឺផ្តោតជាបឋមលើការគ្រប់គ្រងរដ្ឋបាល និងនយោបាយ និងជាបន្ទាប់ទៅលើគោលការណ៍ច្បាប់ព្រហ្មទណ្ឌ ច្បាប់រដ្ឋប្បវេណី និងប្រព័ន្ធតុលាការ ។ មេរៀនអំពីគោលការណ៍ច្បាប់ទាំងនេះត្រូវបានបង្រៀនដោយយកគំរូតាមគោលការណ៍នៃប្រទេសរបស់សាស្ត្រាចារ្យទាំងនោះ ។ ឧទាហរណ៍៖ សាស្ត្រាចារ្យវៀតណាមយកគំរូប្រទេសវៀតណាម សាស្ត្រាចារ្យអាល្លឺម៉ង់យកតាមគំរូអាល្លឺម៉ង់ ចំណែកឯសាស្ត្រាចារ្យខ្មែរផ្អែកលើច្បាប់បច្ចុប្បន្នរបស់ខ្មែរ ។ ចំពោះមុខវិជ្ជាខាងគ្រប់គ្រងរដ្ឋបាល និងនយោបាយ គឺផ្តោតលើការគ្រប់គ្រងកិច្ចការរដ្ឋ និងការបង្កើតសាខាបក្សនៅក្នុងក្រសួងមន្ទីរនានា ។ វគ្គទី ០២(ពីរ) គឺបានប្រមូលផ្តុំប្រធានតុលាការ រដ្ឋអាជ្ញា ចៅក្រម

[៥៩] លោក កុយ នាម និងលោកឡុង បញ្ញារុធសៀវភៅស្តីពី អយ្យការ ប្រវិត្ត និងការសិក្សាប្រៀបធៀប, បោះពុម្ពឆ្នាំ ២០០៦ ។

ក្រឡាបញ្ជី ប្រធានគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង ប្រធាននគរបាល និងប្រធានមន្ទីរក្រសួងនៅភ្នំពេញ ក្នុងវគ្គសិក្សារួមគ្នាដែលមានរយៈពេល ០៦(ប្រាំមួយ)ខែ ហើយមុខវិជ្ជាមានដូចក្នុងវគ្គទី ០១(មួយ) ដែរ ប៉ុន្តែផ្ដោតលើវិជ្ជាច្បាប់ និងលើការអនុវត្តច្រើនជាង ។ ឧទាហរណ៍៖ ក្នុងវិជ្ជាច្បាប់ គេផ្ដោតលើបច្ចេកទេសរដ្ឋបាល ការរៀបចំសវនាការ ការសរសេរសាលក្រម និងរបៀបអនុវត្តនីតិវិធីព្រហ្មទណ្ឌជាដើម ។

**២.១.២. ការបង្កើតមហាអយ្យការអមតុលាការកំពូល និងការតែងតាំងអគ្គរដ្ឋអាជ្ញា អគ្គរដ្ឋអាជ្ញារង និងរដ្ឋអាជ្ញា**

នៅឆ្នាំ ១៩៨៥ ច្បាប់ស្ដីពីការបង្កើតតុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការកំពូលត្រូវបានអនុម័តដោយរដ្ឋសភាសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលបានកំណត់មុខងារ និងតួនាទីរបស់ស្ថាប័នទាំងពីរនេះ ។ មហាអយ្យការនៅអមតុលាការកំពូលមាន អគ្គរដ្ឋអាជ្ញាមួយរូប អគ្គរដ្ឋអាជ្ញារងដែលអាចមានលើសពីមួយរូប និងរដ្ឋអាជ្ញាមួយចំនួន ។ រដ្ឋសភាជាអ្នកបោះឆ្នោតជ្រើសតាំងអគ្គរដ្ឋអាជ្ញាសំរាប់អាណត្តិប្រាំឆ្នាំ ហើយអគ្គរដ្ឋអាជ្ញាស្នើទៅក្រុមប្រឹក្សារដ្ឋដើម្បីតែងតាំងអគ្គរដ្ឋអាជ្ញារង និងរដ្ឋអាជ្ញា ដោយឡែកក្នុងករណីបញ្ឈប់អ្នកទាំងនេះទៅវិញ អគ្គរដ្ឋអាជ្ញាក៏ត្រូវធ្វើតាមនីតិវិធីនេះដែរ (ទាំងតុលាការកំពូល ទាំងមហាអយ្យការអមតុលាការកំពូលត្រូវទទួលខុសត្រូវចំពោះមុខរដ្ឋសភា[៦០]) ។

**២.២. ការជ្រើសរើសនាពេលបច្ចុប្បន្ន**

ការជ្រើសរើស និងការបណ្ដុះបណ្ដាលព្រះរាជអាជ្ញា ត្រូវអនុវត្តរួមគ្នាជាមួយការជ្រើសរើស និងការបណ្ដុះបណ្ដាលចៅក្រមផងដែរ ដោយបេក្ខជនត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម[៦១]៖

១. ត្រូវមានសញ្ជាតិខ្មែរពីកំណើត

២. មានអាយុ ៣៥ (សាមសិបប្រាំ)ឆ្នាំ យ៉ាងច្រើនចំពោះមន្ត្រីបេក្ខជនជានិស្សិត និងមានអាយុ៤០ (សែសិប)ឆ្នាំ យ៉ាងច្រើន ចំពោះបេក្ខជនជាមន្ត្រីរាជការ គិតមកដល់ថ្ងៃប្រឡង

៣. ត្រូវមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ

៤. មិនដែលមានទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ

៥. ត្រូវមានកាយសម្បទាគ្រប់គ្រាន់អាចបំពេញការងារបាន ។

[៦០] លោក កុយ នាម និងលោក ឡុង បញ្ញារុធ, សៀវភៅស្ដីពីអយ្យការ ប្រវិត្ត និងការសិក្សាប្រៀបធៀប, បោះពុម្ពឆ្នាំ ២០០៦ ។

[៦១] លោក កុយ នាម និងលោក ឡុង បញ្ញារុធ, សៀវភៅស្ដីពីអយ្យការ ប្រវិត្ត និងការសិក្សាប្រៀបធៀប, បោះពុម្ពឆ្នាំ ២០០៦ ។

# កថាខណ្ឌទី៣ ការតែងតាំង និងការលុបឈ្មោះចេញពីក្របខណ្ឌ

## ៣.១. ការធ្វើកម្មសិក្សា និងការតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា

### ៣.១.១. ការធ្វើកម្មសិក្សា

សិស្សព្រះរាជអាជ្ញាដែលបានបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈដោយជោគជ័យត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ជាព្រះរាជអាជ្ញាកម្មសិក្សាក្នុងឋានន្តរសក្តិជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ (ព្រះរាជក្រឹត្យតែងតាំងព្រះរាជអាជ្ញាកម្មរងសិក្សា ឆ្នាំ២០២២)[៦២] ។ ព្រះរាជអាជ្ញាកម្មសិក្សា ត្រូវធ្វើកម្មសិក្សារយៈពេល ០១(មួយ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការតែងតាំង ហើយការធ្វើកម្មសិក្សារបស់ព្រះរាជអាជ្ញាកម្មសិក្សាត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ ការតែងតាំងព្រះរាជអាជ្ញាកម្មសិក្សាមានអានុភាពដល់ការរៀបចំប្រាក់បៀវត្ស និងការគិតអំពីអតីតភាពការងារ ។ ព្រះរាជអាជ្ញាដែលត្រូវបានបញ្ជូនទៅធ្វើកម្មសិក្សា ដើម្បីឲ្យមានសុក្រឹត្យភាពក្នុងវិជ្ជាជីវៈត្រូវចាត់ទុកដូចជាព្រះរាជអាជ្ញាដែលកំពុងបំពេញមុខងារ ។

### ៣.១.២. ការតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា

សម្រាប់ព្រះរាជអាជ្ញាកម្មសិក្សាដែលបានបំពេញកម្មសិក្សាចប់ដោយជោគជ័យ ត្រូវតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា និងមានឋានន្តរស័ក្តិជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ ។ ឧត្តមក្រុមបឹក្សានៃអង្គចៅក្រមលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញានេះ តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចសម្រេចឲ្យព្រះរាជអាជ្ញាកម្មសិក្សាបន្តធ្វើកម្មសិក្សា ០១(មួយ)ឆ្នាំ បន្ថែមទៀត កាលបើព្រះរាជអាជ្ញាកម្មសិក្សានោះពុំទទួលបានជោគជ័យក្នុងការធ្វើកម្មសិក្សា ឬមានការអាក់ខានមិនបានធ្វើកម្មសិក្សាសរុបទាំងអស់លើសពី ៣០(សាមសិប) ថ្ងៃ[៦៣] ។

## ៣.២. ការលុបឈ្មោះចេញពីក្របខណ្ឌ

ក្នុងករណីដែលព្រះរាជអាជ្ញាកម្មសិក្សាដែលមិនមានសម្បទាគ្រប់គ្រាន់ ឬមានសុខភាពមិនគ្រប់គ្រាន់ដើម្បីបំពេញមុខងាររបស់ខ្លួនតាមលក្ខខណ្ឌដែលច្បាប់បានកំណត់ ឬមានការខុសឆ្គងក្នុងការបម្រើការងារមិនបានពេញលេញ ឬមានការឈប់រហូតលើសពី ៣០(សាមសិប)ថ្ងៃ ដោយគ្មានការអនុញ្ញាតច្បាប់ ឬមិនបានទទួលជោគជ័យជាថ្មីម្តងទៀតក្នុងការធ្វើកម្មសិក្សាបន្ថែម អាចត្រូវលុបឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញាគ្រប់

[៦២] សូមមើលក្នុងឧបសម្ព័ន្ធ ៣ ។

[៦៣] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា ៨៤ ។

ពេលវេលា ក្រោយពីមានការសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[៦៤] ។ ការលុបឈ្មោះចេញ ឬការតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា ត្រូវសម្រេចក្នុងរយៈពេល ០៣(បី)ខែ យ៉ាងយូរក្រោយពីការបញ្ចប់កម្មសិក្សា ។

### ៣.៣. ការដំឡើងថ្នាក់ និងឋានន្តរស័ក្ដ

ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ត្រូវធ្វើឡើងតាមវេនជ្រើសរើស និងតាមវេនអតីតភាពស្របតាមតារាងនៃថ្នាក់ និងឋានន្តរស័ក្តិនីមួយៗ ។ លក្ខខណ្ឌនៃការដំឡើងថ្នាក់ ឬឋានន្តរស័ក្តតាមវេនជ្រើសរើស និងតាមវេនអតីតភាពត្រូវកំណត់ដោយព្រះរាជក្រឹត្យ ( ព្រះរាជក្រឹត្យដំឡើងឋានន្តរស័ក្ត និងថ្នាក់ ឆ្នាំ២០២១)[៦៥] ។

#### ៣.៣.១. ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិរបស់ព្រះរាជអាជ្ញា

- ការគោរពវិន័យការងារបានត្រឹមត្រូវ
- ការសម្រេចភារកិច្ចបានល្អ
- កិរិយាមាយាទ និងសីលធម៌ល្អ មិនធ្វើឲ្យប៉ះពាល់ដល់កិត្តិយសនៃអង្គចៅក្រម
- ការឆ្លងកាត់វគ្គបណ្ដុះបណ្ដាលនានា ឬបានបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា ។[៦៦]

ក្នុងរយៈពេលនៃការបំពេញការងារ ព្រះរាជអាជ្ញាដែលបានខិតខំសិក្សាបន្ថែម ហើយបានទទួលសញ្ញាបត្រក្រោយឧត្តមសិក្សា ត្រូវបានលើកទឹកចិត្តដោយធ្វើការដំឡើងថ្នាក់បន្ថែម ០១(មួយ) ថ្នាក់ទៀត ។ សម្រាប់ថ្នាក់ និងឋានន្តរស័ក្តិនីមួយៗនៃឋានានុក្រម ចំនួនព្រះរាជអាជ្ញាដែលគ្រោងឲ្យឡើងថ្នាក់ ឬឋានន្តរស័ក្តិសម្រាប់ឆ្នាំនីមួយៗនឹងត្រូវកំណត់ទៅតាមតម្រូវការនៃការងារ និងទៅតាមគម្រោងថវិកាជាតិ ។ ព្រះរាជអាជ្ញាក្នុងឋានន្តរស័ក្តិតែមួយអាចឡើងថ្នាក់បានម្ដងមួយថ្នាក់ និងក្នុងករណីចាំបាច់នោះ ព្រះរាជអាជ្ញាអាចប្ដូរឋានន្តរស័ក្តិបានតាមរយៈការប្រឡង ។

ជារៀងរាល់ឆ្នាំនៅសប្ដាហ៍ទី០១ នៃខែមករា ព្រះរាជអាជ្ញាម្នាក់ៗត្រូវទទួលបាននូវព្រឹត្តិបត្រឯកត្តជនដែលព្រះរាជអាជ្ញានោះត្រូវបំពេញតាមចំណុចសំណួរទាំងឡាយ គឺត្រូវដាក់ពិន្ទុដោយមានបញ្ជាក់យោបល់ និងមូលហេតុច្បាស់លាស់ ។

#### ៣.៣.២. ចំពោះការដាក់ពិន្ទុត្រូវអនុវត្តដូចខាងក្រោម

១. ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូង ត្រូវដាក់ពិន្ទុដោយព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង ។

[៦៤] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា ៨៥ ។

[៦៥] សូមមើលក្នុងឧបសម្ព័ន្ធ ៤ ។

[៦៦] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា ២៨ ។

២. ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ ត្រូវដាក់ពិន្ទុដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

៣. ព្រះរាជអាជ្ញាអមសាលាដំបូង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល ត្រូវដាក់ពិន្ទុដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ។

៤. ព្រះរាជអាជ្ញាដែលបានផ្លាស់ឲ្យទៅបំពេញភារកិច្ចនៅស្ថាប័នផ្សេងៗ ត្រូវដាក់ពិន្ទុដោយប្រធានស្ថាប័ននោះ ។[៦៧]

**៣.៣.៣. សមាសភាពនៃគណៈកម្មការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ**

| | |
|---|---|
| ▪ រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ០១រូប | ប្រធាន |
| ▪ អនុប្រធានតុលាការកំពូល ០១រូប | អនុប្រធាន |
| ▪ អគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល ០១រូប | អនុប្រធាន |
| ▪ ប្រធានសាលាឧទ្ធរណ៍ភ្នំពេញ | សមាជិក |
| ▪ អគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ភ្នំពេញ | សមាជិក |
| ▪ ប្រធានសាលាដំបូងរាជធានីភ្នំពេញ | សមាជិក |
| ▪ ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ | សមាជិក |
| ▪ អគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម | លេខាធិការ ។[៦៨] |

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចតែងតាំងសមាសភាពមួយចំនួនទៀតតាមការចាំបាច់ ដើម្បីជាជំនួយឲ្យគណៈកម្មការនេះ ។ តារាងបេក្ខជនដែលបានដាក់ស្នើដំឡើងថ្នាក់សម្រាប់ឋានន្តរស័ក្តនីមួយៗត្រូវរៀបចំតាមលំដាប់អតីតភាពស្របតាមតារាងនៃថ្នាក់នីមួយៗ និងត្រូវបិតផ្សាយឲ្យសាមីខ្លួនដឹងនៅតាមសាលាជម្រះក្តី ។ ព្រះរាជអាជ្ញាណាមួយដែលមានអតីតភាពគ្រប់កំណត់ត្រូវស្នើដំឡើងថ្នាក់ឬឋានន្តរស័ក្តិ ហើយបើគ្មានឈ្មោះនៅក្នុងតារាងខាងលើនេះ ព្រះរាជអាជ្ញានោះអាចប្តឹងតវ៉ាសុំឈ្មោះរបស់ខ្លួនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ យ៉ាងយូរចាប់ពីថ្ងៃទទួលដំណឹងអំពីតារាងស្នើដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ប៉ុន្តែបើផុតរយៈពេលនេះបណ្តឹងតវ៉ាត្រូវទុកជាអសារបង់ ។

ព្រឹត្តិបត្រឯកជនរបស់ព្រះរាជអាជ្ញាដែលត្រូវបានចុះក្នុងបញ្ជីនៃថ្នាក់នីមួយៗ និងព្រឹត្តិបត្រឯកត្តជនរបស់ព្រះរាជអាជ្ញាដែលបានប្តឹងតវ៉ាត្រូវបញ្ជូនទៅគណៈកម្មការដំឡើងថ្នាក់ និងឋានន្តរស័ក្តិឲ្យបានក្នុងសប្តាហ៍ទី ០២

[៦៧] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ២០១៤, មាត្រា ៣១ ។

[៦៨] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា ៣៣ ។

ខែកុម្ភៈ នៃឆ្នាំនីមួយៗ ។ ប្រធានគណៈកម្មការដំឡើងថ្នាក់ និងឋានន្តរស័ក្តជាអ្នកកោះអញ្ជើញគណៈកម្មការខាងលើប្រជុំ និងត្រូវរួមប្រជុំឲ្យបានមុនថ្ងៃចូលឆ្នាំប្រពៃណីខ្មែរ[៦៩] ។

ក្រោយពីបានពិនិត្យព្រឹត្តិបត្រឯកត្តជន និងសម្រេចលើបណ្តឹងតវ៉ា និងក្រោយពីបានស្តាប់សេចក្តីពន្យល់សព្វគ្រប់របស់ប្រធាន សមាជិកម្នាក់ៗត្រូវដាក់ពិន្ទុពី ០(សូន្យ) ដល់២០(ម្ភៃ) ដល់បេក្ខជនម្នាក់ៗ (ការចុះឈ្មោះក្នុងតារាងបេក្ខជន ត្រូវធ្វើតាមលំដាប់គុណសម្បត្តិនៃលទ្ធផលពិន្ទុសរុប) ។ ប្រសិនបើមានបេក្ខជនពីរនាក់មានពិន្ទុស្មើគ្នា នោះបេក្ខជនដែលមានអាយុច្រើនជាងត្រូវចុះឈ្មោះមុនគេក្នុងបញ្ជី[៧០] ។ គណៈកម្មការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ត្រូវរៀបចំតារាងទៅតាមជំនាន់ព្រះរាជអាជ្ញាដែលដំឡើងថ្នាក់ និងឋានន្តរស័ក្តិ និងតាមលំដាប់ថ្នាក់ក្នុងតារាងចុះឈ្មោះ ដើម្បីដាក់ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមពិនិត្យ និងផ្តល់យោបល់ ។ អគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវរៀបចំតារាងឈ្មោះព្រះរាជអាជ្ញាដែលទទួលបានយោបល់យល់ព្រមរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចំពោះការដំឡើងថ្នាក់ និងឋានន្តរស័ក្តិទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រ ។ ព្រះរាជអាជ្ញាណាដែលកំពុងជាប់ក្នុងការអង្កេតជាបទវិន័យ ឬបទល្មើសព្រហ្មទណ្ឌត្រូវផ្អាកមិនទាន់ឲ្យមានសិទ្ធិចុះឈ្មោះក្នុតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិទេ ។

ក្នុងករណីដែលបេក្ខជនមិនត្រូវបានដំឡើងថ្នាក់ ឬឋានន្តរស័ក្ត បេក្ខជននោះមានអទិភាពត្រូវបានចុះឈ្មោះមុនគេក្នុងតារាងដំឡើងថ្នាក់ ឬឋានន្តរស័ក្តិនៅឆ្នាំបន្ទាប់[៧១] ។ ចំពោះព្រះរាជអាជ្ញាណាដែលបានបម្រើការងារក្រោយពីបានតាំងស៊ប់ក្នុងក្របខណ្ឌ ហើយស្ថិតនៅក្នុងឋានន្តរស័ក្តិ ឬថ្នាក់របស់ខ្លួនយ៉ាងតិច ០២(ពីរ)ឆ្នាំគិតមកទល់ថ្ងៃទី១៣ ខែមេសា នៃឆ្នាំនីមួយៗ អាចឲ្យចុះឈ្មោះក្នុងតារាងតំឡើងថ្នាក់បាន ។

### ៣.៤. ការផ្លាច់ពីមុខងារ ការដាក់ឲ្យនៅក្រៅក្របខណ្ឌ ការដាក់ឲ្យនៅទំនេរ និងការលុបឈ្មោះព្រះរាជអាជ្ញា

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រពីការតែងតាំង ការផ្លាស់ប្តូរការផ្តាច់ពីមុខងារ ការដាក់ឲ្យនៅក្រៅក្របខណ្ឌ ការដាក់ឲ្យនៅទំនេរ និងការលុបឈ្មោះព្រះរាជអាជ្ញាទាំងអស់នៃព្រះរាជាណាចក្រកម្ពុជាតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ (ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបានពិគ្រោះយោបល់ជាចាំបាច់ចំពោះសំណើរខាងលើ) ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើកសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រ អំពីកិច្ចការខាងលើនេះ ។

[៦៩] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា ៣៧ ។

[៧០] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា ៣៨ ។

[៧១] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា ៤១ ។

### ៣.៤.១. ការផ្អាក់ពីមុខងារ និងការដាក់ឲ្យនៅក្រៅក្របខណ្ឌ

ព្រះរាជអាជ្ញាអាចត្រូវបានអនុញ្ញាតឲ្យផ្អាក់ពីមុខងារ ឬឲ្យដាក់ក្រៅក្របខណ្ឌព្រះរាជអាជ្ញាបានតាមការស្នើសុំរបស់សាមីខ្លួន ឬរបស់ស្ថាប័នផ្សេងដោយមានការយល់ព្រមពីសាមីខ្លួន ។ ក្នុងករណីចាំបាច់ដែលត្រូវទៅបំពេញការងារជាបណ្តោះអាសន្ននៅក្នុងតំណែងមុខងារសាធារណៈ តំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា សមាជិករាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការ មុខងារទទួលអាណត្តិដោយការបោះឆ្នោតដទៃទៀត ឬតំណែងទីប្រឹក្សាគ្រប់ឋានានុក្រម ព្រះរាជអាជ្ញាអាចសុំផ្អាក់ពីមុខងារ ។ ការអនុញ្ញាតឲ្យផ្អាក់ពីមុខងារនេះ ត្រូវធ្វើឡើងតាមសំណើររបស់សាមីខ្លួន ឬរបស់ស្ថាប័នផ្សេងដោយមានការយល់ព្រមរបស់សាមីខ្លួន ។ ក្នុងរយៈពេលនៃការអនុញ្ញាតឲ្យផ្អាក់ពីមុខងារព្រះរាជអាជ្ញានោះត្រូវបានបន្តទទួលប្រាក់បៀវត្ស ព្រមទាំងសិទ្ធិក្នុងការឡើងថ្នាក់ ឬឋានន្តរស័ក្តិ និងសិទ្ធិក្នុងការចូលនិវត្តន៍របស់ខ្លួន ប៉ុន្តែពុំមានប្រាក់បំណាច់មុខងារនិងប្រាក់រង្វាន់ផ្សេងៗទៀតនៃមុខងារដើមរបស់ខ្លួនទេ[៧២] ។

ក្នុងករណីចាំបាច់ដែលត្រូវទៅបំពេញការងារជាបណ្តោះអាសន្ននៅក្នុងសហគ្រាសសាធារណៈ ឬនៅតាមអង្គការអន្តរជាតិព្រះរាជអាជ្ញាអាចសុំនៅក្រៅក្របខណ្ឌ ។ ការអនុញ្ញាតឲ្យនៅក្រៅក្របខណ្ឌនេះត្រូវធ្វើឡើងតាមសំណើររបស់សាមីខ្លួន ឬរបស់ស្ថាប័នផ្សេងដោយមានការយល់ព្រមរបស់សាមីខ្លួន ។ ព្រះរាជអាជ្ញាដែលត្រូវបានដាក់ឲ្យនៅក្រៅក្របខណ្ឌ ពុំមានសិទ្ធិទទួលប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារ និងប្រាក់បំណាច់ផ្សេងៗទៀតឡើយ[៧៣] ។

### ៣.៤.២. ការដាក់ឲ្យនៅទំនេរ

ក្នុងករណីចាំបាច់ដោយមូលហេតុផ្ទាល់ខ្លួន គ្រួសារ ឬវិសមិតភាព ព្រះរាជអាជ្ញាអាចស្នើសុំនៅទំនេរ គ្មានបៀវត្សសម្រាប់រយៈពេលកំណត់ណាមួយតាមពាក្យសុំរបស់សាមីខ្លួន ។ ការអនុញ្ញាតឲ្យនៅទំនេរគ្មានបៀវត្សអាចធ្វើឡើងសម្រាប់រយៈពេលម្តង ០១(មួយ)ឆ្នាំ ឬម្តង ០២(ពីរ)ឆ្នាំ ។ ការអនុញ្ញាតឲ្យនៅទំនេរនេះ អាចធ្វើបានតែពីរដងគត់ ហើយរយៈពេលសរុបនៃការអនុញ្ញាតនេះ មិនត្រូវឲ្យលើសពី ០៤(បួន)ឆ្នាំឡើយ ។ លក្ខខណ្ឌដែលអាចអនុញ្ញាតឲ្យនៅទំនេរគ្មានបៀវត្សតាមការស្នើសុំរបស់សាមីខ្លួនបាន លុះត្រាតែព្រះរាជអាជ្ញានោះបានបំពេញមុខងារក្នុងក្របខណ្ឌព្រះរាជអាជ្ញាយ៉ាងតិចបាន ០៤(បួន)ឆ្នាំសិន ដោយមិនគិតពីព្រះរាជអាជ្ញាដែលត្រូវទទួលទណ្ឌកម្មជាវិន័យថ្នាក់ទី ០២ (ពីរ) ។ ពាក្យសុំដាក់ឲ្យនៅទំនេរ ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយសាមីខ្លួន និងត្រូវដាក់ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងចាត់ការតាមនីតិវិធី[៧៤] ។ ព្រះរាជអាជ្ញាដែលកំពុងស្ថិតនៅក្នុងភាព

[៧២] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា ៩០ ។

[៧៣] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា ៩១ ។

[៧៤] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ,មាត្រា ៩១ ។

ទំនេរគ្មានបៀវត្សលើកទី ០១(មួយ) បើមានបំណងសុំបន្ត ឬសុំចូលបម្រើការងារវិញ ត្រូវដាក់ពាក្យសុំឲ្យបាន ០២ (ពីរ)ខែ មុនពេលផុតកំណត់នៃរយៈពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ។

### ៣.៤.៣. ការលុបឈ្មោះព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាអាចត្រូវបានផ្អាកពីមុខងារជាបណ្ដោះអាសន្នដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រសិនបើ ព្រះរាជអាជ្ញានោះកំពុងជាប់នៅក្នុងនីតិវិធីវិន័យរបស់ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ព្រះរាជអាជ្ញាអាចត្រូវលុបឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញា ក្នុងករណីដែលព្រះរាជអាជ្ញានោះទទួលទណ្ឌកម្ម ជាវិន័យថ្នាក់ទី ០២(ពីរ) ឬនៅពេលដែលព្រះរាជអាជ្ញានោះបានបោះបង់ការងារ ឬអវត្តមានលើសពី ៣០(សាបសិប)ថ្ងៃ (មាត្រា ៥២ នៃច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា) ឬដោយសាមីខ្លួនសុំលាឈប់ជាស្ថាពរ ។ ចំពោះការលាឈប់របស់ព្រះរាជអាជ្ញាត្រូវធ្វើជាលក្ខណ៍អក្សរដោយសាមីខ្លួន ហើយពាក្យសុំនេះត្រូវដាក់ជូនមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងចាត់ការតាមនីតិវិធី ។

ចំពោះព្រះរាជអាជ្ញាណាដែលពុំបានដាក់ពាក្យសុំបន្តភាពទំនេរគ្មានបៀវត្ស ឬពុំបានចូលបំពេញមុខងាររបស់ខ្លួនវិញយ៉ាងយូរ ៣០(សាមសិប)ថ្ងៃ ចាប់ពីផុតរយៈពេលនៃភាពទំនេរគ្មានបៀវត្សទេនោះ ត្រូវចាត់ទុកថាបានបោះបង់ការងារ ហើយត្រូវលុបឈ្មោះចេញពីក្របខណ្ឌចាប់ពីថ្ងៃនោះតទៅ[៧៥] ។

ក្នុងករណីមានការលុបឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញា ដោយអនុលោមតាមបញ្ញត្តិនៃច្បាប់ដែលបានចែង សាមីខ្លួនមានសិទ្ធិទទួលយកប្រាក់ទាំងអស់ ដែលបេឡាសោធននិវត្តន៍បានកាត់លើប្រាក់បៀវត្សរបស់ខ្លួនរួចមកហើយ តាមច្បាប់ ឬបទបញ្ជានៃបេឡាសោធននិវត្តន៍[៧៦]។

## ផ្នែកទី២ តួនាទី និងភារកិច្ចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាត្រូវមានភារកិច្ចទទួលខុសត្រូវចំពោះកិច្ចការដែលបានប្រគល់ឲ្យ និងគោរពឲ្យបានម៉ឺងម៉ាត់នូវក្រមសីលធម៌របស់ខ្លួន ។ ក្នុងជីវភាពរស់នៅផ្ទាល់ខ្លួន ព្រះរាជអាជ្ញាមិនត្រូវប្រព្រឹត្តិអំពើណាមួយដែលនាំឲ្យអាប់ឱនដល់កិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់ខ្លួន និងដល់កិត្យានុភាពនៃអង្គអយ្យការឡើយ ។ ព្រះរាជអាជ្ញាដែលកំពុងបំពេញមុខងារនៅតាមអយ្យការអមសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់ ត្រូវសុំការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មុននឹងផ្សាយ ឬសុំឲ្យផ្សាយតាមគ្រប់មធ្យោបាយទាំងអស់នូវអត្ថបទ ឬការសរសេរសំណៅព្រមទាំងមតិផ្សេងៗដែលអាចប៉ះពាល់ដល់កិត្យានុភាពនៃស្ថាប័នអយ្យការ ឬស្ថាប័នតុលាការ ( ដោយឡែកបញ្ញាត្តិនេះមិនត្រូវយកទៅអនុវត្តឡើយចំពោះការធ្វើសេចក្ដីថ្លែងការណ៍ជាសាធារណៈរបស់ព្រះរាជអាជ្ញា) ។ ក្នុងវិស័យ

[៧៥] ច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា ៩២ ។

[៧៦] ច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, ជំពូកទី៣ ផ្នែកទី៨ ។

នយោបាយ ព្រះរាជអាជ្ញាត្រូវប្រកាន់ដាច់ខាតនូវឥរិយាបថអព្យាក្រឹត្យ ។ ព្រះរាជអាជ្ញាទាំងអស់មិនត្រូវបោះបង់ការងាររបស់ខ្លួន ឬអវត្តមានដោយគ្មានការអនុញ្ញាតពីថ្នាក់លើផ្ទាល់របស់ខ្លួនជាមុនឡើយ មួយវិញទៀតសំណើរសុំអនុញ្ញាតអវត្តមានរបស់ព្រះរាជអាជ្ញាអមសាលាដំបូង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងអគ្គព្រះរាជ-អាជ្ញាអមតុលាការកំពូល ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌[៧៧] ។

## កថាខណ្ឌទី១ ការអនុវត្តបណ្តឹងអាជ្ញា

### ១.១. បណ្តឹងអាជ្ញា

**«បណ្តឹងអាជ្ញា»** ឬ បណ្តឹងព្រហ្មទណ្ឌ ដែលធ្វើឡើងដោយតំណាងអយ្យការមានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឲ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះតាមកំណត់ច្បាប់ ។ បណ្តឹងអាជ្ញាត្រូវអនុវត្តលើបុគ្គលគ្រប់រូប ទាំងរូបវន្តបុគ្គល ទាំងនីតិបុគ្គល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ[៧៨] ។ យោងតាមមាត្រា ១៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិថា **«មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា»** ដូច្នេះការធ្វើបណ្តឹងអាជ្ញា គឺជាសិទ្ធិផ្តាច់មុខរបស់ស្ថាប័នអយ្យការ ហើយបណ្តឹងអាជ្ញានឹងត្រូវចាប់ផ្តើមដំណើរការដោយការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណាមួយដោយអយ្យការ និងសន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់ ។ ថ្វីត្បិតតែបណ្តឹងអាជ្ញាត្រូវធ្វើឡើងដោយស្ថាប័នអយ្យការដើម្បីធានានូវសណ្តាប់ធ្នាប់សាធារណៈ និងប្រយោជន៍ទូទៅរបស់សង្គម ប៉ុន្តែបុគ្គលដែលទទួលរងគ្រោះដោយផ្ទាល់ ឬភាគីពាក់ព័ន្ធនឹងហេតុការណ៍ដែលត្រូវបានកំណត់ក្នុងបណ្តឹងអាជ្ញានោះ គឺគេមានសិទ្ធិប្តឹងទាមទារសំណងរដ្ឋប្បវេណីដែលត្រូវបានកំណត់ថាជាប្រភេទបណ្តឹងរដ្ឋប្បវេណីក្នុងនីតិវិធីព្រហ្មទណ្ឌ ដែលបណ្តឹងរដ្ឋប្បវេណីនេះមានគោលបំណងឲ្យភាគីរងគ្រោះបានទទួលសំណងជម្ងឺចិត្តធួនល្មមនឹងព្យសនកម្មដែលខ្លួនទទួលរង ។

## កថាខណ្ឌទី២ ការផុតរលត់នៃបណ្តឹងអាជ្ញា

បណ្តឹងអាជ្ញានឹងមានការផុតរលត់ដោយយោងតាមមូលហេតុដូចខាងក្រោម[៧៩]៖

### ២.១. មរណភាពនៃជនល្មើស

កាលណាជនល្មើសបានទទួលមរណៈភាពមុនពេលមានបណ្តឹងអាជ្ញា ឬស្លាប់មុនពេលមានសេចក្តីសម្រេចស្ថាពរផ្តន្ទាទោសដល់ជនល្មើស នោះនឹងនាំឲ្យបណ្តឹងអាជ្ញាដែលកំពុងតែមានលើជននោះត្រូវរលត់

[៧៧] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤, មាត្រា ៩៦ ។

[៧៨] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៣។

[៧៩] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៧។

ហើយដំណើរការទាំងឡាយនៃនីតិវិធីនឹងត្រូវបិទបញ្ចប់ ។ ប៉ុន្តែចំពោះបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះនៅតែអាចបន្តទាមទារសំណងផ្សេងៗទៀតបានជាមួយនឹងសាច់ញាតិរបស់ជនល្មើស ។

## ២.២. ការផុតអាជ្ញាយុកាល

អាជ្ញាយុកាល គឺជាពេលវេលាកំណត់មួយដែលមានចែងក្នុងច្បាប់អំពីរយៈពេលដែលអាចធ្វើ ឬចាប់ផ្តើមបណ្តឹងអាជ្ញាបាន ។ ជាគោលការណ៍ ចិរវេលានៃអាជ្ញាយុកាលត្រូវចាប់ផ្តើមគិតពីពេលដែលប្រព្រឹត្តិនូវបទល្មើស មានន័យថាសកម្មភាពល្មើសមួយត្រូវបានកើតឡើងនាំឲ្យការគិតអំពីអាជ្ញាយុកាលនៃបទល្មើសត្រូវបានចាប់ផ្តើមឡើង ហើយដល់រយៈកំណត់នៅតែមិនមានបណ្តឹងអាជ្ញាណាមួយត្រូវបានធ្វើឡើងពាក់ព័ន្ធនឹងសកម្មភាពនោះទេ នោះនាំឲ្យបណ្តឹងអាជ្ញាត្រូវរលត់ដោយមូលហេតុនៃការផុតអាជ្ញាយុកាល ។

**-អាជ្ញាយុកាលមានរយៈពេលខុសៗតាមប្រភេទនៃបទល្មើស**[៩០]

- សម្រាប់បទល្មើសលហុអាជ្ញាយុកាលមានរយៈពេល ០១(មួយ) ឆ្នាំ
- បទល្មើសមជ្ឈិមមានអាជ្ញាយុកាល ០៥(ប្រាំ) ឆ្នាំ និង
- បទឧក្រិដ្ឋមានអាជ្ញាយុកាល ១៥(ដប់ប្រាំ) ឆ្នាំ ។ ប៉ុន្តែមានបទឧក្រិដ្ឋធ្ងន់ធ្ងរមួយចំនួនច្បាប់មិនមានកំណត់អាជ្ញាយុកាលនោះទេ ដូចជាបទល្មើសប្រល័យពូជសាសន៍ បទល្មើសប្រឆាំងមនុស្សជាតិ និងបទល្មើសឧក្រិដ្ឋកម្មសង្គ្រាមជាដើម ។

នៅក្នុងរឿងរដ្ឋប្បវេណី ដូចជារឿងទទួលខុសត្រូវក្រៅកិច្ចសិន្យា អាជ្ញាយុកាលមានរយៈពេលតែ ០៣(បី) ឆ្នាំប៉ុណ្ណោះ[៩១] រីឯអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុលមានរយៈពេល ០៥(ប្រាំ) ឆ្នាំ ។ ប្រសិនបើអាជ្ញាយុកាលផ្នែករដ្ឋប្បវេណីកំណត់ដោយច្បាប់មានរយៈពេលវែងជាងអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា នោះការផុតអាជ្ញាយុកាលនៃបទល្មើសពុំអាចជាឧបសគ្គរាំងដល់ជនរងគ្រោះក្នុងការប្តឹងផ្តល់ទៅតុលាការរដ្ឋប្បវេណីដើម្បីទាមទារសំណងនៃការខូចខាតឡើយ ។

## ២.៣. ការលើកលែងទោសជាទូទៅ

ការលើកលែងទោសជាទូទៅ ខុសពីការលើកលែងទោសដោយជារាជានុសិទ្ធិរបស់ព្រះមហាក្សត្រដែលមានចែងក្នុងច្បាប់ ដែលជាទូទៅធ្វើឡើងជារៀងរាល់ឆ្នាំក្នុងឱកាសនៃព្រះរាជពិធីបុណ្យជាតិធំៗ ។ បណ្តឹងអាជ្ញាមួយអាចនឹងត្រូវរលត់តាមរយៈការលើកលែងទោសជាទូទៅ ដែលការលើកលែងទោសនេះសំដៅលើការតម្រូវឲ្យមានមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល[៩២] សម្រាប់លើកលែងទោស ឬលុបចោលនូវប្រភេទ

---

[៩០] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, , ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១០ ។

[៩១] ក្រឹត្យច្បាប់លេខ ៣៨ ស្តីពី កិច្ចសន្យា និងការទទួលខុសត្រូវរកកិច្ចសន្យា ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨ ។

[៩២] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣, មាត្រា ៩០ ថ្មី ។

បទល្មើសណាមួយដែលនាំឲ្យបណ្តឹងអាជ្ញាដែលកំពុងដំណើរការក្នុងនីតិវិធីនឹងត្រូវរលត់ ហើយការលុបការផ្តន្ទាទោសចេញពីបញ្ជីថ្កោលទោសក៏ត្រូវបានអនុវត្តផងដែរ ។ ចំពោះជនជាប់ទោសកំពុងតែរងទោសពន្ធនាគារនោះត្រូវដោះលែងភ្លាម ប៉ុន្តែប្រសិនបើជនជាប់ទោសបានបង់ប្រាក់ពិន័យរួចហើយ ជនជាប់ទោសពុំអាចទារសងវិញបានឡើយ[៩៣] ។ តាមមាត្រា ១៥១ នៃក្រមព្រហ្មទណ្ឌ ការលើកលែងទោសជាទូទៅ មិនមែនជាឧបសគ្គសម្រាប់ជនរងគ្រោះក្នុងការទាមទារព្យសនៈកម្មជម្ងឺចិត្តពីជនជាប់ទោសនោះទេ ។

ច្បាប់លើកលែងទោសជាទូទៅកំណត់ច្បាស់លាស់ពីកាលបរិច្ឆេទដែលក្នុងនោះ ការប្រព្រឹត្តបទល្មើសត្រូវលើកលែងពីប្រភេទនៃបទល្មើសដែលត្រូវលើកលែង ឬពីទោសប្រកាសដែលត្រូវលើកលែង ។ ឧទាហរណ៍ៈ ទណ្ឌិតដែលត្រូវផ្តន្ទាទោសដោយតុលាការពី ០៣(បី)ខែ ដល់ ០៣(បី)ឆ្នាំ ត្រូវលើកលែង ឬក៏ពីគុណសម្បត្តិរបស់ចារីបទល្មើសដែលត្រូវលើកលែងទោស (ឧ. ចារីដែលមានអាយុក្រោម ២៥(ម្ភៃប្រាំ)ឆ្នាំ ។ល។ ជាទូទៅក្នុងករណីនេះ ច្បាប់លើកលែងទោសជាទូទៅតម្រូវឲ្យទណ្ឌិតដែលមានអាយុក្រោម ២៥ឆ្នាំ ធ្វើពាក្យស្នើសុំថ្វាយដល់ព្រះមហាក្សត្រក្នុងរយៈពេលណាមួយជាកំណត់ ហើយព្រះរាជក្រឹត្យនឹងធ្វើការលើកលែងទោសបន្ទាប់ពីមានការសិក្សាទៅលើករណីនីមួយៗ ។ ការលើកលែងទោសដែលកំណត់ដោយច្បាប់ក៏អាចមានលក្ខខណ្ឌផងដែរ (ឧ. ត្រូវបង់ប្រាក់ពិន័យឲ្យអស់ជាដើម) ហើយម្យ៉ាងវិញទៀតនោះ ច្បាប់ស្តីពីការលើកលែងទោសជាទូទៅអាចកំណត់ថា បទល្មើសមួយចំនួនមិនទទួលផលប្រយោជន៍ពីការលើកលែងទោសជាទូទៅនេះទេ គឺមានដូចជា បទល្មើសភេរវកម្មជាដើម ។

ច្បាប់ស្តីពីការលើកលែងទោសជាទូទៅមានអានុភាពលុបចោល ដោយប្រតិសកម្មនូវការផ្តន្ទាទោសអំពើល្មើស គឺមានន័យថា អំពើល្មើសដែលទទួលការផ្តន្ទាទោសរួចហើយនឹងត្រូវបាននូវទទួលនូវការលើកលែងទោសវិញ ហើយអំពើនោះនឹងត្រូវបានគេចាត់ទុកថាមិនមែនជាបទល្មើសទៀតឡើយ ។ ដូចនេះការលើកលែងទោសជាទូទៅមានអានុភាពដូចខាងក្រោមៈ

- ចំពោះអំពើល្មើសដែលទទួលបាននូវការលើកលែងទោស ហើយមិនទាន់ត្រូវបានវិនិច្ឆ័យដោយតុលាការនៅឡើយ នោះបណ្តឹងអាជ្ញាត្រូវរលត់ ដូច្នេះចៅក្រមមិនអាចផ្តន្ទាទោសចារីបានឡើយ ។ ប្រសិនបើការលើកលែងទោសធ្វើឡើងដោយអនុលោមទៅតាមអត្រាទោសដែលប្រកាសវិញ ចៅក្រមត្រូវប្រកាសទោសជាមុនសិន ទើបអាចដឹងថាចូលទៅក្នុងអត្រាដែលត្រូវលើកលែងទោសឬអត់ ដោយឡែកប្រសិនបើមានការផ្តន្ទាទោសជាស្ថាពរ ការផ្តន្ទាទោសនោះត្រូវទុកជាឥតបានការ ។

[៩៣] ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា ១៤៩ ។

## ២.៤. និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

បណ្តឹងអាជ្ញាមួយត្រូវបានធ្វើឡើងតាមរយៈនៃការចោទប្រកាន់របស់អយ្យការក្នុងបទល្មើសណាមួយ ប៉ុន្តែដោយហេតុថា បទល្មើសដែលត្រូវបានចោទប្រកាន់នោះត្រូវបាននិរាករណ៍ដោយមានច្បាប់ព្រហ្មទណ្ឌថ្មី ហេតុនេះបណ្តឹងអាជ្ញាដែលធ្វើឡើងដោយឈរលើមូលដ្ឋាននៃបទល្មើសដែលមានចែងក្នុងច្បាប់ចាស់នឹងត្រូវរលត់[៤៤] ។

## ២.៥. អាជ្ញាអស់ជំនុំ

អាជ្ញាអស់ជំនុំ[៤៥]អាចនិយាយបានថាជា *“គោលការណ៍មិនជំនុំជម្រះពីរដងលើរឿងតែមួយ”* មានន័យថា កាលណាបទល្មើសមួយត្រូវបានកើតឡើង ហើយត្រូវបានធ្វើការចោទប្រកាន់ដោយអយ្យការ និងមានការជំនុំជម្រះសេចក្តីរហូតមានសាលក្រម ឬសាលដីកាស្ថាពរ (សម្រេចផ្តន្ទាទោស ឬសម្រេចដោះលែង ឬលើកលែងការចោទប្រកាន់)ហើយនោះ អង្គហេតុនោះមិនត្រូវបានលើកយកមកធ្វើការចោទប្រកាន់ជាថ្មីបានឡើយ ទោះបីជាគេរកឃើញភស្តុតាងដាក់បន្ទុកថ្មីក៏ដោយ ។ មួយវិញទៀត នៅពេលដែលតុលាការបានសម្រេចសេចក្តីដាក់ទោសជនជាប់ចោទ នាំឲ្យជនជាប់ចោទមានកំហុស ហេតុដូចនេះបណ្តឹងរដ្ឋប្បវេណីនឹងទទួលបានជោគជ័យដោយស្វ័យប្រវិត្ត ។ ផ្ទុយទៅវិញ ប្រសិនជាតុលាការបានសម្រេចឲ្យជនជាប់ចោទរួចផុតពីបទចោទប្រកាន់ ជនរងគ្រោះពុំអាចទទួលបាននូវសំណងការខូចខាតពីជនជាប់ចោទ លើកលែងតែក្នុងករណីដែលអំពើរបស់ជនជាប់ចោទពុំមែនជាបទល្មើសព្រហ្មទណ្ឌ តែជាអំពើល្មើសផ្នែករដ្ឋប្បវេណី ។

- ➢ មានមូលហេតុមួយចំនួនទៀតនៃការរលត់បណ្តឹងអាជ្ញាផងដែរ កាលណាមានច្បាប់ដោយឡែកបានចែងដោយជាក់លាក់ ដូចជា[៤៦]៖

- **ការសម្របសម្រួលៈ** ជាគោលការណ៍ ការសម្របសម្រួលមិនអាចធ្វើបានឡើយចំពោះបទល្មើសព្រហ្មទណ្ឌនោះទេ ប៉ុន្តែច្បាប់ពិសេសអាចអនុញ្ញាតឲ្យរំលត់បណ្តឹងអាជ្ញាបានផងដែរ ។

  - ឧទាហរណ៍៖ ពិន័យអន្តរកាណ៍ (ការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក, នីតិវិធីពិន័យអន្តរការណ៍ លើអំពើល្មើសនឹងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់, ពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម) ។

  - ឧទាហរណ៍៖ មាត្រា ២៦ នៃច្បាប់ស្តីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ចែងថា “ចំពោះបទល្មើសដែលជាអំពើហិង្សាប៉ះពាល់ខាងផ្លូវចិត្ត ឬផ្លូវ

---

[៤៤] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៧ ។

[៤៥] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១២ ។

[៤៦] លោក ថន យូសៀង និងកញ្ញា សារី លីសា, អត្ថបទពត៌មាន យល់ដឹងផ្នែកច្បាប់ បណ្តឹងអាជ្ញា ។

ជីវភាពសេដ្ឋកិច្ច និងបទល្មើសមជ្ឈិម ស្រាល ឬបទហុ ការផ្សះផ្សា ឬការសម្របសម្រួលអាចធ្វើទៅបានតាមការយល់ព្រមពីភាគីសងខាង" ។ ការរំលត់បណ្តឹងអាជ្ញាតាមរយៈការសម្របសម្រួលនេះ ពុំមែនជាមូលហេតុនៃការរំលត់បណ្តឹងរដ្ឋប្បវេណីទេ គឺជនរងគ្រោះនៅតែអាចដាក់ពាក្យប្តឹងក្នុងរឿងរដ្ឋប្បវេណីបាន ។

- **ការដកពាក្យបណ្តឹង:** ការដកពាក្យប្តឹងដោយជនរងគ្រោះ ពុំអាចធ្វើឲ្យអាជ្ញាយុកាលនៃបណ្តឹងអាជ្ញារលត់ទេ ប៉ុន្តែចំពោះបទល្មើសមួយចំនួន ការដកបណ្តឹងរបស់អ្នកទទួលរងការខូចខាត នាំឲ្យរលត់បណ្តឹងអាជ្ញាដែរ ។ មាត្រា ៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រង់ចំណុចទី ២ ត្រូវបានចាត់ទុកដូចជាការដកពាក្យបណ្តឹងដោយជនរងគ្រោះដែរ ករណីដែលមានចែងនៅក្នុងមាត្រា ៣៦ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះដែលចែងថា "ការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌពុំអាចធ្វើបានឡើយ បើមានសំណើរពីជនរងគ្រោះជានីតិជន ដោយបទល្មើសនោះជាបទមជ្ឈិម ស្រាល ឬបទលហុ ។ ក្នុងករណីដែលមានអំពើហិង្សាក្នុងគ្រួសារកើតឡើងជាថ្មីម្តងទៀតដែលល្មើសនឹងច្បាប់ព្រហ្មទណ្ឌ តុលាការត្រូវតែធ្វើការចោទប្រកាន់ជនមុខសញ្ញានោះតាមនីតិវិធីព្រហ្មទណ្ឌ ទោះបីជាមានការស្នើសុំពីជនរងគ្រោះម្តងទៀតក៏ដោយ" ។

## កថាខណ្ឌទី៣ សិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា

### ៣.១. អំណាចរបស់ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង

#### ៣.១.១. អំណាចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ប៉ុន្តែកាលណាអនុវត្តដីកាសម្រេចចាត់ឲ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ គឺព្រះរាជអាជ្ញាប្រើប្រាស់អំណាចទាំងអស់ ដែលក្រមនីតិវិធីព្រហ្មទណ្ឌបានទទួលស្គាល់ឲ្យដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត ។

ព្រះរាជអាជ្ញាអាចចុះទៅកាន់កន្លែងស៊ើបអង្កេត និងធ្វើគ្រប់ការណែនាំដែលមានប្រយោជន៍ដល់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ ។ ក្នុងករណីចាំបាច់ពិសេស ព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ និងរៀបចំជំនួសមន្ត្រីរួមទាំងភ្នាក់ងារនេះ ។ លើសពីនេះទៅទៀត ព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលានៅអង្គភាពនគរបាលយុត្តិធម៌ និងអាចចូលរួមក្នុងការស្តាប់ចម្លើយ អាចត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ជាពិសេសគឺការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន[៨៧] ។

[៨៧] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៣៧ ។

### ៣.១.២. អំណាចរបស់ព្រះរាជអាជ្ញារង

ព្រះរាជអាជ្ញារងដែលស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា គឺអាចប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ និងការចោទប្រកាន់បទល្មើស[៤៨] ។

## ៣.២. អំណាចរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ធ្វើការឃ្លាំមើល និងធ្វើការត្រួតពិនិត្យនគរបាលយុត្តិធម៌ និងអាចកោះអញ្ជើញអ្នកទទួលខុសត្រូវនៃអង្គភាពនគរបាលយុត្តិធម៌ ដើម្បីពិភាក្សាអំពីបញ្ហាដែលទាក់ទងនឹងការប្រព្រឹត្តទៅរបស់អង្គភាពនគរបាលទាំងនេះផងដែរ ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចប្រគល់ភារកិច្ចដល់មន្ត្រី ឬភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ឲ្យបំពេញកិច្ចទាំងឡាយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការគ្រប់គ្រង ឬដំណើរការដ៏ល្អនៃនគរបាលយុត្តិធម៌ ហើយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចធ្វើអធិការកិច្ចគ្រប់ពេលវេលានៅអង្គភាពនគរបាលយុត្តិធម៌ផងដែរ និងអាចចូលរួមក្នុងការស្តាប់ចម្លើយ ត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ជាពិសេស គឺការគោរពទម្រង់ការច្បាប់ និងការកាន់កាប់គ្រប់គ្រងកន្លែងឃាត់ខ្លួន[៤៩] ។

សរុបមក ព្រះរាជអាជ្ញាអមសាលាដំបូងមានឋានន្តរស័ក្តិជា វរៈព្រះរាជអាជ្ញា ចំណែកព្រះរាជអាជ្ញារងអមសាលាដំបូងទាំងអស់មានឋានន្តរស័ក្តិជា វរៈព្រះរាជអាជ្ញា ឬអនុព្រះរាជអាជ្ញាឡើងទៅ រីឯអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានឋានន្តរស័ក្តិជា ឧត្តមព្រះរាជអាជ្ញា ។ ចំពោះ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទាំងអស់មានឋានន្តរស័ក្តិជា ឧត្តមព្រះរាជអាជ្ញា ឬវរៈព្រះរាជអាជ្ញា ។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលមានឋានន្តរស័ក្តិជា ឧត្តមព្រះរាជអាជ្ញាថ្នាក់ខ្ពស់បំផុត ហើយអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូលទាំងអស់មានឋានន្តរស័ក្តិជាឧត្តមព្រះរាជអាជ្ញា ។

[៤៨] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៣៨ ។

[៤៩] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៣៥ ។

# ជំពូកទី៣
# ព្រះរាជអាជ្ញាក្នុងដំណើរការនីតិវិធី
# នៃរឿងក្តីព្រហ្មទណ្ឌ

# ជំពូកទី៣

# ព្រះរាជអាជ្ញាក្នុងដំណើរការនីតិវិធី នៃរឿងក្តីព្រហ្មទណ្ឌ

ដំណើរការនៅក្នុងរឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូងចែកចេញជា ០៣ ដំណាក់កាលគឺៈ ដំណាក់កាលស៊ើបអង្កេត ដំណាក់កាលចោទប្រកាន់ និងដំណាក់កាលជំនុំជម្រះ ។

## ផ្នែកទី១ នីតិវិធីស៊ើបអង្កេត

ជាទូទៅនៅពេលដែលមានបទល្មើសមួយកើតឡើង មន្ត្រីនគរបាលយុត្តិធម៌ភាគច្រើនតែងតែទទួលបានដំណឹង ឬព័ត៌មានអំពីហេតុការណ៍នោះពីប្រជាពលរដ្ឋ ឬតាមរយៈការរាយការណ៍ផ្ទាល់ ឬពីបណ្តាញសង្គមនានា ហើយអាជ្ញាធរមានសមត្ថកិច្ចនឹងប្រតិបត្តិការភារកិច្ចរបស់ខ្លួនក្នុងការស្វែងរកការពិត ក៏ដូចជាស្វែងរកជនល្មើសផងដែរ ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការរាយការណ៍ទៅកាន់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ ឬសុំចេញដីកាដើម្បីមានសិទ្ធិគ្រប់គ្រាន់ក្នុងការអនុវត្ត និងត្រឹមត្រូវតាមនីតិវិធីដែលច្បាប់បានកំណត់ជាធរមាន ។ ព្រះរាជអាជ្ញានឹងធ្វើការពិនិត្យត្រិះរិះពិចារណាទៅលើអង្គហេតុ ធាតុផ្សំនៃបទល្មើស និងតម្រុយផ្សេងៗដែលទទួលបានពីការរាយការណ៍ ឬជាបណ្តឹងរបស់ប្រជាពលរដ្ឋដោយផ្ទាល់ និងសម្រេចថា តើត្រូវបើកការស៊ើបអង្កេតដែរ ឬទេ[៤៩] ។

ជាគោលការណ៍ ការស៊ើបអង្កេតត្រូវតែជាការសម្ងាត់ មានន័យថា *នៅគ្រប់ដំណាក់កាលនៃការស៊ើបអង្កេតរបស់ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ត្រូវបានរក្សានូវការសម្ងាត់* ។ នេះជាប្រការដែលមានលក្ខណៈចាំបាច់មួយតម្រូវឲ្យអ្នកចូលរួមក្នុងការស៊ើបអង្កេតនេះ ជាពិសេសព្រះរាជអាជ្ញា មេធាវី ក្រឡាបញ្ជី នគរបាលកងរាជអាវុធហត្ថ មន្ត្រីរាជការជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ចនានាដទៃទៀតត្រូវរក្សាការសម្ងាត់វិជ្ជាជីវៈ ក៏ដូចជាត្រូវអនុវត្តឲ្យបានត្រឹមត្រូវ និងហ្មត់ចត់បំផុតដោយត្រូវចៀសវៀងឲ្យបានអំពីការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ននានាដែលជាហេតុបណ្តាលឲ្យបែកធ្លាយការសម្ងាត់ ព័ត៌មាននៃការស៊ើបអង្កេតដែលជាបណ្តាលឲ្យមានផលប៉ះពាល់ដល់ការស៊ើបអង្កេត[៥០] ។

ជាទូទៅ ការស៊ើបអង្កេតត្រូវបានបែងចែកជាពីរគឺ ការស៊ើបអង្កេតករណីជាក់ស្តែង និងការស៊ើបអង្កេតបឋម ។

### កថាខណ្ឌទី១ ការស៊ើបអង្កេតជាក់ស្តែង

**-បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង[៥១]**

[៤៩] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ,មាត្រា ៨៩ ។

[៥០] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៨៣ ។

[៥១] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៨៦ ។

- បទល្មើសដែលកំពុងប្រព្រឹត្ត
- បទល្មើសដែលទើបនឹងប្រព្រឹត្តរួច
- កាលណានៅក្រោយពេលមានបទល្មើសបន្តិច
- ជនដែលគេសង្ស័យត្រូវបានសាធារណៈជនស្រែកដេញប្រដាប់ចាប់ប្រដឹង
- បុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយសង្វាក់ផ្សេងទៀត ដែលនាំឲ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្តបទល្មើស ឬបានចូលរួមប្រព្រឹត្តបទល្មើស ។

ម៉្យាងទៀតដែលត្រូវបានចាត់ទុកថាដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែរ កាលណាមានបទល្មើស ឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែលប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះ ស្នើសុំឲ្យព្រះរាជអាជ្ញា ឬ មន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ចូលមកពិនិត្យ[៩២] ។ ក្នុងករណីមានបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមទៅព្រះរាជអាជ្ញាអំពីបទល្មើសដែលបានកើត ឡើង ហើយខណៈដែលទៅដល់ទីកន្លែងកើតហេតុភ្លាម មន្ត្រីនគរបាលយុត្តិធម៌នឹងធ្វើការត្រួតពិនិត្យបទល្មើស និងមានភារកិច្ចធានារ៉ាប់រងរក្សាតម្រុយនៃភស្តុតាងទាំងឡាយ ដែលអាចបាត់បង់ដោយប្រការណាមួយផ្សេងៗ បណ្តាលមកពីកត្តាមនុស្ស ឬកត្តាធម្មជាតិដូចជាទឹក ភ្លៀង ខ្យល់ជាដើម[៩៣] ។ មន្ត្រីនគរបាលយុត្តិធម៌អាចចាប់ យកវត្ថុតាង ព្រមទាំងអាចមានសិទ្ធិធ្វើការហាមឃាត់នូវបុគ្គលគ្រប់រូបដែលសង្ស័យថាបានចូលរួមក្នុងបទល្មើស កុំឲ្យទៅណាឆ្ងាយពីកន្លែងដែលមានបទល្មើស និងនាំមកកាន់អង្គភាពរបស់ខ្លួន ដើម្បីជាជំនួយដល់ការស៊ើប អង្កេត និងប្រមូលភស្តុតាង[៩៤] ។ ទន្ទឹមនឹងនេះ មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់ រូបដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុបាន ហើយក្នុងការស្តាប់ចម្លើយនីមួយៗទៀតសោត គឺត្រូវធ្វើកំណត់ហេតុ ដែលត្រូវចុះហត្ថលេខា ឬស្នាមផ្តិតមេដៃដោយបុគ្គលដែលបានឆ្លើយ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ អាចរកអ្នកបកប្រែភាសាដែលស្បថថានិយាយការពិត ។ ករណី រឹងទទឹងមិនចូលខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវ ជូនដំណឹងដល់ព្រះរាជអាជ្ញាដែលអាចចេញបញ្ជាឲ្យចូលខ្លួនបាន ហើយមន្ត្រីនគរបាលយុត្តិធម៌អាចប្រើកម្លាំង សាធារណៈបង្ខំឲ្យជននោះចូលខ្លួន[៩៥] និងព្រមទាំងអាចពឹងដល់បុគ្គលគ្រប់រូបដែលមានមុខជំនាញដើម្បីធ្វើការ ពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រដែលមិនអាចបង្អង់បាន ។

---

[៩២] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៨៨ ។
[៩៣] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៨៩ ។
[៩៤] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៩២ ។
[៩៥] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៩៤ ។

ចំពោះថិរវេលានៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង មិនអាចលើសពី ០៧(ប្រាំពីរ)ថ្ងៃ គិតពីថ្ងៃប្រព្រឹត្តបទល្មើស ។ កិច្ចស៊ើបអង្កេតត្រូវប្រព្រឹត្តទៅជាប់ជានិច្ចនៅក្នុងថេរវេលានេះ ប្រសិនបើបើកការស៊ើបអង្កេតមិនបាន ក្នុងរយៈពេល ០៧(ប្រាំពីរ) ថ្ងៃនេះទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្នើសុំយោបល់ពីព្រះរាជអាជ្ញា[៩៦] និងត្រូវធ្វើឡើងបន្តបន្ទាប់ក្នុងរយៈពេល ០៧(ប្រាំពីរ)ថ្ងៃ បើពុំនោះទេនាំឲ្យមានមោឃភាពនៃនីតិវិធី ។ ក្រោយពីបញ្ចប់ការស៊ើបអង្កេត បើសិនជាបុគ្គលណាមួយត្រូវបញ្ជូនទៅព្រះរាជអាជ្ញា នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការបញ្ជូនកំណត់ហេតុ និងវត្ថុតាងទៅជាមួយការបញ្ជូនខ្លួនបុគ្គលនោះដែរ ។

**១.១. ការឆែកឆេរ**

ក្នុងករណីបទល្មើសជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាននៅគ្រប់ទីកន្លែងរបស់បុគ្គលដែលខ្លួនសង្ស័យថាជាជនសង្ស័យបាន និងកំពុងធ្វើការលាក់ខ្លួន ឬទីកន្លែងដែលខ្លួនកំពុងអាចនឹងធ្វើការស្វែងរក តែត្រូវទទួលការអនុញ្ញាតជាបឋមពីព្រះរាជអាជ្ញា ទោះបីការអនុញ្ញាតនោះដោយផ្ទាល់មាត់ក៏ដោយ និងត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកណាកាន់កាប់ទីកន្លែងនោះទេ ត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់ដែលត្រូវចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌ ។ សាក្សីមិនអាចជានគរបាលយុត្តិធម៌ ឬមួយក៏ជាកងរាជអាវុធហត្ថដែលជាកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ[៩៧] ។ ការឆែកឆេរមិនអាចធ្វើទៅបាននៅមុនម៉ោង ៦ព្រឹក និងនៅក្រោយម៉ោង ១៨ល្ងាច លើកលែងតែបទល្មើសជាក់ស្តែងមានចែងក្នុងមាត្រា ៨៦ និងមាត្រា ៨៨ និងក្នុងករណីផ្សេងទៀតដែលមានចែងក្នុងមាត្រា ៩១ ដូចជា៖

- ក្នុងករណី មានសម្រែកស្រែកឲ្យជួយក្នុងកន្លែង
- ក្នុងករណី ឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោងដែលបើកចំហរដល់សាធារណៈជន
- ក្នុងករណី ឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិតរក្សា ជួញដូរ ចែកចាយ ប្រើប្រាស់គ្រឿងញៀន ។

**រាល់ប្រតិបត្តិការឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែធ្វើកំណត់ហេតុស្តីពីការឆែកឆេរ ដែលនៅក្នុងនោះមាន៖**

- ការអនុញ្ញាតរបស់ព្រះរាជអាជ្ញា ដោយប្រាប់ថ្ងៃ និងម៉ោងនៃការអនុញ្ញាតនោះ
- អត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ ។

មានតែព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរតែប៉ុណ្ណោះដែលអាចធ្វើការឆែកឆេរនេះបាននៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវី ឬមេធាវីសាម៉ី រីឯមន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើការឆែកឆេរនៅក្នុងការិយាល័យមេធាវីនោះទេ ។ ចំពោះការឆែកឆេរនៅក្នុងអគារសារព័ត៌មាន សហគ្រាសនៃសារព័ត៌មានសរសេរ ឬសហគ្រាសសារព័ត៌មានទៀតសោត មន្ត្រីនគរបាលយុត្តិធម៌អាចប្រព្រឹត្តទៅបានតែចំពោះមុខ

[៩៦] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ,មាត្រា ១០៦ ។

[៩៧] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៩១ ។

ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរម្នាក់ ដែលធានារ៉ាប់រងកុំឲ្យការឆែកឆេរនេះប៉ះពាល់ដល់ការប្រកបដោយសេរីនូវមុខរបរអ្នកសារព័ត៌មាន និងធ្វើឲ្យយឺតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាននេះដោយមិនត្រឹមត្រូវ ។

### ១.២. ការឃាត់ខ្លួន

នៅពេលមានករណីបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងកើតឡើង គ្រប់បុគ្គលទាំងអស់អាចមានសិទ្ធិចាប់ខ្លួនជនល្មើសបាន ហើយបន្ទាប់ពីនេះគឺត្រូវនាំខ្លួនបុគ្គលនោះប្រគល់ជូនទៅកាន់មន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតខ្លួនបំផុត ។ មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនជនសង្ស័យ ហើយទន្ទឹមនឹងនេះដែរមន្ត្រីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួនជនដែលអាចផ្តល់ព័ត៌មានអំពីរឿងហេតុ (តែជននោះប្រកែកមិនព្រមផ្តល់ព័ត៌មាន) ដោយមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីព្រះរាជអាជ្ញា ។

ការឃាត់ខ្លួនក្នុងករណីស៊ើបអង្កេតជាក់ស្តែង ក៏ដូចក្នុងករណីស៊ើបអង្កេតបឋមនៅពេលដែលមានតម្រុយអំពីបទល្មើសព្រហ្មទណ្ឌច្បាស់លាស់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជូនទៅព្រះរាជអាជ្ញាភ្លាមមានន័យថា *ប្រសិនជាក្រោយពីការស៊ើបអង្កេត ពិនិត្យឃើញថាពិតជាមានបទល្មើសព្រហ្មទណ្ឌ ហើយមានមូលហេតុចាំបាច់តម្រូវឲ្យឃាត់ខ្លួនខានមិនបាន មន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំឃាត់ខ្លួនជនសង្ស័យទៅកាន់ព្រះរាជអាជ្ញា ព្រមទាំងត្រូវបញ្ជូនគ្រប់ភស្តុតាងដែលតម្រូវឲ្យមានការឃាត់ខ្លួននេះ* ។ រយៈពេលនៃឃាត់ខ្លួនសម្រាប់នីតិជន ការឃាត់ខ្លួនមិនអាចលើសពី ៤៨ម៉ោង គិតចាប់ពីម៉ោងដែលសាម៉ីខ្លួនមកដល់អង្គភាព ។ ចំពោះបទល្មើសឧក្រិដ្ឋ មន្ត្រីនគរបាលយុត្តិធម៌អាចពន្យារពេលឃាត់ខ្លួនបាន ដើម្បីការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ មានពេលវេលាគ្រប់គ្រាន់សម្រាប់ការធ្វើប្រតិបត្តិការ តែត្រូវសុំទៅព្រះរាជអាជ្ញា ហើយការពន្យារពេលនេះមិនអាចឲ្យលើសពី ២៤ម៉ោង ឡើយដោយមិនគិតពីថេរវេលាចាំបាច់ដឹកជញ្ជូន ។ មិនតែប៉ុណ្ណោះ ការអនុញ្ញាតឲ្យពន្យារពេលក្នុងការឃាត់ខ្លួនត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងព្រមទាំងមានសំអាងហេតុដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង ប៉ុន្តែប្រសិនបើបុគ្គលឃាត់ខ្លួនជាអនីតិជន ការពន្យារពេលមិនអាចធ្វើបានទេ[៩៨] ។

#### ១.២.១. រយៈពេលឃាត់ខ្លួនសម្រាប់អនីតិជន

- បទឧក្រិដ្ឋ អនីតិជនអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ មិនអាចឃាត់ខ្លួនហួស ៣៦ម៉ោង ឡើយ ។
- បទមជ្ឈិម អនីតិជនអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ មិនអាចឃាត់ខ្លួនហួស ២៤ម៉ោង ឡើយ ។
- បទឧក្រិដ្ឋ អនីតិជនអាយុចាប់ពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ មិនអាចឃាត់ខ្លួនហួស ៤៨ម៉ោង ឡើយ ។
- បទមជ្ឈិម អនីតិជនអាយុចាប់ពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ មិនអាចឃាត់ខ្លួនហួស ៣៦ម៉ោង ឡើយ ។
- អនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ។

[៩៨] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៩៦ ។

**១.២.២. បែបបទនៃការឃាត់ខ្លួន**

**ក. ពេលបានទទួលបញ្ជាឲ្យឃាត់ខ្លួនពីព្រះរាជអាជ្ញា មន្ត្រីនគរបាលយុត្តិធម៌ត្រូវ**

- ធ្វើកំណត់ហេតុស្ដីពីការឃាត់ខ្លួន
- ឲ្យដំណឹងអំពីការសម្រេចឃាត់ខ្លួនដល់បុគ្គលនោះដោយប្រាប់អំពីមូលហេតុនៃឃាត់ខ្លួន
- ប្រាប់ដល់សាមីខ្លួនអំពីសិទ្ធិក្នុងការរកជំនួយមេធាវី[៩៩]
- មន្ត្រីនគរបាលយុត្តិធម៌ ជាអ្នករកអ្នកបកប្រែប្រសិនជាក្នុងករណីចាំបាច់
- មន្ត្រីនគរបាលយុត្តិធម៌ ជាអ្នករកអ្នកជំនាញវាយតម្លៃ ឬធ្វើការសន្និដ្ឋាន ក្នុងករណីចាំបាច់កំណត់ហេតុស្ដីពីការឃាត់ខ្លួនមានចុះសេចក្ដីដូចតទៅ៖
  - ✓ ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឲ្យឃាត់ខ្លួន
  - ✓ អត្តសញ្ញាណនៃបុគ្គលដែលត្រូវឃាត់ខ្លួន
  - ✓ មូលហេតុនៃការឃាត់ខ្លួន
  - ✓ ថ្ងៃ ខែ ឆ្នាំ និងម៉ោង ដែលផ្ដើមឃាត់ខ្លួន
  - ✓ ត្រូវឲ្យដំណឹងអំពីសិទ្ធិរកជំនួយរបស់មេធាវី
  - ✓ ត្រូវប្រាប់ពីឈ្មោះអ្នកបកប្រែ ។[១០០]

កំណត់ហេតុនេះត្រូវមានចុះហត្ថលេខា ឬផ្ដិតម្រាមដៃរបស់ជនឃាត់ខ្លួន ក្រោយពីបានអានកំណត់ហេតុរួច ឬបើសាមីខ្លួនមិនចេះអានអក្សរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានកំណត់ហេតុឲ្យស្ដាប់ ។ ក្នុងករណីជននោះប្រកែកមិនព្រមចុះហត្ថលេខា ឬផ្ដិតម្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេស ហើយកំណត់ហេតុត្រូវភ្ជាប់ជាមួយសំណុំរឿង ។

**ខ. សិទ្ធិជួយប្រាស្រ័យពីមេធាវីក្នុងពេលឃាត់ខ្លួន**

- ការឃាត់ខ្លួនហួសពី ២៤ម៉ោង ឡើងទៅ ជនសង្ស័យអាចសន្ទនាជាមួយមេធាវី ឬជនណាម្នាក់ដែលខ្លួនជ្រើសរើស កុំឲ្យតែជននោះមានការទាក់ទិននៅក្នុងរឿងជាមួយ ។
- មេធាវី ឬអ្នកការពារអាចចូលទៅកាន់ទីកន្លែងឃាត់ខ្លួនជនជាប់ចោទ បានរយៈពេល ៣០នាទី ។
- ការសន្ទនាក្នុងលក្ខខណ្ឌធានាការសម្ងាត់នៃការសន្ទនានេះ ។
- ការសន្ទនាកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរដែលត្រូវភ្ជាប់មកជាមួយសំណុំរឿង ។[១០១]

[៩៩] [១០០] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៩៨ ។

[១០១] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៩៨ ។

### គ. សិទ្ធិទទួលជំនួយពីគ្រូពេទ្យក្នុងពេលឃាត់ខ្លួន

- ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌សុំឲ្យគ្រូពេទ្យមកពិនិត្យជនត្រូវឃាត់ខ្លួនបានគ្រប់ពេលវេលា រាល់ការពិនិត្យត្រូវចេញសេចក្តីបញ្ជាក់សុខភាព
- គ្រូពេទ្យត្រូវពិនិត្យមើលថា តើសុខភាពរបស់ជនត្រូវឃាត់ខ្លួននោះសមស្របនឹងការឃាត់ខ្លួនដែរឬទេ
- ប្រសិនបើសុខភាពបុគ្គលនោះមិនសមស្របនឹងការឃាត់ខ្លួនទេនោះ ត្រូវរាយការណ៍ជាបន្ទាន់ទៅកាន់ព្រះរាជអាជ្ញា
- គ្រូពេទ្យចេញវិញ្ញាបនប័ត្របញ្ជាក់សុខភាពដែលត្រូវភ្ជាប់ជាមួយសំណុំរឿង
- ត្រូវចុះនិទ្ទេសនៅលើកំណត់ហេតុអំពីឈ្មោះរបស់គ្រូពេទ្យ ទាំងថ្ងៃ ខែ ឆ្នាំ នៃការចុះពិនិត្យ ។[១០២]

មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានអំពីការឃាត់ខ្លួនតាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបានដើម្បីឲ្យបានដល់ឪពុកម្តាយ ឬអ្នកតំណាងដែលទទួលខុសត្រូវជាបន្ទាន់ កាលបើជនដែលត្រូវបានឃាត់ខ្លួននោះជាអនីតិជន ។ នៅពេលផុតកំណត់នៃរយៈពេលនៃការឃាត់ខ្លួន បុគ្គលដែលត្រូវបានឃាត់ខ្លួននោះត្រូវបញ្ជូនទៅកាន់ព្រះរាជអាជ្ញា ឬដោះលែងឲ្យមានសេរីភាពឡើងវិញ ។ មួយវិញទៀត សេចក្តីសម្រេចនេះធ្វើឡើងដោយព្រះរាជអាជ្ញា ។

### ១.៣ ការបញ្ជូនខ្លួន

ជាការសម្រេចចុងក្រោយនៃការឃាត់ខ្លួន នៅក្នុងរយៈពេលនៃការឃាត់ខ្លួនជនសង្ស័យ មន្ត្រីនគរបាល-យុត្តិធម៌ត្រូវពិនិត្យបណ្តើរៗនូវពិរុទ្ធភាពជនដែលត្រូវបានឃាត់ខ្លួននោះ ហើយក៏ត្រូវពិចារណានូវមូលហេតុទាំងឡាយដែលគួរឃាត់ខ្លួន ឬមិនឃាត់ខ្លួន ។ ក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ទៅកាន់ព្រះរាជអាជ្ញាអំពីមូលហេតុច្បាស់លាស់ដើម្បីសម្រេចថា តើត្រូវបញ្ជូនទៅកាន់ព្រះរាជអាជ្ញា ឬត្រូវដោះលែងឲ្យមានសេរីភាពឡើងវិញ ?។ ជនដែលត្រូវឃាត់ខ្លួន ហើយត្រូវបញ្ជូនទៅកាន់ព្រះរាជអាជ្ញា គឺត្រូវនាំខ្លួនភ្លាមទៅចំពោះមុខព្រះរាជអាជ្ញា ប្រសិនបើពុំអាចធ្វើបាននៅក្នុងថ្ងៃតែមួយ ដោយមូលហេតុនៃការដឹកជញ្ជូននោះអាចផ្តល់រយៈពេលបន្ថែមដោយព្រះរាជអាជ្ញា[១០៣] ហើយចំពោះមូលហេតុនៃការយឺតយ៉ាវទៀតសោត គឺត្រូវចុះនៅក្នុងកំណត់ហេតុ ដែលត្រូវប្រគល់ជូនព្រះរាជអាជ្ញាដោយមន្ត្រីនគរបាលយុត្តិធម៌ ។

## កថាខណ្ឌទី២ ការស៊ើបអង្កេតបឋម

បទល្មើសទាំងអស់អាចធ្វើតាមរបៀបស៊ើបអង្កេតបឋម លើកលែងតែករណីដែលបទល្មើសទាំងនោះតម្រូវឲ្យមានការបើកការស៊ើបអង្កេតពីតុលាការដឹកនាំដោយចៅក្រមស៊ើបសួរ ដែលជាជានីតិវិធីមួយដែលមាន

---

[១០២] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៩៩ ។

[១០៣] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១០៤ ។

ទម្រង់សាមញ្ញ ប៉ុន្តែផ្តល់ឲ្យអ្នកស៊ើបអង្កេតនូវអំណាចមួយដែលមានកម្រិត ។ បើគ្មានការស៊ើបអង្កេតទេនោះ លទ្ធភាពនៃការស៊ើបអង្កេតទំនងជាមានកម្រិត ពីព្រោះថាមន្ត្រីនគរបាលយុត្តិធម៌ដែលបានដឹងពីរឿងហេតុមួយ ដែលមិនមែនជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងត្រូវតែជូនដំណឹងទៅព្រះរាជអាជ្ញាភ្លាម ។ ព្រះរាជអាជ្ញាទាមទារ ឲ្យបើកការស៊ើបអង្កេតមួយ ដែលនាំទៅដល់ការចេញដីកាចាត់ឲ្យស៊ើបសួរជំនួស ឬចេញដីកាតម្កល់សំណុំរឿង ទុកឥតចាត់ការ អាស្រ័យទៅតាមភាពធ្ងន់ធ្ងរនៃបទល្មើស ។

ក្នុងករណីបទល្មើសមិនជាក់ស្តែង កាលណាបានដឹងអំពីអ្វីមួយដែលអាចជាបទល្មើសឧក្រិដ្ឋ ឬបទល្មើសមជ្ឈិម ឬបទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបឋមដោយឯកឯង ឬតាមការស្នើសុំរបស់ព្រះរាជអាជ្ញា[១០៤] ។ គួរកត់សម្គាល់ដែរថាមន្ត្រីនគរបាលយុត្តិធម៌អាចសម្រេចស៊ើបអង្កេតតាមទម្រង់នៃការស៊ើបអង្កេតបឋមជានិច្ច ទោះបីជាលក្ខខណ្ឌអនុវត្តនីតិវិធីស៊ើបអង្កេតបទល្មើសជាក់ស្តែងត្រូវបានបំពេញក៏ដោយ ប៉ុន្តែការសម្រេចនេះមានឥទ្ធិពលដកហូតពីនគរបាលនូវអំណាចដែលអនុវត្តបានក្នុងការស៊ើបអង្កេតជាក់ស្តែង (ការបង្ខំ) ។ ការស៊ើបអង្កេតបឋមនេះ ត្រូវគោរពតាមវិធានដែលមានចែងក្នុងបទប្បញ្ញត្តិនៃមាត្រា ៩០ (កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ) មាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ) មាត្រា ១០៥ (ការហាមឃាត់មិនឲ្យស្តាប់ដោយឯកឯងជាអាទិ៍) មាត្រា ១០៧ (ការបញ្ជូនកំណត់ហេតុទៅកាន់ព្រះរាជអាជ្ញា) មាត្រា ១០៨ (និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ) ។

**២.១. ការឆែកឆេរ**

**-ការស៊ើបអង្កេតបឋម មន្ត្រីនគរបាលយុត្តិធម៌អាចចុះឆែកឆេរបានដោយ[១០៥]៖**

- អាចសុំម្ចាស់ទីកន្លែងចូលឆែកឆេរ និងចាប់យកវត្ថុតាងមកពិនិត្យបានដោយពុំទាន់ចាំសុំយោបល់ពីព្រះរាជអាជ្ញា ប្រសិនបើម្ចាស់កន្លែងនោះអនុញ្ញាតឲ្យ ប៉ុន្តែការអនុញ្ញាតត្រូវតែមានជាលាយលក្ខណ៍អក្សរដោយស្មោះត្រង់ គ្មានការគាបសង្កត់ណាមួយជាដាច់ខាត ។
- ប្រសិនបើអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធការឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ទៅព្រះរាជអាជ្ញា រួចព្រះរាជអាជ្ញានឹងស្នើសុំទៅប្រធានសាលាដំបូង ហើយលុះត្រាតែប្រធានសាលាដំបូងចេញដីកាឲ្យឆែកឆេរតាមការសុំរបស់ព្រះរាជអាជ្ញា ទើបព្រះរាជអាជ្ញាអាចដឹកនាំឆែកឆេរផ្ទាល់បាន ។
- ក្នុងការឆែកឆេរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេត្រូវធ្វើនៅចំពោះមុខសាក្សី ០២(ពីរ)នាក់ ហើយសាក្សីអាចត្រូវបានចាត់តាំងដោយព្រះរាជអាជ្ញា ក្រៅពីនគរបាល ឬ

[១០៤] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១១១ ។

[១០៥] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១១៣ ។

កងរាជអាវុធហត្ថដែលជាកងកម្លាំងរួម ។ ការឆែកឆេរមិនអាចផ្ដើមធ្វើឡើងមុនម៉ោង ០៦ ព្រឹក និងក្រោយម៉ោង ០៦ល្ងាច ឡើយ ប៉ុន្តែបើកិច្ចការបន្ត គឺអាចបន្តបានតាមពេលសមរម្យ (ការឆែកឆេរត្រូវតែកំណត់ហេតុ និងអនុវត្តតាមខ្លឹមសារមាត្រា ៩១ ជាដាច់ខាត) ។

**២.២. ការបញ្ជាឲ្យចូលខ្លួន**

ការបញ្ជាឲ្យចូលខ្លួន គឺជាអំណាចមួយដែលធ្វើឡើងដោយព្រះរាជអាជ្ញាដែលជាការអនុញ្ញាតមួយដែលផ្ដល់ឲ្យមន្ត្រីនគរបាលយុត្តិធម៌អាចមានសិទ្ធិក្នុងការប្រើប្រាស់កងកម្លាំងសាធារណៈ ដើម្បីបង្ខំបុគ្គលនោះឲ្យចូលមកបង្ហាញខ្លួនបានក្នុងករណីបដិសេធមិនព្រមចូលតាមបញ្ជារបស់ព្រះរាជអាជ្ញា ។ បុគ្គលគ្រប់រូបដែលត្រូវបានសង្ស័យថាបានចូលរួមក្នុងការប្រព្រឹត្តិបទល្មើស ឬដែលអាចផ្ដល់ព័ត៌មានស្ដីអំពីរឿងហេតុបាន មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្ដាប់ចម្លើយ ហើយបុគ្គលនោះត្រូវតែបង្ហាញខ្លួន[១០៦] ។ ប្រសិនជាមានការរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងទៅកាន់ជូនដំណឹងទៅកាន់ព្រះរាជអាជ្ញាដែលអាចធ្វើការបញ្ជាឲ្យចូលខ្លួនបាន ដោយត្រូវមានចុះអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ កាលបរិច្ឆេទ និងមានចុះហត្ថលេខាដោយព្រះរាជអាជ្ញា ព្រមទាំងមានបោះត្រាផងដែរ ។

ព្រះរាជអាជ្ញាមានសមត្ថកិច្ចបង្គាប់ឲ្យប្រគល់វត្ថុ ដែលចាប់បាននៅក្នុងពេលស៊ើបអង្កេតនោះទៅហើយម្ចាស់ដើមវិញ[១០៧] ប្រសិនបើវត្ថុទាំងនោះពុំមានប្រយោជន៍សម្រាប់ការរកការពិតទេ ប៉ុន្តែ វត្ថុដែលមានគ្រោះថ្នាក់ចំពោះមនុស្ស ឬចំពោះទ្រព្យសម្បត្តិ ដូចជាអាវុធ ឬ ជាតិផ្ទុះមិនអាចប្រគល់ឲ្យវិញបានទេ ។ លើសពីនេះ វត្ថុទាំងនោះព្រមទាំងវត្ថុដែលត្រូវបានកាន់កាប់ដោយខុសច្បាប់ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ឬត្រូវបំផ្លាញចោល ។ កាលណាមានការក្នុងករណីមិនព្រមប្រគល់ឲ្យវិញទេ អ្នកប្ដឹងអាចប្ដឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាបាន ។ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញាគឺគ្មានសមត្ថកិច្ចក្នុងការប្រគល់ទេ កាលណាមានការចោទប្រកាន់ធ្វើឡើងនៅចំពោះមុខយុត្តាធិការស៊ើបសួរ ឬយុត្តាធិការជំនុំជម្រះ ប៉ុន្តែ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញានៅតែមានសមត្ថកិច្ចកាលណាការស៊ើបសួរត្រូវបានបញ្ចប់ដោយសេចក្ដីសម្រេចលើកលែងចោទប្រកាន់ជាស្ថាពរ ។

កាលបើតុលាការដែលទទួលពាក្យប្ដឹងបានចេញសេចក្ដីសម្រេចមួយជាស្ថាពរ[១០៨] ហើយពុំបានសម្រេចសេចក្ដីលើការប្រគល់វត្ថុដល់ម្ចាស់ដើមវិញទេ នោះព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញាមានសមត្ថកិច្ចទៅតាមករណីនីមួយៗដើម្បីសម្រេចដោយឯកឯងលើពាក្យសុំឲ្យមានការប្រគល់វត្ថុដល់ម្ចាស់ដើមវិញ នៅពេលដែលកម្មសិទ្ធិនៃវត្ថុនោះពុំមានការជំទាស់អ្វីជាប្រាកដប្រជាទេ ។

---

[១០៦] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១១៨ ។

[១០៧] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ១១៩ ។

[១០៨] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧, មាត្រា ១២០ ។

## ផ្នែកទី២ ដំណាក់កាលនៃការចោទប្រកាន់

ការចោទប្រកាន់ គឺសំដៅដល់ការកំណត់អំពីអត្ថិភាពនៃបទល្មើសដោយស្ថាប័នមានសមត្ថកិច្ចរបស់រដ្ឋដែលកំណត់ដោយច្បាប់ ។ នៅពេលដែលមានការរំលោភបំពានណាមួយកើតឡើង ជារឿយៗយើងតែងតែសង្កេតឃើញថាមានការដាក់ពាក្យបណ្តឹងពីសំណាក់ជនរងគ្រោះ ឬគ្រួសារជនរងគ្រោះទៅកាន់ប៉ុស្តិ៍នគរបាល ឬតុលាការ ។ ប្រជាជនភាគច្រើនគិតថាការដាក់ពាក្យបណ្តឹង គឺជាការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ព្រោះនៅក្នុងពាក្យបណ្តឹងបានសរសេរអំពីអង្គហេតុ អំពើល្មើស និងការចោទប្រកាន់ទៅលើបុគ្គលដែលជាជនល្មើស ប៉ុន្តែការពិតទៅ ការចោទប្រកាន់តាមពាក្យបណ្តឹងនេះ គឺគ្រាន់តែជាការប្រកាសប្រាប់ដល់ស្ថាប័នដែលមានសមត្ថកិច្ចអំពីរឿងរ៉ាវដែលបានកើតឡើង និងដើម្បីឲ្យស្ថាប័នមានសមត្ថកិច្ចនោះធ្វើចំណាត់ការតាមផ្លូវច្បាប់តែប៉ុណ្ណោះ ។ អង្គការអយ្យការបានដើរតួនាទីយ៉ាងសំខាន់ដើម្បីពិនិត្យ និងធ្វើការថ្លឹងថ្លែងចំពោះអំពើទាំងនោះ ថាតើគួរធ្វើការចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ (មិនចោទប្រកាន់) ។ នៅក្នុងក្របខណ្ឌនៃនីតិព្រហ្មទណ្ឌ មានគោលការណ៍ចំនួនពីរសម្រាប់ធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌគឺ គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ និងគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ។

គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់[១០៩]ក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាលរបស់កម្ពុជាឆ្នាំ ១៩៩២ សំដៅទៅលើកាលណាមានបទល្មើសព្រហ្មទណ្ឌមួយកើតឡើង ព្រះរាជអាជ្ញាដាច់ខាតត្រូវតែធ្វើការចោទប្រកាន់ មិនឲ្យអំពើល្មើសណាមួយគេចផុតពីការផ្តន្ទាទោសពីបញ្ញត្តិច្បាប់ឡើយ ហើយព្រះរាជអាជ្ញាមិនអាចសម្រេចតម្កល់រឿងទុកឥតចាត់ការបានឡើយ ទោះបីជាអំពើល្មើសនោះជាអំពើតូចតាចក្តី ឬមានការប៉ះពាល់សណ្តាប់ធ្នាប់សង្គមតិចតួចក៏ដោយ ពោលគឺឲ្យតែមានអង្គហេតុដែលជាបទល្មើសព្រហ្មទណ្ឌកើតឡើង ព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់ទាំងអស់ ។ គោលការណ៍នេះមានភាពវិជ្ជមានត្រង់ថា *គ្រប់អង្គហេតុក្នុងរឿងព្រហ្មទណ្ឌទាំងអស់ គឺសុទ្ធតែត្រូវបានចោទប្រកាន់ដោយព្រះរាជអាជ្ញា ដែលអាចផ្តល់យុត្តិធម៌ដល់ជនរងគ្រោះក៏ដូចជាចៀសវាងការសម្រេចតម្កល់រឿងទុកឥតចាត់ការ ដែលអាចមានភាពមិនប្រក្រតីណាមួយ* ។ ប៉ុន្តែផ្ទុយទៅវិញ នៅពេលដែលគ្រប់សំណុំរឿងសុទ្ធតែត្រូវបានចោទប្រកាន់ដោយព្រះរាជអាជ្ញា នោះធ្វើឲ្យសំណុំរឿងព្រហ្មទណ្ឌអាចនឹងត្រូវបានកកស្ទះច្រើនដែលធ្វើឲ្យដំណើរការនីតិវិធីក្នុងរឿងក្តីព្រហ្មទណ្ឌនីមួយៗមិនអាចបញ្ចប់ដោយឆាប់រហ័សបាន ។

គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ ត្រូវបាននិរាករណ៍ដោយវត្តមានក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ដោយជំនួសមកវិញនូវគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ សម្រាប់ដំណើរការរឿងក្តី

---

[១០៩] លោកមេធាវី ម៉េង វណ្ណី , អត្ថបទពត៌មានយល់ដឹងផ្នែកច្បាប់ គោលការណ៍នៃការចោទប្រកាន់ ។

ព្រហ្មទណ្ឌ ។ គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់គឺជា គោលការណ៍មួយក្នុងនីតិវិធីព្រហ្មទណ្ឌ ដែលផ្តល់សិទ្ធិអំណាចដល់ព្រះរាជអាជ្ញា ធ្វើការថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្តឹង និងពាក្យបណ្តឹងបរិហារ ដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលបញ្ជូនមក ដើម្បីសម្រេចថាតើគួរតែតម្កល់រឿងទុកឥតចាត់ការ ឬគួរធ្វើការចោទប្រកាន់ទៅលើជនណាម្នាក់ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ តាមរយៈគោលការណ៍នេះ ព្រះរាជអាជ្ញាអាចប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការសម្រេចមិនធ្វើការចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌណាមួយទោះបីជាអំពើនោះមានចែងក្នុងក្រមព្រហ្មទណ្ឌ ឬច្បាប់ផ្សេងៗទៀតក៏ដោយ ។ តាមរយៈគោលការណ៍នេះ ព្រះរាជអាជ្ញាអាចពិចារណាអំពីតុល្យភាពនៃការផ្តន្ទាទោស និងទំហំនៃព្យសនកម្ម (ការខូចខាត) របស់ជនរងគ្រោះ និងសង្គមជាតិទាំងមូលត្រូវទទួលរង ។ ឧទាហរណ៍៖ ករណីលួចផ្លែល្ហុង ០២ ទៅ ០៣ ផ្លែ ដើម្បីទទួលទាន ។

## កថាខណ្ឌទី១ ការតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកឥតចាត់ការ គឺជាសេចក្តីសម្រេចរបស់តំណាងអយ្យការ តាមគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ដែលមានព្រះរាជអាជ្ញាជាម្ចាស់នៃបណ្តឹងអាជ្ញា និងអនុវត្តបណ្តឹងអាជ្ញាជាទូទៅដើម្បីផលប្រយោជន៍សាធារណៈ និងមានតួនាទីក្នុងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ។ ព្រះរាជអាជ្ញាមានសិទ្ធិអំណាចក្នុងការចោទប្រកាន់ ឬតម្កល់ទុកឥតចាត់ការបានតាមរយៈដីកាតម្កល់រឿងទុកឥតចាត់ការ មុននឹងសម្រេចការស៊ើបអង្កេតបឋម ឬបង្គាប់ឲ្យធ្វើការស្រាវជ្រាវបន្ថែមទៅលើអំពើដែលជាបទល្មើស និងអំពើដែលមិនមែនជាបទល្មើសផងដែរ ។

### ១.១. មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ

**- មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ[១១០]មានដូចជា៖**

- កង្វះអត្តសញ្ញាណរបស់ជនល្មើស ឬមិនអាចកំណត់អត្តសញ្ញាណរបស់ជនល្មើស
- កង្វះធាតុផ្សំនៃបទល្មើស ឬពុំមានភស្តុតាងគ្រប់គ្រាន់ក្នុងការដាក់បន្ទុក
- នត្ថិភាពនៃបទល្មើស ឬអំពើដែលបង្ហាញមកនោះមិនបង្កើតឲ្យទៅជាបទល្មើសព្រហ្មទណ្ឌណាមួយ
- បទល្មើសដែលបង្កឲ្យមានព្យសនកម្មតិចតួច
- ជនល្មើសជាអនីតិជនអាយុក្រោម ១៤ឆ្នាំ ឬជាជនវិបល្លាសស្មារតី
- អភ័យឯកសិទ្ធិ
- អនិយ័តភាពនៃនីតិវិធី

[១១០] លោក សូ ឥស្សរៈ, អត្ថបទ មូលហេតុដែលតុលាការសម្រេចតម្កល់រឿងទុកឥតចាត់ការ ។

- ការការពារស្របច្បាប់
- ការផុតរលត់នៃបណ្តឹងអាជ្ញា ។

### ១.២. នីតិវិធីក្នុងការអនុវត្តការតម្កល់រឿងទុកឥតចាត់ការ

កាលណាបណ្តឹងមួយត្រូវបានតម្កល់ទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវជូនដំណឹងដល់អ្នកប្តឹងពីសេចក្តីសម្រេចរបស់ខ្លួននៅក្នុងរយៈពេលយូរបំផុត ០២(ពីរ)ខែ ដោយគិតពីថ្ងៃដែលចុះពាក្យបណ្តឹងក្នុងបញ្ជី ។ ការតម្កល់រឿងទុកឥតចាត់ការត្រូវតែមានសំអាងច្បាប់ និងសំអាងហេតុច្បាស់លាស់ ព្រមទាំងគ្មានអាជ្ញាអស់ជំនុំទេ បានសេចក្តីថា *ព្រះរាជអាជ្ញាអាចធ្វើការសើរើ កែប្រែសេចក្តីសម្រេចរបស់ខ្លួនឡើងវិញដោយមានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ ក្នុងខណៈដែលបណ្តឹងអាជ្ញាមិនទាន់ផុតរលត់នៅឡើយ* ។ ប្រសិនបើអ្នកប្តឹងមានការមិនសុខចិត្តនឹងសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការទេ នោះសាមីខ្លួនមានសិទ្ធិអាចធ្វើការប្តឹងទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន ហើយបន្ទាប់មកសំណុំរឿងនឹងត្រូវបានបញ្ជូនភ្លាមទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដោយតំណាងអយ្យការអមសាលាដំបូង ដើម្បីឲ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ពិនិត្យពិចារណា និងសម្រេច ។ មុននឹងធ្វើសេចក្តីសម្រេច អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចធ្វើការស៊ើបអង្កេតបន្ថែមទៀតបាន បើសិនជាយល់ឃើញថា ការតវ៉ានេះមានមូលហេតុត្រឹមត្រូវ គឺអាចចេញអធិបញ្ញាដែលត្រូវធ្វើជាលាយលក្ខណ៍អក្សរទៅកាន់ព្រះរាជអាជ្ញាអមសាលាដំបូងឲ្យធ្វើការចោទប្រកាន់តាមការសន្និដ្ឋានរបស់ខ្លួន ។ ផ្ទុយទៅវិញ ប្រសិនជាយល់ឃើញថា ការតវ៉ាមិនមានមូលហេតុត្រឹមត្រូវទេ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចតម្កល់សេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញាអមសាលាដំបូងទុកថាបានការដដែល ហើយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវជូនដំណឹងអំពីការសម្រេចនេះទៅដល់អ្នកប្តឹងតវ៉ានោះឲ្យបានដឹង[១១១] ។

☛**គួរកត់សម្គាល់៖** *ថ្វីត្បិតតែក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់ អំណាចឆន្ទានុសិទ្ធិដល់ព្រះរាជអាជ្ញាក្នុងការតម្កល់រឿងទុកឥត ចាត់ការចំពោះអំពើដែលជាបទល្មើសតាមរយៈការថ្លឹងថ្លែងរបស់ ខ្លួន ប៉ុន្តែការសម្រេចតម្កល់រឿងទុកឥតចាត់ការនេះ ត្រូវតែមាន សំអាងច្បាប់ និងសំអាងហេតុ (មាត្រា៤១-២ នៃក្រមនីតិវិធី.)។ មានន័យថា ត្រូវតែមានអំណះអំណាងគ្រប់គ្រាន់ដើម្បីគាំទ្រដល់ ការចេញសេចក្តីសម្រេចរបស់ខ្លួន ។*

## កថាខណ្ឌទី២ ការចោទប្រកាន់

នៅក្នុងការចោទប្រកាន់ ដែលជាចំណាត់ការលើរឿងក្តីដែលជាបទល្មើសនេះ ត្រូវបាននីតិនិពន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌបញ្ញត្តិជាបច្ចេកស័ព្ទគតិយុត្តថា **“ជម្រើសនៃការចោទប្រកាន់”** ។ ជម្រើសនៃការចោទប្រកាន់

[១១១] ក្រមនីតិវិធីព្រហ្មទណ្ឌទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៤១ ។

អាចធ្វើឡើងតាមវិធីចំនួន ០២(ពីរ) គឺព្រះរាជអាជ្ញាអាចធ្វើការការបើកការស៊ើបសួរ ដោយបញ្ជូនរឿងក្តីទៅកាន់យុត្តាធិការស៊ើបសួរ និងព្រះរាជអាជ្ញាអាចធ្វើការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដោយបញ្ជូនរឿងក្តីទៅយុត្តាធិកាជំនុំជម្រះតែម្តង ។ ជម្រើសនៃការចោទប្រកាន់ បានបើកផ្លូវឲ្យព្រះរាជអាជ្ញាមានមធ្យោបាយច្រើនក្នុងការធ្វើបណ្តឹងអាជ្ញា ដោយអាស្រ័យលើស្ថានភាពនៃសំណុំរឿង និងប្រភេទនៃបទល្មើស ។

ការចោទប្រកាន់ខាងបទល្មើសព្រហ្មទណ្ឌអាចធ្វើតាមនីតិវិធី ០៣(បី) យ៉ាងគឺៈ ការបើកការស៊ើបសួរ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម[១១២] ។

### ២.១. ការបើកការស៊ើបសួរ

ការបើកការស៊ើបសួរ គឺជាប្រភេទមួយនៃការចោទប្រកាន់របស់តំណាងអយ្យការ ដែលធ្វើការចោទប្រកាន់តាមរយៈការបើកការស៊ើបសួរ ធ្វើឡើងដើម្បីសុំឲ្យយុត្តាធិកាស៊ើបសួរអនុវត្តច្បាប់ ពោលគឺដើម្បីឲ្យចៅក្រមស៊ើបសួរធ្វើចំណាត់ការបន្ត ។ ការចោទប្រកាន់តាមរយៈនីតិវិធីនេះ គឺធ្វើឡើងក្នុងគោលបំណងដើម្បីឲ្យចៅក្រមស៊ើបសួរធ្វើការស្រាវជ្រាវបន្ថែម ព្រោះសំណុំរឿងពុំទាន់មានលក្ខណៈអាចបញ្ជូនទៅជំនុំជម្រះបាន ។

- កត្តាដែលនាំឲ្យមានការស្រាវជ្រាវបន្ថែម គឺបណ្តាលមកពីកត្តាផ្សេងៗដែលទាក់ទងនឹងភស្តុតាងដូចជាៈ ពុំទាន់មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ពុំទាន់មានភស្តុតាងចាំបាច់សម្រាប់ធ្វើការជំនុំជម្រះជាដើម ។
- កត្តាទាក់ទងនឹងជនល្មើសដូចជាករណីៈ ជនល្មើសមិនស្គាល់អត្តសញ្ញាណ ឬការប្រព្រឹត្តបទល្មើសមានគ្នាច្រើនដែលត្រូវស្រាវជ្រាវបន្ថែមជាអាទិ៍ និងកត្តាផ្សេងៗទៀត ។

#### ២.១.១. លក្ខខណ្ឌដែលនាំឲ្យមានការបើកការស៊ើបសួរ

តំណាងអយ្យការ អាចចោទប្រកាន់តាមតាមរយៈការបើកការស៊ើបសួរនៅពេលលក្ខខណ្ឌទាក់ទងនឹងបទល្មើសត្រូវបានបំពេញ

- បទឧក្រិដ្ឋៈ ក្នុងករណីបទឧក្រិដ្ឋ តំណាងអយ្យការត្រូវតែបើកការស៊ើបសួរ[១១៣]
- បទមជ្ឈិមៈ ក្នុងករណីបទមជ្ឈឹម តំណាងអយ្យការអាចជ្រើសរើសនីតិវិធីចោទប្រកាន់តាមការបើកការស៊ើបសួរ ឬតាមនីតិវិធី ២ ផ្សេងទៀត[១១៤]
- ចំពោះបទល្មើសលហុមិនអាចបើកការស៊ើបសួរបានទេ ។

---

[១១២] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៤៣ ។

[១១៣] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧, មាត្រា ៤៤ ។

[១១៤] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧, មាត្រា ៤៥ ។

### ២.១.២. នីតិវិធីនៃការបើកការស៊ើបសួរ

ការបើកការស៊ើបសួរ ត្រូវបើកតាមរយៈដីកាបញ្ជូនរឿងឲ្យស៊ើបសួរដែលចេញដោយព្រះរាជអាជ្ញាប្តឹងទៅកាន់ចៅក្រមស៊ើបសួរឲ្យបើកការស៊ើបសួរ ។ ចៅក្រមស៊ើបសួរដែលទទួលបានបណ្តឹងអំពីអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការនេះ អាចធ្វើការស៊ើបសួរតែចំពោះអង្គហេតុដែលបានបញ្ជូនមកឲ្យខ្លួនពិនិត្យតែប៉ុណ្ណោះ ។ នៅពេលបំពេញភារកិច្ច ប្រសិនជាលេចមានចេញនូវអង្គហេតុថ្មីដែលអាចជាបទល្មើសព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងអំពីព័ត៌មាននៃអង្គហេតុថ្មីនោះទៅកាន់តំណាងអយ្យការ ដើម្បីឲ្យតំណាងអយ្យការអាចប្តឹងសុំឲ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនោះតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ។ ចៅក្រមស៊ើបសួរគ្មានអំណាចក្នុងការស៊ើបសួរអំពីអង្គហេតុថ្មីណាមួយឡើយ ប្រសិនបើមិនទទួលបាននូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពីព្រះរាជអាជ្ញាទេនោះ ។

**-នីតិវិធីនៃការបើកការស៊ើបសួរអាចត្រូវបានធ្វើឡើងទៅតាមករណី ០២យ៉ាងគឺ៖**[១១៥]

- ការបើកការស៊ើបសួរតាមរយៈបណ្តឹង ដែលមានការមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី
- ការបើកការស៊ើបសួរតាមរយៈសំណុំរឿងបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌ ។

#### ក. ការបើកការស៊ើបសួរតាមរយៈបណ្តឹង ដែលមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

ដើមបណ្តឹងអាចដាក់ពាក្យបណ្តឹងមកកាន់ស្ថាប័នអយ្យការដោយផ្ទាល់បាន ដើម្បីស្នើសុំឲ្យព្រះរាជអាជ្ញាធ្វើការពិនិត្យ និងសម្រេចក្នុងការធ្វើបណ្តឹងអាជ្ញា ។ ក្រោយពីពេលដែលព្រះរាជអាជ្ញាទទួលបាននូវពាក្យបណ្តឹងពីសំណាក់ដើមបណ្តឹង ព្រះរាជអាជ្ញាត្រូវធ្វើការថ្លឹងថ្លែងសម្រេចក្នុងការធ្វើការចោទប្រកាន់តាមរយៈនីតិវិធីណាមួយប្រសិនជាមានការពិនិត្យឃើញថាអំពើនៅក្នុងអង្គហេតុនៃសំណុំរឿងនោះជាបទល្មើស ។ នៅក្នុងការថ្លឹងថ្លែងទៀតសោត នឹងត្រូវធ្វើឡើងតាមរយៈការស្នើឲ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើការស៊ើបអង្កេតបឋម ឬកោះហៅដើមបណ្តឹង ឬសាក្សីមកសួរ និងស្តាប់ចម្លើយដោយផ្ទាល់ ។ បន្ទាប់ពីការស៊ើបអង្កេតត្រូវបានបញ្ចប់ ហើយរកឃើញថាអង្គហេតុនោះមានបទល្មើស និងបានបំពេញលក្ខខណ្ឌដែលនាំឲ្យមានការបើកការស៊ើបសួរបាន ព្រះរាជអាជ្ញានឹងសម្រេចចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទៅចៅក្រមស៊ើបសួរ ។

#### ខ. ការបើកការស៊ើបសួរតាមរយៈសំណុំរឿងបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌

នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ទទួលបានពាក្យបណ្តឹងពីប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនហើយ មន្ត្រីនគរបាលយុត្តិធម៌អាចបើកការស៊ើបអង្កេតបឋមទៅលើពាក្យបណ្តឹងដែលខ្លួនបានទទួលនៅពេលដឹងថាអំពើល្មើសនោះជាបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ រួចកសាងសំណុំរឿងបញ្ជូនទៅតំណាង

[១១៥] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៤៣ ។

អយ្យការ ហើយចំពោះបទល្មើសជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនជនសង្ស័យ និងចាប់ខ្លួនបញ្ជូនទៅកាន់ព្រះរាជអាជ្ញា ។

### ២.២. ការបញ្ជូនទៅជំនុំជំរះផ្ទាល់

ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាប្រភេទមួយនៃការចោទប្រកាន់របស់តំណាងអយ្យការដែលចោទប្រកាន់តាមរយៈការបញ្ជូនទៅជំនុំជម្រះផ្ទាល់ធ្វើឡើងដោយពុំឆ្លងកាត់ដំណាក់កាលស៊ើបសួរនោះទេ គឺបញ្ជូនសំណុំរឿងទៅចៅក្រមជំនុំជម្រះដើម្បីធ្វើការជំនុំជម្រះតែម្តង ។ ការចោទប្រកាន់តាមនីតិវិធីនេះ គឺត្រូវបានអនុវត្តចំពោះរឿងក្តីដែលមានលក្ខណៈគ្រប់គ្រាន់អាចជំនុំជម្រះបាន ដោយពុំត្រូវការការស្រាវជ្រាវបន្ថែមក្នុងគោលបំណងដើម្បីឲ្យចំណេញពេលវេលា និងដើម្បីកាត់បន្ថយសំណុំរឿងនៅដំណាក់កាលស៊ើបសួរ ។

#### ២.២.១. លក្ខខណ្ឌដែលនាំឲ្យមានការបញ្ជូនទៅជំនុំជម្រះផ្ទាល់

តំណាងអយ្យការអាចចោទប្រកាន់តាមរយៈការបញ្ជូនទៅជំនុំជម្រះផ្ទាល់ នៅពេលដែលលក្ខខណ្ឌខាងក្រោមត្រូវបានបំពេញ៖

- ប្រភេទបទល្មើស៖ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់អាចធ្វើឡើងចំពោះ បទមជ្ឈិម (មាត្រា៤៥) និងបទលហុ (មាត្រា៤៩នៃក្រមនីតិព្រហ្មទណ្ឌ) ។
- អត្តសញ្ញាណជនជាប់ចោទ៖ នីតិវិធីនេះធ្វើឡើងតាមរយៈការកោះហៅជនជាប់ចោទទៅជំនុំជម្រះនៅចំពោះមុខចៅក្រមជំនុំជម្រះ ទាមទារឲ្យមានអត្តសញ្ញាណរបស់ជនត្រូវចោទ ។
- មានលក្ខណៈគ្រប់គ្រាន់អាចជំនុំជម្រះបាន៖ ពុំត្រូវការការស្រាវជ្រាវបន្ថែម ។

#### ២.២.២. នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់

នៅពេលដែលទទួលបានបណ្តឹងសាមញ្ញ ឬសំណុំរឿងដែលបញ្ជូនមកពីមន្ត្រីនគរបាលយុត្តិធម៌ តំណាងអយ្យការធ្វើចំណាត់ការដូចតទៅ៖

- ការស្រាវជ្រាវ៖ តាមមាត្រា ៤០ កថាខណ្ឌទី ២ (ក្រមនីតិព្រហ្មទណ្ឌ) មុនសម្រេចចោទប្រកាន់ តំណាងអយ្យការបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឲ្យស្រាវជ្រាវបន្ថែម ។ ការស្រាវជ្រាវអាចធ្វើឡើងតាមវិធីផ្សេងៗដូចជា ស្នើសុំឲ្យបើកការស៊ើបអង្កេតបឋម កោះហៅសួរ និងស្តាប់ចម្លើយ បង្គាប់ឲ្យចូលខ្លួនផែកឆេរ....... ។
- ការចោទប្រកាន់៖ នៅពេលសម្រេចថាចោទប្រកាន់តាមការបញ្ជូនទៅជំនុំជម្រះផ្ទាល់ តំណាងអយ្យការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ និងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ។
- ការបញ្ជូនដីកា៖ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ត្រូវបញ្ជូនទៅជនជាប់ចោទ ។

### ២.៣. ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម

ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម គឺជាប្រភេទមួយនៃការចោទប្រកាន់របស់តំណាងអយ្យការ ដែលធ្វើការចោទប្រកាន់តាមរយៈការបង្គាប់ឲ្យចូលខ្លួនភ្លាមធ្វើឡើងដោយពុំឆ្លងកាត់ដំណាក់កាលស៊ើបសួរនោះទេ គឺបញ្ជូនសំណុំរឿង និងជនជាប់ចោទទៅចៅក្រមជំនុំជម្រះដើម្បីធ្វើការជំនុំជម្រះ នៅថ្ងៃដែលជនជាប់ចោទចូលមកបង្ហាញខ្លួននៅចំពោះមុខតំណាងអយ្យការតែម្តង ។ ការចោទប្រកាន់តាមនីតិវិធីនេះ គឺត្រូវបានអនុវត្តចំពោះរឿងក្តីមានលក្ខណៈគ្រប់គ្រាន់អាចជំនុំជម្រះបាន (ពុំត្រូវការការស្រាវជ្រាវបន្ថែម) ហើយក្នុងគោលបំណងដើម្បីឲ្យចំណេញពេលវេលានិងដើម្បីកាត់បន្ថយសំណុំរឿងនៅដំណាក់កាលស៊ើបសួរដូចការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ប៉ុន្តែខុសត្រង់លក្ខខណ្ឌមួយចំនួន ។

#### ២.៣.១. លក្ខខណ្ឌនៃការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម

តាមមាត្រា ៤៧ ការចោទប្រកាន់តាមរយៈការបង្គាប់ចូលបង្ហាញខ្លួនភ្លាមអាចប្រព្រឹត្តទៅបាន ប្រសិនបើលក្ខខណ្ឌទាំង ០៤ ត្រូវបានបំពេញ៖

- បទល្មើសជាបទល្មើសជាក់ស្តែង
- បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ឆ្នាំ និងយ៉ាងច្រើន ៥ឆ្នាំ
- ជនជាប់ចោទជានីតិជន
- រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន ។

#### ២.៣.២. នីតិវិធីនៃការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម

តាមមាត្រា ៤៨ នៃក្រមនីតិព្រហ្មទណ្ឌ កាលណាសម្រេចថា ត្រូវប្រើនីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ព្រះរាជអាជ្ញាត្រូវ៖

- ពិនិត្យអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឲ្យខ្លួន
- ឲ្យដំណឹងដល់ជននេះអំពីរឿងរ៉ាវដែលចោទប្រកាន់ និងឈ្មោះបទល្មើស
- ទទួលចម្លើយរបស់បុគ្គលនោះ ប្រសិនបើសាមីខ្លួនចង់និយាយ
- ធ្វើកំណត់ហេតុស្តីអំពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ដើម្បីចោទប្រកាន់
- បញ្ជូនសំណុំរឿង និងជនជាប់ចោទទៅជំនុំជម្រះនៅក្នុងថ្ងៃនោះតែម្តង ។

## ផ្នែកទី៣ ព្រះរាជអាជ្ញាក្នុងដំណាក់កាលនៃការជំនុំជម្រះ

ដំណាក់កាលជំនុំជម្រះ ជាដំណាក់កាលដែលសំណុំរឿងនឹងអាចត្រូវបញ្ចប់ កាលណាសំណុំរឿងនោះបានឆ្លងកាត់ការជំនុំជម្រះរួចជាសេចក្តីសម្រេចហៅថា “**សាលក្រម ឬសាលដីកា**” ។

## កថាខណ្ឌទី ១ វិធានទូទៅនៃការជំនុំជម្រះ

ជាគោលការណ៍តុលាការពិនិត្យធាតុនៃសំណុំរឿង និងស្តាប់ចម្លើយរបស់ភាគីទាំងអស់ដែលពាក់ព័ន្ធទៅនឹងរឿងក្តី ។ ប្រសិនបើយល់ឃើញថា មានករណីចាំបាច់ត្រូវស្រាវជ្រាវបន្ថែមនោះ តុលាការអាចបង្គាប់តាមសាលក្រម ឲ្យស៊ើបសួរបន្ថែមបាន ដើម្បីស្វែងរកការពិតឲ្យបានច្បាស់លាស់ ។ ម៉្យាងទៀតតុលាការដែលទទួលបណ្តឹងអាជ្ញាមានសមត្ថកិច្ច ដើម្បីសម្រេចអំពីគ្រប់អញ្ញត្រកម្មទាំងអស់ ដែលលើកឡើងដោយគូភាគី លើកលែងតែច្បាប់បានបញ្ញត្តិផ្សេងពីនេះ និងមានសមត្ថកិច្ច ជាអាទិ៍ ដើម្បីសម្រេចពីអញ្ញត្រកម្ម ស្តីពីមោឃភាពនៃនីតិវិធីដែលគេដាក់ជូនខ្លួនពិនិត្យ លើកលែងតែកាលណាតុលាការទទួលជំនុំជម្រះតាមដីកាបញ្ជូនពីចៅក្រមស៊ើបសួរ ឬ សាលដីកាបញ្ជូនរបស់សភាស៊ើបសួរ[១១៦] ។

☛**គួររំលឹកថា:** *នៅពេលបើកសវនាការ មានការពិភាក្សាដេញដោល ដែលធ្វើឡើងជាសាធារណៈ ។ ប៉ុន្តែករណីដែលតុលាការយល់ឃើញថាបើសវនាការជាសាធារណៈអាចបង្កឲ្យមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សង្គម ឬដល់ទំនៀមទម្លាប់របស់ខ្មែរយើងនោះ តុលាការអាចចេញនូវដីកាដោយមានសំអាងហេតុអាចបង្គាប់ឲ្យការពិភាក្សាដេញដោលទាំងស្រុង ឬក៏មួយផ្នែកប្រព្រឹត្តទៅជាការសម្ងាត់បាន ដោយសារមូលហេតុដូចបានបញ្ជាក់នេះ។*

មួយវិញទៀត ចំពោះវិធាននៃភស្តុតាងក្នុងរឿងព្រហ្មទណ្ឌអាចជូនបានដោយសេរី មានន័យថា *ភាគីនៃរឿងក្តីអាចស្វែងរកភស្តុតាងនានា ដែលខ្លួនគិតថាមានប្រយោជន៍ ដើម្បីដាក់ជូនទៅឲ្យតុលាការពិនិត្យបានដោយសេរី* ។ តុលាការនឹងថ្លឹងថ្លែងដោយឥតស្សរចិត្តពីតម្លៃភស្តុតាងដែលគេដាក់ជូនមកខ្លួនដើម្បីពិនិត្យ ដោយផ្អែកទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន និងមានសំអាងក្នុងសេចក្តីសម្រេចរបស់ខ្លួន តែលើភស្តុតាងដែលមានក្នុងសំណុំរឿង ឬត្រូវគេយកមកបង្ហាញនៅពេលសវនាការប៉ុណ្ណោះ មានន័យថា *ពេលសម្រេចសេចក្តីតុលាការធ្វើការសម្រេចក្តី ដោយផ្អែកលើភស្តុតាងជាមូលដ្ឋានសំខាន់ៗក្នុងការចេញសេចក្តីសម្រេច*។ ចំពោះការសារភាព ប្រភេទភស្តុតាងដទៃទៀតដែរត្រូវដាក់ជូនទៅតុលាការធ្វើការថ្លឹងថ្លែង ផ្ទុយទៅវិញ ចម្លើយដែលបានទទួលដោយសារការបង្ខិតបង្ខំមិនអាចយកមកធ្វើជាភស្តុតាងបានឡើយ ។

## កថាខណ្ឌទី២ ការកោះហៅ

ព្រះរាជអាជ្ញា ត្រូវកោះហៅជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី អ្នកជំនាញ អ្នកបកប្រែ អ្នកទទួលខុសត្រូវរដ្ឋប្បវេណីតាមរយៈព័ត៌មានដែលផ្តល់ឲ្យដោយជនជាប់ចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីឲ្យចូលសវនាការតាមរយៈដីកាកោះហៅ បន្ទាប់ពីបានទទួលបណ្តឹងដោយដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសភាស៊ើប-សួរ ។

[១១៦] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៣៤២ ។

ការធ្វើដីកាកោះហៅជនជាប់ចោទ ព្រះរាជអាជ្ញាត្រូវធ្វើដោយមាននិទ្ទេសដូចជា អត្តសញ្ញាណជនជាប់ចោទ កាលបរិច្ឆេទ និងទីកន្លែងកំណើតនៃជនជាប់ចោទ លំនៅឋាននៃជនជាប់ចោទ ការយោងដីកា ឬសាលដីកាបញ្ជូនរបស់តុលាការ ដែលត្រូវទទួលបណ្តឹងដើម្បីជំនុំជម្រះ ទីកន្លែង កាលបរិច្ឆេទ និងម៉ោងសវនាការ កាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា និងបញ្ជាក់អំពីសិទ្ធិមានមេធាវីការពារខ្លួន ។ ក្នុងករណីនេះ ព្រះរាជអាជ្ញាត្រូវធ្វើការប្រគល់ចុងដីកាកោះឲ្យជនជាប់ចោទដោយព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសលើដើមដីកាអំពីកាលបរិច្ឆេទ និងទីកន្លែងនៃការប្រគល់ ព្រមទាំងឲ្យជនជាប់ចោទចុះហត្ថលេខានៅលើដើមដីកានោះផងដែរ ។ ការប្រគល់ដីកាកោះហៅដល់ជនជាប់ចោទអាចធ្វើឡើងដោយព្រះរាជអាជ្ញាផ្ទាល់ និងអាចធ្វើបានតាមរយៈមធ្យោបាយផ្សេងៗដែលមានចែងដោយក្រមព្រហ្មទណ្ឌជាអាទិ៍ តាមរយៈអាជ្ញាសាលា ក្រឡាបញ្ជី អាជ្ញាធរពន្ធធនាគារ ។ល។ ចំពោះរយៈពេលនៃការបញ្ជូនដីកាកោះវិញនោះ ព្រះរាជអាជ្ញាត្រូវគោរពតាមវិធានរយៈពេលស្របតាមទីកន្លែងរស់នៅជាក់ស្តែងរបស់ជនជាប់ចោទដែលច្បាប់បានកំណត់[១១៧] ។

ព្រះរាជអាជ្ញាក៏មានតួនាទីក្នុងការកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ឬ ជនរងគ្រោះ និងអ្នកពាក់ព័ន្ធ (សាក្សី អ្នកជំនាញ អ្នកបកប្រែ និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី) តាមរយៈដីកាកោះហៅមកកាន់សវនាការដែលជាការមានសារៈសំខាន់ណាស់ចំពោះសក្ខីកម្មនៃរឿងក្តី និងដំណើរការជំនុំជម្រះ ។ ការកោះហៅជនរងគ្រោះត្រូវធ្វើឡើង កាលណាជនរងគ្រោះមិនបានធ្វើការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ។ ដីកាកោះហៅជនខាងលើនេះ ព្រះរាជអាជ្ញាត្រូវមាននិទ្ទេសដូចជា អត្តសញ្ញាណ លំនៅឋាន ឈ្មោះជនជាប់ចោទ បទល្មើសដែលចោទប្រកាន់ តុលាការដែលត្រូវជំនុំជម្រះ ទីកន្លែង កាលបរិច្ឆេទ ពេលវេលានៃសវនាការ និងហត្ថលេខារបស់ព្រះរាជអាជ្ញា ព្រមទាំងបញ្ជាក់អំពីឋានៈនៃជនខាងលើ ។ នីតិវិធីនៃការប្រគល់ដីកាកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ឬជនរងគ្រោះ ឬអ្នកពាក់ព័ន្ធត្រូវធ្វើឡើងដូចគ្នាទៅនឹងការប្រគល់ដីកាកោះហៅដល់ជនជាប់ចោទដែរ[១១៨] ។

---

[១១៧] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៤៧៥ ។

[១១៨] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៤៧៥, ៤៧៦, ៤៧៧ ។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានឆ្លងកាត់តាមការសិក្សាស្រាវជ្រាវតាមរយៈបទបញ្ញត្តិច្បាប់ និងឯកសារផ្សេងៗទាក់ទងជាមួយនឹង **អង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត** ដែលផ្តោតសំខាន់លើខ្លឹមសារប្រវត្តិអង្គការអយ្យការក្របខណ្ឌព្រះរាជអាជ្ញា រចនាសម្ព័ន្ធ និងគោលការណ៍នៃអង្គការអយ្យការ, មុខងារ និងតួនាទីរបស់តំណាងអយ្យការ និងអង្គការអយ្យការនៅអមសាលាដំបូងរាជធានី-ខេត្តដែលជាស្នូលដ៏សំខាន់ក្នុងការសិក្សាស្វែងយល់លំអិតលើប្រធានបទទាំងមូល ។ មានលក្ខខណ្ឌជាច្រើន ដែលតម្រូវឲ្យតំណាងអយ្យការត្រូវតែគោរពតាមបទបញ្ញត្តិជាចាំបាច់ចំពោះចំណាត់ការលើបណ្តឹងរបស់ខ្លួនគឺរវាងការចោទប្រកាន់ និងការតម្កល់រឿងទុកឥតចាត់ការគឺជាជម្រើសមួយដែលតំណាងអយ្យការត្រូវថ្លឹងថ្លែងឲ្យបានម៉ត់ចត់ជាទីបំផុតនៅមុនពេលធ្វើសេចក្តីសម្រេច ។ ជារួមការអនុវត្តតួនាទី សិទ្ធិអំណាចរបស់តំណាងអយ្យការត្រូវបានគោរពតាមបទបញ្ញត្តិច្បាប់យ៉ាងខ្ជាប់ខ្ជួន ទើបបានជាការអនុវត្តមុខងារជាក់ស្តែងបង្ហាញនូវភាពស៊ីសង្វាក់គ្នាជាមួយច្បាប់ដែលមានចែងជាធរមាន ។ ព្រះរាជ-អាជ្ញាជាផ្នែកមួយដ៏សំខាន់ក្នុងការជួយសម្រួលបញ្ហាខាងនីតិវិធី ការចោទប្រកាន់តាមរយៈការបញ្ជូនរឿងទៅចៅក្រមដើម្បីជម្រះផ្ទាល់តាមនីតិវិធី ការបញ្ជូនទៅជម្រះផ្ទាល់ និងការបង្ហាញខ្លួនភ្លាមសម្រាប់បទមជ្ឈិមដែលត្រូវបានអនុញ្ញាត ។ ម្យ៉ាងវិញទៀត តំណាងអយ្យការជាតួអង្គដ៏សំខាន់ ក្នុងការការពារសណ្តាប់ធ្នាប់សាធារណៈព្រមទាំងដើរតួក្នុងនាមជាម្ចាស់នៃបណ្តឹងអាជ្ញា ក្នុងគោលបំណងបម្រើនូវផលប្រយោជន៍សង្គម ការពារផលប្រយោជន៍ទូទៅ ។ ដូចនេះ តំណាងអយ្យការត្រូវបំពេញការងារដោយមានឆន្ទៈ មានទំនួលខុសត្រូវ និងមានមនសិកាខ្ពស់ដើម្បីស្វែងរកយុត្តិធម៌ជូនសង្គមជាតិ ។

ជាទីបញ្ចប់ ការសិក្សាស្រាវជ្រាវរបស់ក្រុមយើងខ្ញុំ ទៅលើគម្រោងការសរសេរសារណាបញ្ចប់ការសិក្សានេះ បានស្តែងចេញនូវលទ្ធផលនៃការស្វែងយល់បន្ថែមជាមួយនឹងកម្រងឯកសារផ្សេងៗដែលបានទទួលចំណេះដឹងផ្ទាល់ពីបណ្ណាល័យ សាស្ត្រាចារ្យណែនាំ ដែលឆ្លុះបញ្ចាំងពីការរកឃើញនូវចំណុចខ្វះចន្លោះ ឬ ចំណេះដឹងថ្មីដែលធ្វើឲ្យយើងខ្ញុំបានស្វែងយល់កាន់តែច្បាស់ ។ ក្រុមសិក្សាស្រាវជ្រាវយើងខ្ញុំសង្ឃឹមយ៉ាងថា ប្រសិនបើអ្នកអនុវត្តច្បាប់ទាំងអស់គ្នាចូលរួមចំណែកសាមគ្គីបម្រើសង្គមតាមរយៈការផ្តល់ភាពយុត្តិធម៌ មានឆន្ទៈដោះស្រាយបញ្ហាប្រកបដោយមនសិការនោះពិតជាអាចដោះស្រាយបានរាល់នូវឧបសគ្គទាំងឡាយបានជាក់ជាមិនខាន នៅពេលនោះភាពអយុត្តិធម៌នឹងត្រូវបានកាត់បន្ថយ ហើយនឹងធ្វើឲ្យទំនុកចិត្តរបស់ប្រជាជនលើវិស័យយុត្តិធម៌កាន់តែមានភាពល្អប្រសើរឡើងវិញ ។

# អនុសាសន៍

ដើម្បីចូលរួមចំណែកក្នុងការធ្វើសេចក្តីសម្រេចចិត្តឲ្យបានល្អប្រសើរប្រកបទៅដោយភាពយុត្តិធម៌ ក្រុមស្រាវជ្រាវ សូមជូននូវយោបល់ខ្លះៗចំពោះការបំពេញការងាររបស់តំណាងអយ្យការដូចខាងក្រោមៈ

ក. នៅគ្រប់ពេលដែលធ្វើចំណាត់ការសំណុំរឿងព្រហ្មទណ្ឌ តំណាងអយ្យការគប្បីធ្វើការស៊ើបអង្កេតផ្ទាល់ដល់ទីកន្លែងកើតហេតុភ្លាមៗ ប្រមូលភស្តុតាងឲ្យបានគ្រប់គ្រាន់មុននិងធ្វើដីការ សន្និដ្ឋានបញ្ជូនរឿងឲ្យចៅក្រមស៊ើបសួរ ព្រោះជាក់ស្តែងតំណាងអយ្យការពុំសូវបានចុះស៊ើបអង្កេតផ្ទាល់ពេលរឿងហេតុកើតឡើងភ្លាមៗនោះទេ ដោយលោកច្រើនប្រមូលភស្តុតាង ឬឲ្យមន្ត្រីនរគបាលយុត្តិធម៌ជាអ្នកដែលចុះដល់ទីកន្លែងកើតហេតុ

ខ. តំណាងអយ្យការត្រូវប្រកាន់ភ្ជាប់នូវគោលការណ៍ការពារផលប្រយោជន៍សង្គម

គ. តំណាងអយ្យការគួរពង្រឹងទំនាក់ទំនងល្អជាមួយយុត្តាធិការស៊ើបសួរ នគរបាលយុត្តិធម៌ ឬមន្ត្រីសាធារណៈ ដទៃទៀតដែលពាក់ព័ន្ធលើការអនុវត្តមុខងាររបស់ខ្លួន

ឃ. ត្រូវបំពេញមុខងារដោយផ្អែកលើគោលការណ៍សុចរិតភាព និងភាពស្មោះត្រង់

ង. គ្រប់សេចក្តីសម្រេចផ្អែកលើបទបញ្ញត្តិដែលមានចែងក្នុងច្បាប់ជាធរមាន និងគួរគប្បីបញ្ជាក់សំអាងហេតុត្រឹមត្រូវដើម្បីធ្វើការចោទប្រកាន់ ឬ សេចក្តីសម្រេចណាមួយ ដើម្បីធានាថាភាគីនៃរឿងក្តីដែលខ្លួនកំពុងធ្វើចំណាត់ការនឹងទទួលបានភាពយុត្តិធម៌ និងទទួលយកនូវការអនុវត្តនោះ ។

# ឯកសារយោង

## I. លិខិតបទដ្ឋានគតិយុត្ត

១. រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ មហាសន្និបាតជាតិលើកទី៣ អនុម័តកាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៥, ប្រកាសជាផ្លូវការ នៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ ។

២. ក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨ ។

៣. រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានព្រះមហាក្សត្រឡាយព្រះហស្ថលេខាលើព្រះរាជក្រម ប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ។

៤. ច្បាប់ស្តីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ , មាត្រា ២៦ ។

៥. ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ប្រកាសឲ្យប្រើនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

៦. ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ប្រកាសឲ្យប្រើនាថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ។

៧. ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ។

៨. ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ។

## II. ព្រះរាជក្រឹត្យ

១. ព្រះរាជក្រឹត្យស្តីពីការដាក់ឲ្យដំណើរការសាលាឧទ្ធរណ៍តំបន់ នស/រកត/០២២០/១៩៨ ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ២០២០។

២. ព្រះរាជក្រឹត្យ ត្រាស់បង្គាប់តម្លើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ២០២១ នៃក្របខណ្ឌព្រះរាជអាជ្ញា ដល់ព្រះរាជអាជ្ញា ៣០រូប នស/រកត/០៥២២/៥០៣ ចុះថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០២២។

៣. ព្រះរាជក្រឹត្យ ត្រាស់បង្គាប់តែងតាំងចៅក្រមកម្មសិក្សា ព្រះរាជអាជ្ញាកម្មសិក្សា ចំនួន៥៦នាក់ឲ្យទៅបម្រើការងារនៅតាមសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្ត នស/រកត/០៦២២/៦៩២ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២២។

III. **ព្រះរាជក្រម**

១. ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ប្រកាសឲ្យប្រើតាម ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ។

IV. **សេចក្តីព្រាងច្បាប់**

១. សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឯកសារសំរាប់ប្រជុំលើកទី ១ (ថ្ងៃទី ០៩ ខែមករា ឆ្នាំ ២០១៤) របស់គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។

V. **សៀវភៅ**

១. អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី៨ ស្តីពីការបង្ការបទឧក្រិដ្ឋ និងការគ្រប់គ្រងជនល្មើស នាទីក្រុងហាវ៉ាណានៃប្រទេសគុយបា, សៀវភៅ គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា, ថ្ងៃទី ២៧ ខែសីហា ដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩០, ចំនុចទី ១៣ ។

២. រៀបរៀងដោយលោកសាស្ត្រាចារ្យ កុយ នាម និង លោកសាស្ត្រាចារ្យ ឡុងបញ្ញារុធ, សៀវភៅ អយ្យការ ប្រវត្តិ និងការសិក្សាប្រៀបធៀប បោះពុម្ពឆ្នាំ ២០០៦ ។

៣. រៀបរៀងដោយ Dr.Wilhelm Treiber/ Andrea Behm/ Hout Sotheary, សៀវភៅ ការពិចារណាពិស្តារផ្នែកគតិយុត្តិ ប្រព័ន្ធតុលាការ នៃវិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ ។

VI. **អត្ថបទ**

១. រៀបរៀងដោយ Evan Gottesman, Cambodia after the Khmer Rouge 2003, ជំពូកទី១១ អំពីច្បាប់ សិទ្ធិមនុស្ស និងរឿងក្តីត្រកូលយេន ។

២. រៀបរៀងដោយលោក សេង ឈុនលី, អត្ថបទពត៌មានយល់ដឹងផ្នែកច្បាប់៖ សាលាជម្រះក្តី ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ ។

៣. រៀបរៀងដោយលោក ថន យូសៀង និងកញ្ញា សាវី លីសា នៃក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ អត្ថបទពត៌មានយល់ដឹងផ្នែកច្បាប់៖ បណ្តឹងអាជ្ញា ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ ។

៤. រៀបរៀងដោយលោកមេធាវី ម៉េង វណ្ណី និងលោក ឡេង ពុទ្ធិតារា ជំនួយការមេធាវី និងជាសមាជិកក្រុមការងារនៃក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ អត្ថបទពត៌មានយល់ដឹងផ្នែកច្បាប់៖ គោលការណ៍នៃការចោទប្រកាន់ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ ។

៥. រៀបរៀងដោយលោក សូ ឥស្សរៈ, អត្ថបទ៖ មូលហេតុដែលតុលាការសម្រេចតម្កល់រឿងទុកឥតចាត់ការ ថ្ងៃទី១០ ខែ មេសា ឆ្នាំ២០២២ ។

៦. រៀបរៀងដោយលោកមេធាវី ទៀង វុទ្ធា, អត្ថបទ៖ មូលដ្ឋានចោទប្រកាន់សម្រាប់ព្រះរាជអាជ្ញាក្នុងរឿងព្រហ្មទណ្ឌ ។

៧. រៀបរៀងដោយលោកសាស្ត្រាចារ្យ កុយ នាម, អត្ថបទ៖ សិក្សាប្រៀបធៀបអំពីតុលាការកំពូល ។

VII. **ប្រសាសន៍ដកស្រង់**

១. ប្រសាសន៍របស់ឯកឧត្តម ផូវ សំភី អគ្គនាយកនៃអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌ នៃក្រសួងយុត្តិធម៌ ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី ក្រមនីតិវិធីព្រហ្មទណ្ឌ កាលពីខែមករា ឆ្នាំ២០០៨ នៅ ទូរទស្សន៍ជាតិកម្ពុជា (ទទក) ។

២. ប្រសាសន៍របស់អ្នកនាំពាក្យក្រសួងយុត្តិធម៌ លោក ជិន ម៉ាលីន កាលពីខែកក្កដា ថ្ងៃទី៧ ឆ្នាំ២០១៩ តាមរយៈអាស៊ីសេរី (RFA) ។

# ឧបសម្ព័ន្ធ

| ល.រ | **បញ្ជីឧបសម្ព័ន្ធ** |
|---|---|
| ០១ | ព្រះរាជក្រម ស្តីពីការប្រកាសឲ្យប្រើ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤ |
| ០២ | ព្រះរាជក្រឹត្យ ស្តីពីការដាក់ឲ្យសំណើរការសាលាឧទ្ធរណ៍តំបន់ ឆ្នាំ២០២០ |
| ០៣ | ព្រះរាជក្រឹត្យ ស្តីពីការត្រាស់បង្គាប់តែងតាំងចៅក្រមកម្មសិក្សា និងព្រះរាជអាជ្ញារង កម្មសិក្សា ឆ្នាំ២០២២ |
| ០៤ | ព្រះរាជក្រឹត្យ ស្តីពីការតម្លើងឋានន្តរស័ក្តិ និងថ្នាក់ ប្រចាំឆ្នាំ២០២១ |
| ០៥ | គំរូពាក្យបណ្តឹង (អំពីបទល្មើសឧក្រិដ្ឋមនុស្សឃាតកម្មគិតទុកជាមុន) |
| ០៦ | គំរូពាក្យបណ្តឹង (អំពីបទល្មើសសម្លាប់មនុស្ស និងបង្ករបួសស្នាមដោយចេតនា) |
| ០៧ | កំណត់ហេតុស្តីពីការឃាត់ខ្លួន |
| ០៨ | ដីកាបញ្ជាឲ្យចូលខ្លួន |
| ០៩ | ដីកាបង្គាប់ឲ្យឆែកឆេរលំនៅឋាន និងរុករកវត្ថុតាង |
| ១០ | ដីកាតំកល់រឿងទុកឥតចាត់ការ |
| ១១ | ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ |
| ១២ | ដីកាបង្គាប់ឲ្យនាំខ្លួន |
| ១៣ | ដីកាបង្គាប់ឲ្យឃុំខ្លួន |
| ១៤ | ដីកាសម្រេចមិនឃុំខ្លួនជាបណ្តោះអាសន្ន |
| ១៥ | ដីកាបង្គាប់ឲ្យចាប់ខ្លួន |
| ១៦ | ដីកាបង្គាប់ឲ្យដោះលែង |
| ១៧ | ដីកាលើកលែងចោទប្រកាន់ |
| ១៨ | ដីកាកោះហៅជនជាប់ចោទឲ្យចូលសវនាការ |
| ១៩ | ដីកាសន្និដ្ឋានស្ថាពរ ។ |

**ឧបសម្ព័ន្ធ ១**

# ព្រះរាជក្រម

## យើង

នស/រកម/០៧១៤/០១៥

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រតនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៥ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របតាមនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ១៤៩/០០៣/២០១៤ កបធ.ច ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE

ឲ្យប្រើដោយព្រះរាជក្រមលេខ ០៩ ន.ស.៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តដែលផ្ទុយពីនេះ ត្រូវទុកជានិរាករណ៍ ហើយត្រូវជំនួសដោយច្បាប់នេះ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ចរស.១៤០៧.៨១៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ហត្ថលេខា**

**អង្គ វង្សវឌ្ឍានា**

លេខ: ៩០៤ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ឧបសម្ព័ន្ធ ២**

# ព្រះរាជក្រឹត្យ

នស/រកត/០២២០/ ១៩៤

## ស្ដីពី

## ការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់

## យើង

## ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១..**

ត្រូវបានដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ចំនួនបីដូចខាងក្រោម៖

-សាលាឧទ្ធរណ៍ព្រះសីហនុ

-សាលាឧទ្ធរណ៍បាត់ដំបង

-សាលាឧទ្ធរណ៍ត្បូងឃ្មុំ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

សាលាឧទ្ធរណ៍តំបន់ទាំងបីនេះ ចាប់ផ្តើមដំណើរការពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២០ នេះតទៅ។

នៅអមសាលាឧទ្ធរណ៍តំបន់នីមួយៗ មានមហាអយ្យការមួយ ស្របតាមបទប្បញ្ញត្តិដូចមានចែងនៅក្នុងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងច្បាប់ជាធរមានពាក់ព័ន្ធដទៃផ្សេងទៀត។

**មាត្រា ២.-**

សាលាឧទ្ធរណ៍ព្រះសីហនុ មានទីតាំងស្ថិតនៅក្នុងខេត្តព្រះសីហនុ និងមានសមត្ថកិច្ចជំនុំជម្រះរឿងក្តីដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីដែលគ្របដណ្តប់លើខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តកំពត និងខេត្តកែប លើកលែងតែរឿងក្តីទាំងឡាយដែលច្បាប់ប្រគល់សមត្ថកិច្ចទៅឱ្យតុលាការផ្សេងទៀត។

សាលាឧទ្ធរណ៍បាត់ដំបង មានទីតាំងស្ថិតនៅក្នុងខេត្តបាត់ដំបង និងមានសមត្ថកិច្ចជំនុំជម្រះរឿងក្តីដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីដែលគ្របដណ្តប់លើខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប លើកលែងតែរឿងក្តីទាំងឡាយដែលច្បាប់ប្រគល់សមត្ថកិច្ចទៅឱ្យតុលាការផ្សេងទៀត។

សាលាឧទ្ធរណ៍ត្បូងឃ្មុំ មានទីតាំងស្ថិតនៅក្នុងខេត្តត្បូងឃ្មុំ និងមានសមត្ថកិច្ចជំនុំជម្រះរឿងក្តីដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីដែលគ្របដណ្តប់លើខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី លើកលែងតែរឿងក្តីទាំងឡាយដែលច្បាប់ប្រគល់សមត្ថកិច្ចទៅឱ្យតុលាការផ្សេងទៀត។

សាលាឧទ្ធរណ៍ភ្នំពេញ មានសមត្ថកិច្ចជំនុំជម្រះរឿងក្តីដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីដែលគ្របដណ្តប់លើរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តព្រៃវែង និងខេត្តស្វាយរៀង ព្រមទាំងរឿងក្តីដែលមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍តំបន់ លើកលែងតែរឿងក្តីទាំងឡាយដែលច្បាប់ប្រគល់សមត្ថកិច្ចទៅឱ្យតុលាការផ្សេងទៀត។

**មាត្រា ៣.-**

សាលាឧទ្ធរណ៍តំបន់ មានសមត្ថកិច្ចជំនុំជម្រះរឿងក្តីដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២០ តទៅ។

ចំពោះសំណុំរឿងទាំងឡាយដែលស្ថិតក្រោមសមត្ថកិច្ចដែនដីរបស់សាលាឧទ្ធរណ៍តំបន់ ប៉ុន្តែដែលសាលាឧទ្ធរណ៍ភ្នំពេញបានទទួលជាសមត្ថកិច្ច នៅមុនថ្ងៃទី១ ខែមេសា ឆ្នាំ២០២០ ត្រូវកំណត់ជាសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីតាក់ការបន្ត ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

វិធានដែលមានចែងក្នុងមាត្រានេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់។

**មាត្រា ៤.-**

ក្នុងករណីដែលសាលាឧទ្ធរណ៍តំបន់ណាមួយមិនអាចដំណើរការបាន សមត្ថកិច្ចជំនុំជម្រះរឿងក្តីដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍តំបន់នោះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍ភ្នំពេញ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចេញប្រកាស ដើម្បីកំណត់អំពីការមិនអាចដំណើរការបាននៃសាលាឧទ្ធរណ៍

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

តំបន់នេះ។

ប្រសិនបើសាលាឧទ្ធរណ៍តំបន់ណាមួយមានចៅក្រមមិនគ្រប់គ្រាន់ ឬខ្វះខាតចៅក្រមដោយមូលហេតុវិសមិតភាពជាអាទិ៍ ប្រធានសាលាឧទ្ធរណ៍តំបន់នោះត្រូវស្នើសុំទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីចាត់តាំងចៅក្រមពីសាលាឧទ្ធរណ៍ផ្សេងទៀតមកបំពេញសមាសភាព។

**មាត្រា ៥.-**

ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៩/១៣០០ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៩/១៣០១ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៩/១៣០២ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៩/១៣០៣ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ និងលិខិតបទដ្ឋានគតិយុត្តដែលផ្ទុយពីនេះ ត្រូវទុកជានិរាករណ៍ ហើយត្រូវជំនួសដោយព្រះរាជក្រឹត្យនេះ។

**មាត្រា ៦.-**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣៧.២០០២.២០៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០២០*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

# ព្រះរាជក្រឹត្យ

នស/រកត/០៦២២/៦៧៤

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានតួមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១០៥/០១៩ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥ ស្ដីពីការបង្កើតរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានការយល់ព្រមពីសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

## ត្រាស់បង្គាប់

**មាត្រា១:** តែងតាំងចៅក្រមកម្មសិក្សា ព្រះរាជអាជ្ញារងកម្មសិក្សា ចំនួន ៥៦នាក់ ឱ្យទៅបម្រើការងារនៅតាមសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្ត:

**ក**-សាលាដំបូងខេត្តកណ្ដាល

| | | |
|---|---|---|
| ១ - | លោកស្រី **ហុង ម៉ារីណិច** | ជាចៅក្រមកម្មសិក្សា |
| ២ - | លោក **ថៃ ថេង** | ជាចៅក្រមកម្មសិក្សា |
| ៣ - | លោក **ម៉ាង ណុាល** | ជាចៅក្រមកម្មសិក្សា |

**ខ**-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តកំពង់ចាម

១ - លោកស្រី **សុខុម សុជាតា** ជាចៅក្រមកម្មសិក្សា

២ - លោក **រិទ្ធ ចន្ទ្រះ** ជាចៅក្រមកម្មសិក្សា

៣ - លោក **តារា ចិន្ត** ជាព្រះរាជអាជ្ញារងកម្មសិក្សា

៤ - លោក **ឈឹម បញ្ញា** ជាព្រះរាជអាជ្ញារងកម្មសិក្សា

**គ**-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ

១ - លោក **កែច បញ្ញា** ជាចៅក្រមកម្មសិក្សា

២ - លោក **សួន ធី** ជាព្រះរាជអាជ្ញារងកម្មសិក្សា

**ឃ**-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តបាត់ដំបង

១ - លោក **គា សីហា** ជាចៅក្រមកម្មសិក្សា

២ - លោកស្រី **នេត្រ សុផារិន** ជាព្រះរាជអាជ្ញារងកម្មសិក្សា

៣ - លោកស្រី **ហ៊ិន ស៊ីចហ្វិច** ជាព្រះរាជអាជ្ញារងកម្មសិក្សា

**ង**-សាលាដំបូងខេត្តព្រះសីហនុ

១ - លោក **ផាត់ ពៅ** ជាចៅក្រមកម្មសិក្សា

**ច**-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តសៀមរាប

១ - លោក **ហេង លៀងត្រី** ជាចៅក្រមកម្មសិក្សា

២ - លោក **តុប ផាណារិន** ជាចៅក្រមកម្មសិក្សា

៣ - លោក **យិន មុនីរិទ្ធ** ជាព្រះរាជអាជ្ញារងកម្មសិក្សា

៤ - លោក **ឌិល សុវណ្ណារិទ្ធ** ជាព្រះរាជអាជ្ញារងកម្មសិក្សា

**ឆ**-សាលាដំបូងខេត្តឧត្តរមានជ័យ

១ - លោកស្រី **ជួន វិបុលរដ្ឋា** ជាចៅក្រមកម្មសិក្សា

**ជ**-សាលាដំបូងខេត្តបន្ទាយមានជ័យ

១ - លោក **សាយ ម៉ិនលាយ** ជាចៅក្រមកម្មសិក្សា

**ឈ**-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តកំពត

១ - លោក **ឆេព តារ៉ុង** ជាចៅក្រមកម្មសិក្សា

២ - លោក **ម៉ុង ហ៊ុយ** ជាព្រះរាជអាជ្ញារងកម្មសិក្សា

**ញ**-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ

១ - លោកស្រី **នាង ស៊ីរីណា** ជាចៅក្រមកម្មសិក្សា

២ - លោក **ប៉ែន ភាម៉ច់ភា** ជាចៅក្រមកម្មសិក្សា

៣ - លោក **ខាន់ សុខា** ជាចៅក្រមកម្មសិក្សា

៤ - លោក **រ៉ា លីសួន** ជាព្រះរាជអាជ្ញារងកម្មសិក្សា

**ដ**-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តតាកែវ

១ - លោក **តូច មានរិទ្ធិ** ជាចៅក្រមកម្មសិក្សា

២ - លោកស្រី **ខៃ រចនា** ជាចៅក្រមកម្មសិក្សា

៣ - លោក **សេង ជីវប៉ាច** ជាចៅក្រមកម្មសិក្សា

៤ - លោកស្រី **សៃ សុជាតា** ជាចៅក្រមកម្មសិក្សា

៥ - លោក **ស៊ឹម ជុំសុខហេង** ជាព្រះរាជអាជ្ញារងកម្មសិក្សា

**ឋ**-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង

| | |
|---|---|
| ១ - លោក **ស៊ីន ច័ន្ទសុគ័ន្ធ** | ជាចៅក្រមកម្មសិក្សា |
| ២ - លោកស្រី **ប៊ី សុវណ្ណារ័ត្ន** | ជាចៅក្រមកម្មសិក្សា |
| ៣ - លោកស្រី **ឆឹម គានីតា** | ជាចៅក្រមកម្មសិក្សា |
| ៤ - លោក **ឆេង ណាត** | ជាចៅក្រមកម្មសិក្សា |
| ៥ - លោក **យ៉ាន ច័ន្ទក្រុន** | ជាព្រះរាជអាជ្ញារងកម្មសិក្សា |

**ឌ**-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តកំពង់ធំ

| | |
|---|---|
| ១ - លោកស្រី **សួន សុខខេន** | ជាចៅក្រមកម្មសិក្សា |
| ២ - លោក **សេន ខេន** | ជាព្រះរាជអាជ្ញារងកម្មសិក្សា |

**ឍ**-សាលាដំបូងខេត្តពោធិ៍សាត់

| | |
|---|---|
| ១ - លោក **គង់ វ៉ាចន** | ជាចៅក្រមកម្មសិក្សា |

**ណ**-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តព្រៃវែង

| | |
|---|---|
| ១ - លោកស្រី **មៀច សិទ្ធិភាព្យដេស៊ីភាព្យ** | ជាចៅក្រមកម្មសិក្សា |
| ២ - លោក **ខឹម សេនហឿន** | ជាចៅក្រមកម្មសិក្សា |
| ៣ - លោក **អៀ ហាំងឡេង** | ជាចៅក្រមកម្មសិក្សា |
| ៤ - លោក **សេង ចាន់ចន្ទ្រា** | ជាចៅក្រមកម្មសិក្សា |
| ៥ - លោកស្រី **យេល គន្ធជា** | ជាចៅក្រមកម្មសិក្សា |
| ៦ - លោក **ហែម គ្រីស្នា** | ជាចៅក្រមកម្មសិក្សា |
| ៧ - លោក **ថេង វ៉ាណាត** | ជាព្រះរាជអាជ្ញារងកម្មសិក្សា |
| ៨ - លោក **តាន់ ម៉ិនលី** | ជាព្រះរាជអាជ្ញារងកម្មសិក្សា |
| ៩ - លោក **យន់ សំណាង** | ជាព្រះរាជអាជ្ញារងកម្មសិក្សា |

**ត**-សាលាដំបូងខេត្តក្រចេះ

| | |
|---|---|
| ១ - លោក **ចេង សល់សម្បត្តិ** | ជាចៅក្រមកម្មសិក្សា |

**ថ**-សាលាដំបូង-អយ្យការអមសាលាដំបូងខេត្តស្វាយរៀង

| | |
|---|---|
| ១ - លោក **សុខ សុគន្ធរ័ត្ន** | ជាចៅក្រមកម្មសិក្សា |
| ២ - លោក **ឡាយ ជុនហេង** | ជាព្រះរាជអាជ្ញារងកម្មសិក្សា |

**ទ**-សាលាដំបូងខេត្តស្ទឹងត្រែង

| | |
|---|---|
| ១ - លោក **ហួយ សេរីចន្ទ្រនពិសិដ្ឋ** | ជាចៅក្រមកម្មសិក្សា |
| ២ - លោក **លាង គុនម៉េង** | ជាចៅក្រមកម្មសិក្សា |

**ធ**-សាលាដំបូងខេត្តកោះកុង

| | |
|---|---|
| ១ - លោក **ហុក ច័ន្ទឆាយា** | ជាចៅក្រមកម្មសិក្សា |

**ន**-សាលាដំបូងខេត្តរតនគិរី

| | |
|---|---|
| ១ - លោក **ឡេង បញ្ញារិទ្ធ** | ជាចៅក្រមកម្មសិក្សា |

**ប**-សាលាដំបូងខេត្តមណ្ឌលគិរី

| | |
|---|---|
| ១ - លោក **ចាន់ដា វ៉ាចឡូ** | ជាចៅក្រមកម្មសិក្សា |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៨-សាលាដំបូងខេត្តព្រះវិហារ

១ - លោក **ឌឹម សុជាថា** ជាចៅក្រមកម្មសិក្សា

**មាត្រា២:** អស់លោក លោកស្រី ដែលមានឈ្មោះក្នុងមាត្រា១ ខាងលើនេះ ត្រូវបំពេញកម្មសិក្សារយៈពេល១២ (ដប់ពីរ)ខែ ចាប់ពីថ្ងៃតែងតាំង។

**មាត្រា៣:** ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ការប. ៤៤០៦.៦៩៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០២២*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

**ឧបសម្ព័ន្ធ ៤**

# ព្រះរាជក្រឹត្យ

នស/រកត/០៥២២/៥០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៣៩៨ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពីឋានន្តរស័ក្តិ និងថ្នាក់សម្រាប់ចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧១៨/៧៣៧ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីលក្ខខណ្ឌនៃការដំឡើងថ្នាក់ ឬឋានន្តរស័ក្តិសម្រាប់ចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានយោបល់យល់ព្រមពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២

## ត្រាស់បង្គាប់

**មាត្រា ១:** តម្លើងឋានន្តរស័ក្តិ និងថ្នាក់ ប្រចាំឆ្នាំ២០២១ នៃក្របខណ្ឌព្រះរាជអាជ្ញា ដល់ព្រះរាជអាជ្ញា ៣០រូប:

ក- តម្លើងថ្នាក់ ក្នុងឋានន្តរស័ក្តិវរៈព្រះរាជអាជ្ញា:

| | | |
|---|---|---|
| ១-លោក **គង់ ច័ន្ទខេមរិទ្ធ** | ពីវរៈព្រះរាជអាជ្ញា ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ២-លោក **ហាក់ ហ៊ាន់** | ពីវរៈព្រះរាជអាជ្ញា ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ៣-លោក **គង់ សំសារ៉ែត** | ពីវរៈព្រះរាជអាជ្ញា ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ៤-លោក **អ៊ិច រី** | ពីវរៈព្រះរាជអាជ្ញា ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |
| ៥-លោក **ស៊ិត ចណ្ណា:** | ពីវរៈព្រះរាជអាជ្ញា ថ្នាក់លេខ ៤ | មកជាថ្នាក់លេខ ៣ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

Scanned with CamScanner

ខ- តម្លើងឋានន្តរស័ក្តិ និងថ្នាក់ ពីឋានន្តរស័ក្តិអនុព្រះរាជអាជ្ញា មកជាឋានន្តរស័ក្តិវរៈព្រះរាជអាជ្ញា:

| | | |
|---|---|---|
| ១-លោក **ឈឺន សុផុន** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ១ | មកជាវរៈព្រះរាជអាជ្ញា ថ្នាក់លេខ ៤ |

គ- តម្លើងថ្នាក់ ក្នុងឋានន្តរស័ក្តិអនុព្រះរាជអាជ្ញា:

| | | |
|---|---|---|
| ១-លោក **ឆាយ ហុខ** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ២-លោក **សេខ ហៀខ** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៣-លោក **សេខ រិទ្ធី** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៤-លោកស្រី **ស៊ុ សុជាតា** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៥-លោក **សាន សុតៈ** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៦-លោកស្រី **សាត ធីតា** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៧-លោក **ថេខ សំណាខ** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៨-លោក **ជួខ សារ៉ែន** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ៩-លោក **យុន តឿន** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ១០-លោក **លី តារ៉ា** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ១១-លោក **ខា ដែនណា** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ១២-លោក **លឹម ប៊ុនហេខ** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ១៣-លោកស្រី **តី ស៊ីថខ** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ១៤-លោក **ឌុត ឌីនីត** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ១៥-លោក **រ៉ា បុរ៉ាន់ឌី** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ១៦-លោក **ខឡូ សាខ៉ាត** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ១៧-លោកស្រី **ឆាម ច័ន្ទពីលីការ** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ១៨-លោក **ផាន់ រតនា** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ១៩-លោក **ប៉ុក តារា** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ២ | មកជាថ្នាក់លេខ ១ |
| ២០-លោក **អ៊ុន សុវណ្ណធានី** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ២១-លោក **ចក សម្បត្តិ** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ២២-លោក **គង់ រតនា** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ២៣-លោក **ហាក់ សៀកលីម** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |
| ២៤-លោក **ឡៀខ ពណ្ណរាយ** | ពីអនុព្រះរាជអាជ្ញា ថ្នាក់លេខ ៣ | មកជាថ្នាក់លេខ ២ |

**មាត្រា ២**: ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នសរកត.០៥២២.៥០៦

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០២២*

**ឧបសម្ព័ន្ធ ៥**

## អំពីបទល្មើសឧក្រិដ្ឋមនុស្សឃាតគិតទុកជាមុន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## <u>ពាក្យបណ្តឹង</u>

ខ្ញុំបាទឈ្មោះ.................... អាយុ.............ឆ្នាំ ជាតិ.................. មុខរបរ..................
ទីលំនៅភូមិ.................. ឃុំ.................. ស្រុក.................. ខេត្ត.................. ។

សូមគោរពជូន

លោកប្រធានសមាគមសិទ្ធិមនុស្ស......................

កម្មវត្ថុ : សុំប្តឹងពីឈ្មោះ.................. ភេទ......... អាយុ......... ឆ្នាំ សញ្ជាតិ..................
មុខរបរធ្វើអាជីវកម្មព្រៃឈើ ពីបទ " ប៉ុនប៉ងសម្លាប់រូបខ្ញុំ " ។

ត្បិតក្រោយពីកាសែត.................. លេខ............ ចេញផ្សាយថ្ងៃទី...... ខែ.......... ឆ្នាំ.......... រួចមកមានសាក្សីឈ្មោះ.................. និងឈ្មោះ.................. បានប្រាប់ខ្ញុំបាទថា ឈ្មោះខាងលើមានបំណងចង់សម្លាប់រូបខ្ញុំ ដោយសារតែខ្ញុំបាទសរសេរអត្ថបទកាសែតមួយច្បាប់ ក្រោមចំណងជើងថា "........................" ដែលមានការប៉ះពាល់ដល់សកម្មភាពប្រកបអាជីវកម្មព្រៃឈើខុសច្បាប់របស់ពួកគេ បញ្ហានេះខ្ញុំបាទមានការព្រួយបារម្ភណាស់ ព្រោះឈ្មោះខាងលើកំពុងស្វែងរកខ្ញុំ ដើម្បីសម្លាប់ចោល ។

ហេតុនេះ សូមលោកប្រធានសមាគមមេត្តាជួយធ្វើអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ច ដើម្បីមានវិធានការទប់ស្កាត់ អំពើប៉ុនប៉ងរបស់ជនល្មើសដោយអនុគ្រោះផង ។

សូមលោកប្រធានមេត្តាទទួលនូវការគោរពយ៉ាងជ្រាលជ្រៅអំពីខ្ញុំបាទ ។

ភ្នំពេញ, ថ្ងៃទី......... ខែ.............. ឆ្នាំ..........

ហត្ថលេខា ឬស្នាមមេដៃស្តាំអ្នកប្តឹង

ឈ្មោះ..................

www.elibrarycambodia.org

ឧបសម្ព័ន្ធ ៦

## អំពើបទល្មើសសម្លាប់មនុស្ស និងបង្ករបួសស្នាមដោយចេតនា

### ពាក្យបណ្តឹង

ខ្ញុំបាទឈ្មោះ......................អាយុ..............ឆ្នាំ ជាតិ..................មុខរបរ..................
ទីលំនៅភូមិ......................ឃុំ..................ស្រុក..................ខេត្ត.................. ។

**សូមគោរពជូន**

**ព្រះរាជអាជ្ញាអមតុលាការខេត្ត......................**

**កម្មវត្ថុ** : សុំប្តឹងពីអ្នកបើករថយន្តម្នាក់មិនទាន់ស្គាល់ឈ្មោះ ។

សេចក្តីដូចមានក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមជំរាបជូនព្រះរាជអាជ្ញាជ្រាបនូវដំណើររឿងហេតុដូចខាងក្រោមនេះ ៖

កាលពីថ្ងៃទី..........ខែ..............ឆ្នាំ............វេលាម៉ោង៥ល្ងាច នៅពេលដែលខ្ញុំបាទកំពុងជិះម៉ូតូមួយគ្រឿងម៉ាក..............តាមបណ្តោយផ្លូវជាតិលេខ..............ឆ្ពោះទៅទិសខាងលិច មកដល់ត្រង់ចំណុចផ្លូវបត់ចូលដេប៉ូខ្សាច់ ភូមិ............ឃុំ............ស្រុក............ខេត្ត............ ស្រាប់តែមានរថយន្តបែនពណ៌លឿងម៉ាក..............មួយគ្រឿង ពាក់ផ្លាកលេខ..............បើកមកពីក្រោយស្របទិសតែមួយ ហើយបរជែងម៉ូតូរបស់ខ្ញុំបាទដោយកាច់ចង្កូតមកខាងស្តាំ កាត់មុខម៉ូតូរបស់ខ្ញុំបាទៗពិតស្មានថា រថយន្តនោះវែបស្តាំ ខ្ញុំបាទក៏ងាកមកឆ្វេង ការពិតរថយន្តគ្រាន់តែងាកស្តាំកាត់មុខម៉ូតូ ដើម្បីយកស្ថានភាពហើយក៏បត់ឆ្វេង ។ មួយរំពេចភ្លាមនោះ ខ្ញុំបាទក៏ងាកចង្កូតម៉ូតូបញ្ជៀសកុំអោយបុករថយន្ត តែរថយន្តចេះតែកៀនខ្ញុំរហូតដល់ផ្លូវចុះពីថ្នល់ជាតិ ហើយក៏ទង្គិចដៃម៉ូតូរបស់ខ្ញុំបាទ បណ្តាលឱ្យម៉ូតូដួល ហើយបណ្តាលអោយកូនរបស់ខ្ញុំបាទធ្លាក់ស្លាប់នៅនឹងកន្លែងកើតហេតុ ។

បន្ទាប់ពីគ្រោះថ្នាក់កើតឡើង អ្នកបើកបរបានឈប់រថយន្ត ហើយរត់គេចខ្លួនទៅទិសខាងត្បូង ដោយមានអោបកូនម្នាក់អាយុប្រហាក់ប្រហែលនឹងកូនរបស់ខ្ញុំបាទដែរ ពេលកំពុងរត់ ខ្ញុំបាទបានបក់ដៃហៅជននោះអោយត្រឡប់ក្រោយវិញ ដើម្បីជួយយកកូនរបស់ខ្ញុំបាទទៅមន្ទីរពេទ្យ ប៉ុន្តែគេគ្រាន់តែងាកមកក្រោយ តែមិនត្រឡប់ក្រោយចេះតែរត់ដោយមិនរវល់អ្វីទាំងអស់ ។

ក្រោយពេលកើតហេតុ នគរបាលចរាចរស្រុកបានធ្វើកិច្ចការនោះ ដោយនាំយកទាំងរថយន្ត និងម៉ូតូរបស់ខ្ញុំបាទទៅទុកនៅផ្នែកចរាចរស្រុក ដើម្បីធ្វើការដោះស្រាយដោយកំណត់ពេលផ្សះផ្សាចំនួន

www.budnst.gov.kh www.elibraryofcambodia.org

**ឧបសម្ព័ន្ធ ៧**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ស្នងការដ្ឋាននគរបាលខេត្តកោះកុង**
**ការិយាល័យកណ្ដាលនគរបាលយុត្តិធម៌**
**ការិយាល័យព្រហ្មទណ្ឌកំរិតធ្ងន់**

**កំណត់ហេតុឃាត់ខ្លួនឈ្មោះ**.......................................................................

ឆ្នាំ.......................................................ខែ....................ថ្ងៃទី............វេលាម៉ោង.........
យើង.......................................................ឋានៈ...............................ជាមន្ត្រីនគរបាលយុត្តិធម៌ជំនួយ
ដោយលោក.........................................................................................ជាលេខាកត់ត្រានិង
ចូលរួមដោយលោក.................................................................................................

១. .........................................................................................................

២. .........................................................................................................

យោងតាម...........................................................................................................

.....................................................................................................................

បានឃាត់ខ្លួនឈ្មោះ.......................................ភេទ..........ឈ្មោះហៅក្រៅ..........................................
ជនជាតិ...................សញ្ជាតិ.....................ថ្ងៃខែឆ្នាំកំណើត.......................................................
ស្រុកកំណើត៖......................................................................................................
ទីលំនៅបច្ចុប្បន្ន៖.................................................................................................
អត្តសញ្ញាណប័ណ្ណលេខ៖...................................ចុះថ្ងៃទី........................ផ្ដល់ដោយ..........................
លិខិតឆ្លងដែនលេខ៖..........................................ចុះថ្ងៃទី.......................ផ្ដល់ដោយ..........................
ទូរស័ព្ទលេខ៖......................................................................................................
មុខរបរ៖.......................................................កំរិតវប្បធម៌...............................................
ឪពុកឈ្មោះ៖.......................................(ស្ល-រ) ម្ដាយឈ្មោះ៖.............................................(ស្ល-រ)
ប្ដី ឬ ប្រពន្ធឈ្មោះ៖..................................(ស្ល-រ) មានកូន........................នាក់ ស្រី..........................នាក់
មូលហេតុនៃការឃាត់ខ្លួន៖......................................................................................

**ឧបសម្ព័ន្ធ ៨**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអមសាលាដំបូង
រាជធានីភ្នំពេញ

លេខ: ...១១០.....អ.យ.ប

## ដីកាបញ្ជាឲ្យចូលខ្លួន[1]

**យើង ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញមាត្រា៣៧[2], ៩៥[3] និងមាត្រា ១១៥[4] នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ: នស/រកម/០៨០៧/០២៤/ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

-បានឃើញរបាយការណ៍ សុំដីកាបញ្ជាឲ្យចូលខ្លួនលេខ១១៨ដ.អ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៨ របស់ **នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ។**

**បញ្ជា**

*ឲ្យកម្លាំងមានសមត្ថកិច្ចនាំខ្លួនបុគ្គល៖*

នាម-គោត្តនាម ភេទ អាយុ ឆ្នាំ មុខរបរ

ជនជាតិ ទីលំនៅបច្ចុប្បន្ន សង្កាត់ ក្រុង

ខេត្ត

មកបង្ហាញខ្លួននៅ នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ

ឲ្យបានមុនថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨ ដើម្បីសាកសួរពីដំណើររឿង: ឃាតកម្ម កាលពីថ្ងៃ២៦ ខែមករា ឆ្នាំ២០១៨ នៅចំណុចផ្ទះជួល ក្នុងភូមិផ្សារតាកោ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ ។

ថ្ងៃ.អាទិត្យ....១រោច..ខែចេត្រ ឆ្នាំរកា នព្វស័ក,ព.ស២៥៦១
រាជធានីភ្នំពេញ,ថ្ងៃទី ០១ ខែមេសា ឆ្នាំ២០១៨
ជ.ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញារង

---

[1] ដីកានេះអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កំលាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះឲ្យចូលបង្ហាញខ្លួនបាន

[2] អំណាចរបស់ព្រះរាជអាជ្ញា

[3] ករណីស៊ើបអង្កេតជាក់ស្តែង

[4] ករណីស៊ើបអង្កេតបឋម

CS Scanned with CamScanner

**ឧបសម្ព័ន្ធ ៩**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តក្រចេះ

មន្ទីរស៊ើបសួរ:
លេខ: ២៤៣៨ ព.ស ២០១៩

## ដីកាបង្គាប់ឲ្យឆែកឆេរលំនៅដ្ឋាន
## ឬ រុករកវត្ថុតាង

យើង ប្រធានសាលាដំបូងខេត្តក្រចេះ ។

-បានឃើញ មាត្រា១១៣ និងមាត្រាពាក់ព័ន្ធ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

-បានឃើញ ពាក្យសុំដីកាឆែកឆេរលំនៅដ្ឋាន ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ របស់គណៈកម្មការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ ។

-យល់ឃើញថា: ដើម្បីទប់ស្កាត់បង្ក្រាបបទល្មើសធនធានធម្មជាតិ និងបម្រើឲ្យការស៊ើបអង្កេត ចាប់យកវត្ថុតាងនៃបទល្មើស គប្បីតុលាការចេញដីកាឆែកឆេរលំនៅដ្ឋានរបស់ឈ្មោះ , ភេទ អាយុ ឆ្នាំ ជនជាតិ មានទីលំនៅ : ។

## ហេតុដូច្នេះ សម្រេច

១- បង្គាប់មក គណៈកម្មការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ ដើម្បីចាត់ចែងចុះឆែកឆេរលំនៅដ្ឋាន ឬរុករកវត្ថុតាង របស់ឈ្មោះ ដែលស្ថិតនៅភូមិ ។

ថ្ងៃសុក្រ ១រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
ក្រចេះ, ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩
**ប្រធានសាលាដំបូង**

**ឧបសម្ព័ន្ធ ១០**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តព្រៃវែង

សំណុំរឿងព្រហ្មទណ្ឌ លេខ: ២៥៨
ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១
លេខ: ៩៤ អក/ពវ២១

## <u>ដីកាតម្កល់រឿងទុកឥតចាត់ការ</u>

យើង ព្រះរាជអាជ្ញា អមសាលាដំបូងខេត្តព្រៃវែង។

-បានឃើញ មាត្រា៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

-បានឃើញ ពាក្យបណ្ដឹង របស់ឈ្មោះ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ២៥៨ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តព្រៃវែង និង សំណុំលិខិតភ្ជាប់មកជាមួយព្រមទាំងភស្តុតាងនានា។

-បានឃើញ ពាក្យការពារក្ដី របស់លោកមេធាវី ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ ។

-បានឃើញ ពាក្យបណ្ដឹង (រដ្ឋប្បវេណី) របស់ឈ្មោះ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ ។

### ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា :

១- អវត្តមានបទល្មើស

☑ ១.១ អវត្តមានបទល្មើស

២- ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

☐ ២.១ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

៣- មូលហេតុគតិយុត្ត

☐ ៣.១ ការដកពាក្យបណ្ដឹង

☐ ៣.២ ការលើកលែងទោសជាទូទៅ

☐ ៣.៣ មរណភាពជនល្មើស

☐ ៣.៤ ផុតអាជ្ញាយុកាល

☐ ៣.៥ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

☐ ៣.៦ អាជ្ញាអស់ជំនុំ

☐ ៣.៧ ការសម្របសម្រួលជាមយរង

□៣.៩ អភ័យឯកសិទ្ធិ

□៣.១០ អនិយ័តភាពនៃនីតិវិធី

□៣.១១ ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស [១]

៤- ការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍

□៤.១ ការស្វែងរកមិនបានផល

□៤.២ ការបោះបង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង[២]

□៤.៣ ស្ថានភាពវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវ

□៤.៤ ការខកខានរបស់ដើមបណ្តឹង

□៤.៥ អាកប្បកិរិយារបស់ជនរងគ្រោះ

□៤.៦ ជនរងគ្រោះមិនចាប់អារម្មណ៍នឹងបទល្មើស

□៤.៧ និយ័តកម្មដោយឯកឯង [៣]

□៤.៨ ព្យសនកម្ម ឬការរំខានតិចតួចបង្កដោយបទល្មើស

៥- នីតិវិធីជាជំរើសអនុវត្តដោយព្រះរាជអាជ្ញា

□៥.១ ការជួសជុលការខូះខាតដោយ/ ដល់នីតិវិធី

□៥.២ សន្ធានកម្ម[៤]

□៥.៣ អធិបញ្ញាដល់ការព្យាបាល

□៥.៤ ជនរងគ្រោះ/ដើមបណ្តឹងបោះបង់ការបណ្តឹងតាមការស្នើរសុំរបស់ព្រះរាជអាជ្ញា

□៥.៥ និយ័តកម្មតាមសំនើរបស់ព្រះរាជអាជ្ញា

□៥.៦ ការរំលឹកពីអត្ថបទច្បាប់ /កាព្រមាន[៥]

□៥.៧ ការកំណត់ទិសដៅចំពោះរចនាសម្ព័ន្ធនៃសុខភាព នៃសង្គម ឬនៃវិជ្ជាជីវៈ

□៥.៨ ការសំរុះសំរួលព្រហ្មទណ្ឌ[៦]

៦- នីតិវិធីជម្រើសអនុវត្តដោយអាជ្ញាធរផ្សេងៗទៀត :

□៦.១ ការចោទប្រកាន់ ឬទណ្ឌកម្មផ្សេងៗទៀតមិនមែនព្រហ្មទណ្ឌ

៧- ជនល្មើសមិនត្រូវបានស្គាល់

□៧.១ ជនល្មើសមិនត្រូវបានស្គាល់

៨- ជំនួយការអប់រំ:

---

[១] ដូចជាមូលហេតុវិកលចរិត ការការពារស្របច្បាប់ ការបង្ខំ ស្ថានភាពចាំបាច់ អនីតិជនអាយុក្រោម ១៨ ឆ្នាំ

[២] ដើមបណ្តឹងឈប់ប្តឹង

[៣] សកម្មភាពដែលជនល្មើសបានបញ្ឈប់បទល្មើស និងស្តារស្ថានភាពឡើងវិញ

[៤]ករណីចែងដោយច្បាប់

៨.១ ការផ្តល់ជំនួយការអប់រំជំនួសការចោទប្រកាន់

**ការសង្ខេបរឿងក្តី**:

កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២១ ឈ្មោះ និងឈ្មោះ បានទៅទិញស្រាបៀរហ្គេនបឺត មកផឹកជុំគ្នានៅការដ្ឋានចុងប៉មខាងមុខសាលាខេត្តព្រៃវែង ដែលមានទីតាំងនៅភូមិ០១ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង ដោយឈ្មោះ ចេញប្រាក់ចំនួន ២០,០០០ (ពីរម៉ឺន) រៀល និងអ្នកផឹកផឹជាមួយគ្នាម្នាក់ចេញប្រាក់ចំនួន ១,០០០ (មួយពាន់) រៀល ចំណែកឈ្មោះ ចូលប្រាក់ចំនួន ៥,០០០ (ប្រាំពាន់) រៀល ។ បន្ទាប់ពីទិញបានហើយ ឈ្មោះ និងឈ្មោះ បានចែកកំប៉ុងគ្នាផឹករហូតទាល់តែជិតអស់ ពេលដែលនៅសល់មួយកំប៉ុង (កំប៉ុងដែលត្រូវរង្វាន់) ឈ្មោះ បានយកកំប៉ុងនោះហុចឱ្យគេគ្រប់គ្នា ក៏ប៉ុន្តែគ្នាអ្នកណាយក ក៏បានគាស់ផឹកខ្លួនឯង ស្រាប់តែឃើញរូបឡានទៅក្នុងកំប៉ុងនោះ ។ បន្ទាប់ពីត្រូវរង្វាន់ឡាន ឈ្មោះ បានឱ្យលុយទៅ មិត្តរួមការងារម្នាក់ ចំនួន ១០០ (មួយរយ) ដុល្លារអាមេរិក ចំណែកឈ្មោះ សុំទាមទារចំណែក ១ ភាគ ៣ នៃរង្វាន់ឡាននោះ ។

ក្រោយធ្វើការបែងចែកចំណែករង្វាន់ឡានមិនត្រូវគ្នា ឈ្មោះ ក៏បានដាក់ពាក្យបណ្តឹងប្តឹងឈ្មោះពីបទ ៖ " កំហែងយក, គំរាមកំហែងហែកកេរ្តិ៍ និង បទបរិហាបង្កាច់កេរ្តិ៍ " ។

**ឃ្លានឃើញ ៖**

-បានឃើញ កំណត់ហេតុសួរចម្លើយជនសង្ស័យឈ្មោះ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ បានឆ្លើយថា ៖ ខ្ញុំបាទសូមបដិសេធចំពោះការចោទប្រកាន់របស់ឈ្មោះ ដែលប្តឹងរូបខ្ញុំពីបទ ៖ ១. កំហែងយក, ២. គំរាមកំហែងហែកកេរ្តិ៍ និង បទប្តឹងបរិហាបង្កាច់កេរ្តិ៍ មូលហេតុដោយសារតែរូបខ្ញុំមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ។ ម្យ៉ាងទៀត រូបខ្ញុំបានចូលលុយគ្នាជាមួយឈ្មោះ ដោយរូបខ្ញុំចេញលុយចំនួន ៥,០០០ (ប្រាំពាន់) រៀល និង ក្រវិលកំប៉ុងដែលត្រូវរង្វាន់ចំនួន ០២ កំប៉ុង ចំណែកឈ្មោះ គាត់និយាយថាគាត់ចេញលុយចំនួន ២០,០០០ (ពីរម៉ឺន) រៀល ដោយគាត់បានយកលុយ និង ក្រវិលកំប៉ុង របស់ខ្ញុំ ទៅទិញស្រាបៀរហ្គេន បឺត ដោយរូបខ្ញុំមិនបានទៅទិញស្រាជាមួយគាត់នោះទេ ។

នៅពេលដែលឈ្មោះ ទិញស្រាហ្គេនបឺត បានហើយ ខ្ញុំឃើញមានស្រាបៀរចំនួន ១២ កំប៉ុង ហើយពួកខ្ញុំក៏បានផឹកស្រាជាមួយគ្នា ដោយមានឈ្មោះ ៖ ១. , ២. , ៣. , ៤. , ពីរនាក់ទៀតមិនស្គាល់ឈ្មោះ និង រូបខ្ញុំ ។ ចំពោះអ្នកទាំងប្រាំនាក់ ខ្ញុំមិនបានដឹងថាគាត់បានទទួលលុយ ឬ មិនបានទទួលលុយពីឈ្មោះ នោះទេ ចំណែករូបខ្ញុំដំបូងឡើយគាត់ថាឱ្យ ៥០០ (ប្រាំរយ) ដុល្លារអាមេរិក ប៉ុន្តែរូបខ្ញុំសូមទាមទារចំណែករបស់ខ្ញុំ តែមួយភាគបី នៃតម្លៃរង្វាន់ទាំងមូល តែប៉ុណ្ណោះ ។ សូមបញ្ជាក់ថារូបខ្ញុំបានផឹកថាអស់តែ ០២ កំប៉ុងតែប៉ុណ្ណោះ ចំណែកឈ្មោះ ខ្ញុំមិនដឹងថាគាត់ផឹកអស់ប៉ុន្មាននោះទេ។ អ្នកដែលគាស់កំប៉ុងត្រូវរង្វាន់ គឺឈ្មោះ ប៉ុន្តែខ្ញុំមិនដឹងថាត្រូវរង្វាន់កំប៉ុងទីប៉ុន្មាននោះទេ ។

ខ្ញុំមិនបានទៅជំរិតទារប្រាក់ពីឈ្មោះ នោះទេ គឺខ្ញុំគ្រាន់ទាមទារចំណែករបស់ខ្ញុំ មួយភាគបី នៃតម្លៃរង្វាន់ទាំងមូល តែប៉ុណ្ណោះ ហើយក៏មិនបានគំរាមថាទៅប្តឹងគ្រប់ស្ថាប័ន ដូចដែលគាត់ចោទរូបខ្ញុំផងដែរ ។ លើសពីនេះ ខ្ញុំក៏មិនបានគំរាមកំហែងបើកកកាយអ្វីដែលមិនមែនជាការពិត ឬ ទំលាក់កំហុសធ្វើឱ្យប៉ះពាល់កិត្តិយស សេចក្តី

បំណាងឱ្យគាត់ជាប់គុកទេ គឺខ្ញុំប្តឹងឱ្យតុលាការរកយុត្តិធម៌ខ្ញុំតែប៉ុណ្ណោះ ។ ខ្ញុំបាទសូមសំណូមមកតំណាងអយ្យការមេត្តាកុំចោទប្រកាន់លើរូបខ្ញុំបាទ និង ស្នើសុំតម្កល់រឿងទុកឥតចាត់ការ ។

**យល់ឃើញថា ៖**

១-យល់ឃើញថា កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២១ ដើមបណ្តឹងឈ្មោះ និងជនសង្ស័យឈ្មោះ ពិតជាបានទៅទិញស្រាបៀរហ្គេន បីត មកផឹកជុំគ្នានៅការដ្ឋានចុងប៉មខាងមុខសាលាខេត្តព្រៃវែង ទីតាំងនៅភូមិ០១ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង ដោយដើមបណ្តឹងឈ្មោះ ចេញប្រាក់ចំនួន ២០,០០០ (ពីរម៉ឺន) រៀល និងអ្នកផឹកដីជាមួយគ្នាម្នាក់ ចេញប្រាក់ចំនួន ១,០០០ (មួយពាន់) រៀល ចំណែកជនសង្ស័យឈ្មោះ ហន រិទ្ធី បានចូលប្រាក់ចំនួន ៥,០០០ (ប្រាំពាន់) រៀល ពិតប្រាកដមែន ។ ប៉ុន្តែដោយសារតែដើមបណ្តឹង និង ជនសង្ស័យ ធ្វើការបែងចែកចំណែករង្វាន់ឡានមិនត្រូវគ្នា ដើមបណ្តឹងក៏បានដាក់ពាក្យបណ្តឹងប្តឹងជនសង្ស័យឈ្មោះ មកអយ្យការអមសាលាដំបូង ខេត្តព្រៃវែង ដើម្បីចាត់ការតាមច្បាប់ ។

២-យល់ឃើញថា ក្រោយពេលដើមបណ្តឹងឈ្មោះ បានដាក់ពាក្យបណ្តឹងមកអយ្យការអមសាលាដំបូងខេត្តព្រៃវែង រួចមក តំណាងអយ្យការបានធ្វើការកោះហៅដើមបណ្តឹង ដែលមានអាសយដ្ឋានដូចមាននៅក្នុងពាក្យបណ្តឹង ដើម្បីមកឆ្លើយបំភ្លឺចំពោះករណីបណ្តឹងរបស់ខ្លួន ដែលបានប្តឹងជនសង្ស័យឈ្មោះ ។ ប៉ុន្តែសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលស្វាយជ្រុំ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ បានបញ្ជាក់ថា ៖ ឈ្មោះ ពុំមាននៅក្នុងមូលដ្ឋានភូមិក្បាលខ្វែក ឃុំស្វាយជ្រុំ ស្រុកមេសាង ខេត្តព្រៃវែង នេះទេ (ដូចមាននៅខាងក្រោយដីកាកោះឈ្មោះ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១) ។

៣-យល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ មិនបានដាក់ភស្តុតាងជាឯកសារ ឬ សាក្សីណាមួយ ដើម្បីអាចឱ្យតំណាងអយ្យការជឿជាក់បានថា ជនសង្ស័យឈ្មោះ ពិតជាបានប្រព្រឹត្តអំពើ កំហែងយក គំរាមកំហែងហែកកេរ្តិ៍ និង បទបរិហាបង្អាច់កេរ្តិ៍ នោះទេ ។

៤-យល់ឃើញថា ជនសង្ស័យឈ្មោះ បានដាក់ពាក្យបណ្តឹងប្តឹងឈ្មោះ ទៅតុលាការរដ្ឋប្បវេណី ដើម្បីឱ្យតុលាការធ្វើការបែងចែកចំណែករង្វាន់រថយន្ត ហើយតុលាការរដ្ឋប្បវេណី កំពុងតែចាត់ការតាមនីតិវិធីច្បាប់ ហើយមិនទាន់បានសេចក្តីសម្រេចណាមួយ នៅឡើយនោះទេ ។

៥-យល់ឃើញថា មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសទោសព្រហ្មទណ្ឌបាន បន្ថែមពីនេះទៀត ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត ស្របតាមបញ្ញត្តិនៃមាត្រា ០៣ កថាខណ្ឌទី០១ និង មាត្រា ០៤ កថាខណ្ឌទី០១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ។

៦-យល់ឃើញថា គ្មានពិរុទ្ធភាព និង ភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ ពីបទ ៖ **កំហែងយក**, **គំរាមកំហែងហែកកេរ្តិ៍** និង **បទបរិហាបង្អាច់កេរ្តិ៍** ប្រព្រឹត្តនៅការដ្ឋានចុងប៉មខាងមុខសាលាខេត្តព្រៃវែង ស្ថិតនៅភូមិ០១ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិនៃមាត្រា មាត្រា ៣៦៣, មាត្រា ៣៧២ និង មាត្រា ៣១១ នៃក្រមព្រហ្ម

## ហេតុដូច្នេះ សម្រេច

១-តម្កល់សំណុំរឿងព្រហ្មទណ្ឌ លេខ ២៥៨ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ ទុកឥតចាត់ការស្របតាម បញ្ញត្តិមាត្រា ៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ តទៅ។

២-បង្គាប់ឱ្យក្រឡាបញ្ជី ជូនដំណឹងដល់ភាគីបណ្តឹង ដើម្បីបើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

ថ្ងៃពុ.ធ.១១រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ពស.២៥៦៥

ធ្វើនៅព្រៃវែង, ថ្ងៃទី០៤ខែសីហា ឆ្នាំ២០២១

ព្រះរាជអាជ្ញា

**ឧបសម្ព័ន្ធ ១១**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ ៣៥៦៥
ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៩
លេខ: 2404 អ.យ.ម

## ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

យើង ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ:របាយការណ៍សំយោគលេខ: ០៨៨/១៩ រ.ប.ក ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៩ របស់អធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-បានឃើញ:ដីកាចាត់តាំងតំណាងអយ្យការលេខ: ៣៦៣១ អ.យ.ក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

ក្រោយពីបានពិនិត្យឯកសារខាងលើ

ឃើញមានតម្រុយសន្មតថា៖

១-នាមត្រកូល និងនាមខ្លួន: ភេទ ប្រុស អាយុ ៣២ ឆ្នាំ, ជនជាតិខ្មែរ, ទីកន្លែងកំណើត នៅភូមិតាង៉ួន សង្កាត់កាកប ខណ្ឌដង្កោ រាជធានីភ្នំពេញ, កាន់សាសនាព្រះពុទ្ធ, មានទីលំនៅមុនពេលឃាត់ខ្លួននៅភូមិតាង៉ួន២ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ, មុខរបរ អ្នកយកកាស៊ុកង, ប្រពន្ធឈ្មោះ - - មានកូនចំនួន ២នាក់, ឪពុកឈ្មោះ - - -, ម្តាយឈ្មោះ - -, កំរិតវប្បធម៌ ថ្នាក់ទី៧ថ្មី, ទោសពីមុនគ្មាន ។ (ឃាត់ខ្លួន)

បានប្រព្រឹត្តអំពើដូចតទៅ៖ កាលពីថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៩ វេលាម៉ោង ១៦ និង ០០នាទី ជនសង្ស័យឈ្មោះ បានធ្វើសកម្មភាពលួចយកកាបូបរបស់ជនរងគ្រោះឈ្មោះ ភេទស្រី អាយុ ៣៥ ឆ្នាំ ដែលមានដាក់: ១-លុយខ្មែរចំនួន ១៥០០០០០៛ (មួយលានប្រាំសែនរៀល),២- លុយដុល្លារ ៣៥០$ (បីរយហាសិបដុល្លារអាមេរិក) និង៣-អត្តសញ្ញាណសញ្ញាតិខ្មែរ ១សន្លឹក នៅតូបរបស់ជនរងគ្រោះលេខ៤៧ ក្នុងផ្សារតាំងកសាងចាស់ ភូមិចំការឪឡឹក១ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ហើយត្រូវអ្នកលក់ដូរក្បែរគ្នាឃើញ ក៏ស្រែកចោទ្បោ រួចក៏មានប្រជាពលរដ្ឋនៅតំបន់នោះនាំគ្នាតាមចាប់ និងធ្វើការឃាត់ខ្លួនជនសង្ស័យ ប្រគល់អោយសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលកាកាបទី១ តែម្តង ។

[1] សេចក្តីសង្ខេបអង្គហេតុ

អំពើប្រព្រឹត្តខាងលើ ជាបទល្មើសៈ លួច ប្រព្រឹត្តនៅចំណុចតូបលេខ៤៧ ក្នុងផ្សារតាំងកសាងចាស់ ភូមិចំការឪឡឹក១ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៩ តាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

-បានឃើញៈ មាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

ហេតុដូច្នេះសម្រេច

បើកការស៊ើបសួរលើអង្គហេតុខាងលើ និង ៖

☐ ដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ[2] ៖

-ឈ្មោះ កេទ ប្រុស អាយុ ៣២ ឆ្នាំ។ (ឃាត់ខ្លួន)

<u>ពីបទ</u>៖ លួច ប្រព្រឹត្តនៅចំណុចតូបលេខ៤៧ ក្នុងផ្សារតាំងកសាងចាស់ ភូមិចំការឪឡឹក១ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៩ តាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

☐ ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[3]៖.................................

☐ ដាក់ឲ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្ន[4] លើ

-ឈ្មោះ កេទ ប្រុស អាយុ ៣២ ឆ្នាំ។ (ឃាត់ខ្លួន)

ថ្ងៃ សុក្រ 12 កើត ខែជេស្ឋ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី 11 ខែ មិថុនា ឆ្នាំ ២០១៩

តំណាងអយ្យការ

ព្រះរាជអាជ្ញារង

[2] ឈ្មោះជនត្រូវចោទ

[3] ការតព្វកិច្ចណាមួយដែលបានចែងនៅក្នុងមាត្រា ២២៣

[4] មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្នដែលមានចែងនៅក្នុងមាត្រា ២០៥

**ឧបសម្ព័ន្ធ ១២**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ "ឃ១" ជាន់ទី៤

លេខ: 1300 "ឃ១" ច.ក.ខ

## ដីកាបង្គាប់ឲ្យនាំខ្លួន

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ មាត្រា ១៨៩ និងមាត្រាបន្តបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ៤៦៧០ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: ៣៨៨៥ អ.យ.ក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០ ដែលចោទប្រកាន់លើឈ្មោះ ភេទប្រុស អាយុ ឆ្នាំ សញ្ជាតិ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះ

-ពីបទ: **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍ដែលអាចជួញដូរបាន** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍ដែលអាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

-បានឃើញ ដីកាបង្គាប់ឲ្យចូលខ្លួន (លើកទី១) លេខ: ៤៧០ "ឃ១" ព្រ.ច ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាបង្គាប់ឲ្យចូលខ្លួន (លើកទី២) លេខ: ៥២៥ "ឃ១" ព្រ.ច ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

### យល់ឃើញថា:

-តាមដីកាបង្គាប់ឲ្យចូលខ្លួន (លើកទី១) លេខ: ៤៧០ "ឃ១" ព្រ.ច ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០ ។

-តាមដីកាបង្គាប់ឲ្យចូលខ្លួន (លើកទី២) លេខ: ៥២៥ "ឃ១" ព្រ.ច ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ជនត្រូវចោទពុំបានមកបង្ហាញខ្លួននៅចំពោះមុខតុលាការទាល់តែសោះ ហេតុដូច្នេះតុលាការគប្បីនាំខ្លួនជនត្រូវចោទឈ្មោះ មកបង្ហាញខ្លួននៅចំពោះមុខតុលាការ ។

-ដើម្បីធានាដល់ការស៊ើបសួរឲ្យបានពេញលេញគប្បីសម្រេចនាំខ្លួនឈ្មោះ ភេទប្រុស អាយុ ៥៥ឆ្នាំ សញ្ជាតិខ្មែរ មកចំពោះមុខចៅក្រមស៊ើបសួរដើម្បីបំភ្លឺការពិត ។

### ហេតុដូច្នេះសម្រេច

១-ឲ្យនាំខ្លួនឈ្មោះ ភេទ អាយុ ឆ្នាំ សញ្ជាតិ ដែលមានអត្តសញ្ញាណខាងលើនេះ ។

២-បង្គាប់មកកងកម្លាំងសាធារណៈឲ្យចាប់ និងនាំខ្លួនឈ្មោះខាងលើនេះមកប្រគល់ជូនសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមច្បាប់ ។

ថ្ងៃអង្គារ ១២កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ . ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០

**ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធ ១៣**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ជាន់ទី៨ បន្ទប់ "ល"

សាលាដំបូងរាជធានីភ្នំពេញ

មន្ទីរស៊ើបសួរ "ល"

លេខ ..5334.. "ល" ដ.ឃ.ខ

# ដីកាបង្គាប់ឱ្យឃុំខ្លួន

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

- បានឃើញ មាត្រា២០៦, ២១៩, ២២០, ២២១ និងមាត្រា២២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៥៤០០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩។
- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣៦៩៣ អ.យ.ក ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ សំណុំរឿងស៊ើបសួរលេខ ៣៦៥៩ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ ដែលទាក់ទងនឹង:

នាមត្រកូល និងនាមខ្លួន ភេទ អាយុ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅ

ឪពុកឈ្មោះ ម្តាយឈ្មោះ ប្រពន្ធឈ្មោះ

មានកូន ជាទីតិជន ទោសពីមុនគ្មាន។

-ឃាត់ខ្លួននៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៩

ជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ ឈ្មោះ ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៦ បទ ល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

- បានឃើញ ដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ .6057..... "ល" ដ.ព.ស ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩។

**បង្គាប់**

១-ឱ្យភ្នាក់ងារមានសមត្ថកិច្ចនៃកងកម្លាំងសាធារណៈធ្វើការនាំខ្លួនជនត្រូវចោទដែលមានឈ្មោះ ភេទ អាយុ ឆ្នាំ ទៅ **ពន្ធនាគាររាជធានីភ្នំពេញ** (PJ) ដោយអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់។

២-ឱ្យ **ប្រធានពន្ធនាគាររាជធានីភ្នំពេញ** (PJ) និងឃុំខ្លួនជននេះរហូតដល់មានបទបញ្ជាថ្មីសម្រេចផ្សេងពីនេះ។

៣-ឱ្យគ្រប់ភ្នាក់ងារនៃកងកម្លាំងសាធារណៈទាំងអស់សហការអនុវត្តឱ្យបានល្អនៅពេលដីកានេះត្រូវបានបង្ហាញក្នុងករណីចាំបាច់។

ថ្ងៃពុធ ១៤កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩

ចៅក្រមស៊ើបសួរ

**ឧបសម្ព័ន្ធ ១៤**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ: ៥.212...(ស.១) ដ.ក.ស

## ដីកាសម្រេចមិនឃុំខ្លួនជាបណ្ដោះអាសន្ន

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ជាក្រឡាបញ្ជី។

-បានឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ: នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

-បានឃើញ មាត្រា ២០៧ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ៤៦២៧ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ៣៣០៦ អ.យ.ន ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ កំណត់ហេតុសួរចម្លើយជនត្រូវចោទ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២០។

ក្រោយពីបានសួរចម្លើយជនត្រូវចោទ និងពិចារណាយ៉ាងត្រឹមត្រូវតាមច្បាប់រួចហើយ

### ហេតុដូច្នេះសម្រេច

១/.មិនឃុំខ្លួនឈ្មោះ ភេទ អាយុ ឆ្នាំ ជនជាតិ ទីកន្លែងកំណើតនៅ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ ផ្លូវលំ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ឪពុកឈ្មោះ ម្ដាយឈ្មោះ នៅលីវ ជាអនីតិជន ទោសពីមុខ៖គ្មាន។

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ ៖ លួចមានស្ថានទម្ងន់ទោស (ឆក់ទូរស័ព្ទដៃ) ប្រព្រឹត្តនៅចំណុចមុខផ្សារហេងលី ផ្លូវលេខ:២៧១ ភូមិបុរីកម្មករ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២០។ បទល្មើសព្រហ្មទណ្ឌមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២/.ដីកាសម្រេចនេះមានសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២០
ចៅក្រមស៊ើបសួរ

បានទទួលដំណឹងរួចហើយ
ថ្ងៃព្រហស្បតិ៍ ១២កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២០
តំណាងអយ្យការ

ក្រឡាបញ្ជី

ព្រះរាជអាជ្ញារង

ed with C

**ឧបសម្ព័ន្ធ ១៥**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**
លេខ...០៤.... អ.យ.យ

## ដីកាបង្គាប់ឲ្យចាប់ខ្លួន

យើង តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ មាត្រា ២៧ មាត្រា ១៩៦ មាត្រា ៤៩៦ និងមាត្រា ៤៩៧ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០-០៨-២០០៧។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៣២ (ច) ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៨៩ (ច) ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ សាលដីកាស្ថាពរលេខ ១៧ ក្រ៥.ប ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍។

-បានឃើញ ពាក្យសុំអនុវត្តសាលដីកាស្ថាពរ ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ របស់លោក មេធាវីតំណាងដោយអាណត្តិឲ្យ ។

ក្រោយពីបានពិនិត្យឃើញថា:

-នាមត្រកូល-នាមខ្លួន ភេទប្រុស អាយុ ឆ្នាំ ជនជាតិ មុខរបរ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ផ្លូវជាតិលេខ ក្រុមទី ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ។

ត្រូវចោទប្រកាន់ពីបទ: *បរិហារកេរ្តិ៍ជាសាធារណៈ និងញុះញង់ឲ្យមានការរើសអើង* ប្រព្រឹត្តនៅសារមន្ទីរជើងឯក សង្កាត់ជង្គោ ខណ្ឌជង្គោ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០០៨ តាមមាត្រា ៣០៥ មាត្រា ៤៩៤ និងមាត្រា ៤៩៦ នៃក្រមព្រហ្មទណ្ឌ ។

### យល់ឃើញថា

-តាមអំណាចសាលក្រម និងសាលដីកាស្ថាពរខាងលើបានចូលជាស្ថាពរ មានប្រសិទ្ធិភាពអនុវត្តហើយ ។

-ឈ្មោះ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨.០០០.០០០(ប្រាំបីលាន)រៀល ហើយសាលាឧទ្ធរណ៍បានសម្រេច ចំណាយសំណុំរឿងចេញពីបញ្ជីក្តីសាលាឧទ្ធរណ៍ តាមសាលដីកាស្ថាពរលេខ ១៧ ក្រ៥.ប ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ តែឈ្មោះ ពុំទាន់បានអនុវត្តទោសនៅឡើយ ។

### ហេតុដូច្នេះសម្រេច

១-ឲ្យចាប់ខ្លួនឈ្មោះ ដែលមានអត្តសញ្ញាណខាងលើនេះ តាមអំណាចសាលដីកាស្ថាពរលេខ ១៧ ក្រ៥.ប ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ របស់សាលាឧទ្ធរណ៍ ។

២-បង្គាប់មកកងកម្លាំងសាធារណៈឲ្យស្រាវជ្រាវកេចាប់ និងនាំខ្លួនទណ្ឌិតឈ្មោះ យកទៅអនុវត្តទោសនៅពន្ធនាគារនៃក្រសួងមហាផ្ទៃ ។

៣-គ្រប់ភ្នាក់ងារនៃកងកម្លាំងសាធារណៈទាំងអស់ត្រូវសហការអនុវត្តឲ្យមានប្រសិទ្ធភាពល្អ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥

**តំណាងអយ្យការ**

**ព្រះរាជអាជ្ញារង**

**ឧបសម្ព័ន្ធ ១៦**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

...អយ្យការអមតុលាការកំពូល

លេខ :...២៧/២០...មអក.......

## ដីកាបង្គាប់ឲ្យដោះលែង

អគ្គព្រះរាជអាជ្ញាតុលាការកំពូល

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៣៩៤ "I" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ របស់តុលាការកំពូលដែលបានសម្រេច៖

-បដិសេធសាលដីកាលេខ ៤៩ ក្រIII "ឃ" ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ។

-បង្គាប់ឲ្យដោះលែងឈ្មោះ ភេទ អាយុ ឆ្នាំ ជនជាតិ មុខរបរជា ដែលត្រូវបានឃុំខ្លួនជាបណ្ដោះអាសន្នតាមដីកាសម្រេចឲ្យឃុំខ្លួនជាបណ្ដោះអាសន្នលេខ ២៥៣៥"ម"ដពស ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ និងតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៣៨៤១ "ម" ដឃង ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ចេញពីមណ្ឌលឃុំខ្លួន ប្រសិនបើបុគ្គលឈ្មោះនេះមិនត្រូវបានឃុំខ្លួននៅក្នុងរឿងក្ដីផ្សេងទៀតនោះទេ។

### <u>ហេតុដូច្នេះបង្គាប់មក</u>

លោកប្រធានមណ្ឌលអប់រំកែប្រែ (PJ) ឲ្យដោះលែងឈ្មោះ ភេទ អាយុ ឆ្នាំ ជនជាតិ មុខរបរជា ដែលត្រូវបានឃុំខ្លួនជាបណ្ដោះអាសន្នតាមដីកាសម្រេចឲ្យឃុំខ្លួនជាបណ្ដោះអាសន្នលេខ ២៥៣៥"ម"ដពស ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ និងតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៣៨៤១ "ម" ដឃង ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ <u>ចេញពីមណ្ឌលឃុំខ្លួន</u> ប្រសិនបើបុគ្គលឈ្មោះនេះមិនត្រូវបានឃុំខ្លួននៅក្នុងរឿងក្ដីផ្សេងទៀតនោះទេ។

ថ្ងៃអង្គារ ១១កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០

អគ្គព្រះរាជអាជ្ញា

**ឧបសម្ព័ន្ធ ១៧**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់សើបសួរ "ម"

លេខៈ 28315 "ម" ដដ

# ដីកាលើកលែងចោទប្រកាន់

យើង អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ និងជាចៅក្រមស៊ើបសួរ ដោយមានលោកស្រី ជាក្រឡាបញ្ជី។

- បានឃើញ បញ្ញត្តិមាត្រា ២៤៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ១៨៤៦ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១។
- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៤២២ អ.យ.ផ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ សំណុំរឿងស៊ើបសួរលេខ ១៣៨៤ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១។
- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ២០៦០ អ.យ.ផ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលទាក់ទងនឹងជនត្រូវចោទដូចខាងក្រោម៖

ឈ្មោះ ហៅ ភេទ អាយុ ឆ្នាំ សញ្ជាតិ មុខរបរ ទីកន្លែងកំណើត ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ សង្កាត់ ខណ្ឌ នៅលើវ ឪពុកឈ្មោះ ម្តាយឈ្មោះ ជានីតិជន ទោសពីមុនគ្មាន ដែលត្រូវបានចោទប្រកាន់ពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្លូវ ១៣៨ កែងផ្លូវ ២៥៩ ស្ថិតនៅក្រុម ២៨ ភូមិ ១០ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ជាបទល្មើសព្រហ្មទណ្ឌ និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។ (ក្រៅឃុំ)

- ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំលេខ ២២៩៧ "ម" ដពស ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១។
- ដីកាបង្គាប់ឱ្យដោះលែងលេខ ៣២៧២ "ម" ដឃដ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១។

- ជនរងគ្រោះ ឈ្មោះ ភេទ អាយុ ឆ្នាំ សញ្ជាតិ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ផ្លូវ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

- មេធាវី ឈ្មោះ អត្តលេខ មេធាវី ឈ្មោះ មេធាវី ឈ្មោះ មេធាវី ឈ្មោះ អត្តលេខ មេធាវី ឈ្មោះ អត្តលេខ មេធាវី ឈ្មោះ និង មេធាវី ឈ្មោះ ជាសហមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ។
- មេធាវី ឈ្មោះ អត្តលេខ មេធាវី ឈ្មោះ និងមេធាវី ឈ្មោះ ជាសហមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ។

## សម្រេច

១. លើកលែងចោទប្រកាន់លើឈ្មោះ ហៅ ភេទ អាយុ ឆ្នាំ សញ្ជាតិ ដែលមានអត្តសញ្ញាណដូចខាងលើ ពីបទ **លួច មានស្ថានទម្ងន់ទោសដោយសារប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចផ្ទះ កែងផ្លូវ ស្ថិតនៅក្រុម ភូមិ សង្កាត់ , ខណ្ឌ ជាបទល្មើសព្រហ្មទណ្ឌ និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២. សម្រេចលើវត្ថុចាប់យ ដូចខាងក្រោម៖

២.១ ប្រគល់នូវទូរស័ព្ទ គ្រឿង ម៉ាក iPhone 12 pro max ពណ៌ទឹកមាស បែកអេក្រង់ (មិនប្រក្រតី) ឱ្យទៅម្ចាស់ដើមវិញ ឈ្មោះ ដូចមានក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៩០០ វវត ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

២.២ ប្រគល់នូវទូរស័ព្ទ១គ្រឿង ម៉ាក ពណ៌ខ្មៅ លេខ IMEI: 353959101077501 បែកអេក្រង់ (មិនប្រក្រតី) ឱ្យទៅម្ចាស់ដើមវិញ ឈ្មោះ ដូចមានក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៩០០ វវត ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

២.៣ រឹបអូសនូវកូនកាំបិតចុងស្រួច ដងពណ៌ខ្មៅ ចំនួន ១ដើម ដូចមានក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៩០៤ វវត ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ស្របតាមបញ្ញត្តិមាត្រា ១៦១ កថាខណ្ឌ ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ថ្ងៃ ចន្ទ ១២ រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០២១
ចៅក្រមជំនុំជម្រះ

បានឃើញ
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០២១
ជ.ព្រះរាជអាជ្ញា

ក្រឡាបញ្ជី

ព្រះរាជអាជ្ញារង

**ឧបសម្ព័ន្ធ ១៨**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

បន្ទប់"ឈ" ជាន់ទី៤

**អយ្យការអមសាលាដំបូង**
**រាជធានីភ្នំពេញ**

## ដីកាកោះហៅជនជាប់ចោទឲ្យចូលសវនាការ

យើង តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៣១២០ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៥

-បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជំរះលេខ ២៥៨៨ "ឆ"ដជ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានបញ្ជូនជនជាប់ចោទឈ្មោះ ភេទ , កើតថ្ងៃទី ខែ ឆ្នាំ ទៅតុលាការព្រហ្មទណ្ឌរាជធានីភ្នំពេញដើម្បីជំនុំជម្រៈ ពីបទៈ សមគំនិតក្នុងអំពើ ក្លែងបន្លំឯកសារសាធារណៈ , ប្រើប្រាស់ឯកសារសាធារណៈក្លែង និងញុះញង់បង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១២ និង១៣ ខែសីហា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២៩ , មាត្រា ៦២៩ មាត្រា ៦៣០ និងមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ ។

បង្គាប់មកឈ្មោះ ភេទ កើតថ្ងៃទី ខែ ឆ្នាំ សញ្ជាតិខ្មែរ តួនាទី កាន់លិខិតឆ្លងដែនលេខ មានទីលំនៅបច្ចុប្បន្ន ឲ្យចូលទៅកាន់សាលសវនាការបន្ទប់ទី២ ជាន់ទី១ នៃសាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី **២៥ ខែ វិច្ឆិកា ឆ្នាំ២០១៦** វេលាម៉ោង **០៨និង០០នាទីព្រឹក** ជាកំហិត ដើម្បីធ្វើការជំនុំជម្រៈ ក្នុងឋានៈជាជនជាប់ចោទ ។

សមាសភាពក្រុមប្រឹក្សាជំនុំជម្រៈ

លោក អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សាជំនុំជម្រៈ

លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាសមាជិក

លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាសមាជិក

តំណាងអយ្យការ

លោក តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

លោក ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦

**តំណាងអយ្យការ**

ព្រះរាជអាជ្ញារង

សិទ្ធិរបស់ជនជាប់ចោទមានដូចតទៅៈ

-សិទ្ធិទទួលដឹងឮពីការចោទប្រកាន់

-សិទ្ធិបង្ហាញភស្តុតាងនិងធ្វើសំណូមពរចុងក្រោយ

-សិទ្ធិប្តឹងជិតចិត្តចៅក្រមជំនុំជម្រៈ

-សិទ្ធិពឹងពាក់មេធាវី ឬទទួលបានមេធាវីការពារ

CS Scanned with CamScanner

**ឧបសម្ព័ន្ធ ១៩**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

********

**អយ្យការអម**

តុលាការខេត្ត-ក្រុង

.............................

**********

**ដីកាសន្និដ្ឋានស្ថាពរ(១)**

*********

លេខ.............................

យើង .................................................. តំណាងអយ្យការអមតុលាការខេត្ត-ក្រុង ..................................

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ...................... ថ្ងៃទី............... ខែ...................... ឆ្នាំ .................. ។

បានឃើញសំណុំរឿងស៊ើបសួរលេខ ....................... ចុះថ្ងៃទី .................... ខែ .................... ឆ្នាំ ..............

បានឃើញដីកាជូនរឿងមូលទៅពិនិត្យលេខ .............. ចុះថ្ងៃទី ................... ខែ ................... ឆ្នាំ .............

របស់ចៅក្រមស៊ើបអង្កេត ។

ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ឃើញថា: (២) ..................................................................................................

.............................................................................................................................................................

.............................................................................................................................................................

.............................................................................................................................................................

.............................................................................................................................................................

.............................................................................................................................................................

.............................................................................................................................................................

.............................................................................................................................................................

.............................................................................................................................................................

.............................................................................................................................................................

.............................................................................................................................................................

.............................................................................................................................................................

.............................................................................................................................................................

.............................................................................................................................................................

.............................................................................................................................................................

.............................................................................................................................................................

.............................................................................................................................................................

.............................................................................................................................................................

---

(១)- ដីកានេះ ប្រើសំរាប់ព្រះរាជអាជ្ញា ធ្វើដីកាសន្និដ្ឋានចោទប្រកាន់ស្ថាពរ ជូនរឿងទៅជំនុំជម្រះ តាមរយៈចៅក្រមស៊ើបអង្កេត ។

(២)- រៀបរាប់អំពីដំណើររឿង ឬអង្គហេតុសង្ខេបតាមសំណុំរឿង ក្រោយពីបញ្ចប់ការស៊ើបអង្កេត ។

**បានឃើញ** (៣) ..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

..............................................................................................

---

(៣)- លើកយកលិខិត និងភស្តុតាងសំអាងផ្សេងៗ សំរាប់ធ្វើជាមូលដ្ឋានក្នុងការយល់ឃើញរបស់ខ្លួន ដើម្បីសម្រេចឱ្យបានត្រឹមត្រូវតាមច្បាប់ ។

យល់ឃើញថា(៨) : ..................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

---

(៨) - សន្និដ្ឋានវាយតម្លៃ ពីអំពើរបស់ជនត្រូវចោទ ទៅលើជាតុផ្សំនៃបទល្មើស សំរាប់បញ្ជាក់ថា មានឬគ្មានពិរុទ្ធភាពគ្រប់គ្រាន់ ឬស្លាប់ ឬគេចខ្លួនបាត់ មានឬគ្មានសវតាជាតិគ្រប់គ្រាន់ ។

**<u>ហេតុដូច្នេះ សម្រេច</u>**[៥]

១-ចោទប្រកាន់ឈ្មោះ .......................................... ភេទ............ អាយុ ................ឆ្នាំ ជាតិ.............
របររកស៊ី........................................ ទីលំនៅបច្ចុប្បន្ននៅភូមិ..........................ឃុំ-សង្កាត់.................................

ស្រុក-ខណ្ឌ..................................................ខេត្ត-ក្រុង......................................ទោសពីមុន .........................។

ឪពុកឈ្មោះ.................................................... "រ-ស" ម្ដាយឈ្មោះ ....................................................... "រ-ស"

ប្ដីឬប្រពន្ធឈ្មោះ........................................................"រ-ស" មានកូន ឬនៅលីវ ................................. ត្រូវជាប់ចោទ

ពីបទ.............................................................................. ប្រព្រឹត្តនៅភូមិ.....................................................

ឃុំ-សង្កាត់............................ ស្រុក-ខណ្ឌ................................ ខេត្ត-ក្រុង...........................................កាលពី

ថ្ងៃទី ........... ខែ .................. ឆ្នាំ .................... បទល្មើសដែលមានចែងឱ្យផ្ដន្ទាទោស តាមមាត្រា .......................

នៃច្បាប់ .............................................................................................................................................។

២-បង្គង់បណ្ដឹងអាជ្ញាលើឈ្មោះ ...........................................................................................................

តាមដីកាសម្រេចបង្គង់បណ្ដឹងអាជ្ញាលេខ ............... ចុះថ្ងៃទី ............... ខែ .................... ឆ្នាំ .........................។

៣- រំលត់បណ្ដឹងអាជ្ញាលើឈ្មោះ ..........................................................................................................

តាមដីកាសម្រេចរំលត់បណ្ដឹងអាជ្ញាលេខ .................. ចុះថ្ងៃទី ................. ខែ ........................ ឆ្នាំ ....................។

៤-បញ្ជូនជនជាប់ចោទដូចមានឈ្មោះខាងលើ សំណុំរឿងព្រហ្មទណ្ឌលេខ ................................................
ចុះថ្ងៃទី .................... ខែ.................. ឆ្នាំ ................... និងវត្ថុតាងព្រមទាំងបញ្ជីរាយនាមជនដែលទាក់ទិន
ក្នុងរឿងនេះទៅចៅក្រមស៊ើបអង្កេតនៃតុលាការខេត្ត-ក្រុង .......................................... ដើម្បីចាត់ការតាមច្បាប់ ។

ធ្វើនៅ...................................... ថ្ងៃទី........ ខែ............... ឆ្នាំ..........

**ព្រះរាជអាជ្ញា**

---

(៥)- ផ្អែកតាមសំអាងហេតុ និងការយល់ឃើញរបស់ខ្លួន តំណាងអយ្យការត្រូវសំរេចឱ្យបានច្បាស់លាស់ អំពី ការចោទប្រកាន់ ការបង្គង់បណ្ដឹងអាជ្ញា
និងការរំលត់បណ្ដឹងអាជ្ញាដោយលើកយកមាត្រាច្បាប់មកសំអាងឱ្យបានត្រឹមត្រូវ ។